ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកិច្ចការនារី

# នារីរតនៈទី៤

## ផែនការយុទ្ធសាស្ត្រដើម្បីសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី

## ឆ្នាំ២០១៤ - ២០១៨

# នារីរតនៈទី៤

ផែនការយុទ្ធសាស្ត្រដើម្បីសមភាពយេនឌ័រ
និងការបង្កើនភាពអង់អាចដល់ស្ត្រី

**ឆ្នាំ២០១៤ - ២០១៨**

# អារម្ភកថា

**នារីរតនៈទី៤** គឺជាផែនការយុទ្ធសាស្ត្រ រយៈពេល៥ឆ្នាំ (២០១៤-២០១៨) សម្រាប់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនៅកម្ពុជា ។

តាងនាមក្រសួងកិច្ចការនារី និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នាងខ្ញុំមានកិត្តិយសសូមជម្រាបជូនថា÷

ស្របតាមស្ថានភាពបច្ចុប្បន្ន និងយោងតាម**យុទ្ធសាស្ត្រចតុកោណ** ដំណាក់កាលទី៣ "ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា" ក្រសួងកិច្ចការនារី ក្នុងភាពជាដៃគូជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ បានរៀបចំផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ ក្នុងការបន្តរួមចំណែកលើកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី ។ មូលដ្ឋានគ្រឹះនៃការរៀបចំផែនការយុទ្ធសាស្ត្រនេះ បានផ្អែកលើលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រ**នារីរតនៈទី៣** ២០០៨-២០១៣ និងឯកសារប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា ឆ្នាំ២០១៤ ។ ផែនការយុទ្ធសាស្ត្រនេះបានបង្ហាញនូវទស្សនៈវិស័យសម្រាប់រយៈពេល៥ឆ្នាំខាងមុខ ដោយផ្តោតជាពិសេសលើការពង្រឹងសមត្ថភាព និងអភិវឌ្ឍស្ថាប័នក្នុងរយៈពេលវែងរបស់ក្រសួងកិច្ចការនារី ដើម្បីបំពេញតួនាទីរបស់ខ្លួនក្នុងនាមជាអ្នកសម្របសម្រួល និងផ្តល់យោបល់ជាយុទ្ធសាស្ត្រពាក់ព័ន្ធនឹងបញ្ហាយេនឌ័រដល់ក្រសួងស្ថាប័នពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងក្រោមជាតិ ។ **នារីរតនៈទី៤** បានរៀបចំឡើងសម្រាប់គាំទ្រដល់ក្រសួងកិច្ចការនារី ក្នុងការអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងលើកកម្ពស់មុខងារក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**នារីរតនៈទី៤** បានរួមចំណែកក្នុងការគាំទ្រការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចជាកំណែទម្រង់រដ្ឋសាធារណៈ កម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងកំណែទម្រង់ដីធ្លីជាដើម ។ ជាមួយគ្នានេះ ផែនការយុទ្ធសាស្ត្រ **នារីរតនៈទី៤**ក៏បញ្ជាក់ពីការចូលរួមចំណែក និងផ្សារភ្ជាប់ជាមួយនឹងការអនុវត្តគោលនយោបាយ និងផែនការជាតិសំខាន់ៗ ដូចជាគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយអប់រំសម្រាប់ទាំងអស់គ្នា ផែនការជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ផែនការជាតិស្តីពីការប្រឆាំងនឹងការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ គោលនយោបាយស្តីពីសុវត្ថិភាពសង្គម ផែនការពន្លឿនគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យ និងផែនការយុទ្ធសាស្ត្រក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីជាដើម ។

ផែនការយុទ្ធសាស្ត្រនេះ ក៏បានរៀបចំឡើងស្របតាមអាទិភាពក្នុងកិច្ចអភិវឌ្ឍនាពេលបច្ចុប្បន្ន និងដំណើរវិវឌ្ឍន៍ថ្មីៗនៅកម្ពុជា ក្នុងតំបន់ និងសកលលោក រួមទាំងយោបល់សន្និដ្ឋានរបស់គណៈកម្មាធិការនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី ។ ផែនការយុទ្ធសាស្ត្រមានការពិគ្រោះយោបល់ និងកិច្ចសហការយ៉ាងទូលំទូលាយជាមួយក្រសួង ស្ថាប័នតាមវិស័យ និងដៃគូពាក់ព័ន្ធផ្សេងទៀត ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងដៃគូអភិវឌ្ឍន៍និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានរួមចំណែកឲ្យកាន់តែមានភាពប្រសើរឡើងក្នុងការឆ្លើយតបនឹងបញ្ហាយេនឌ័រនៅកម្ពុជា ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ នឹងបន្តនូវការគាំទ្រ និងកិច្ចសហប្រតិបត្តិការក្នុងស្មារតីខ្ពស់ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ រួមទាំងការអនុវត្តផែនការយុទ្ធសាស្ត្រ "**នារីរតនៈទី៤**" ប្រកបដោយជោគជ័យ និងប្រសិទ្ធភាពសម្រាប់ជាឧត្តមប្រយោជន៍ដល់សង្គមជាតិទាំងមូល។

*រាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ២០១៤*

**រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី**

**អ៊ឹង កន្ថាផាវី**

# មាតិកា


អារម្ភកថា

សេចក្តីផ្តើម ........................................................................................................ ១

សមិទ្ធផលចម្បងៗ និងបញ្ហាប្រឈម........................................................................................២

ផ្នែកទី១÷ ចក្ខុវិស័យ និងបេសកកម្ម.................................................................................. ១២

ផ្នែកទី២÷ គោលបំណង.....................................................................................................១៣

ផ្នែកទី៣÷ ក្របខណ្ឌយុទ្ធសាស្ត្រ............................................................................................១៤

១. កំណើនសេដ្ឋកិច្ច ..............................................................................................១៥

២. លទ្ធភាពទទួលបានសេវាសង្គម និងកិច្ចគាំពារសង្គម................................................ ១៧

៣. បញ្ហាអន្តរវិស័យ ............................................................................................... ២១

៤. ការពង្រឹងស្ថាប័ន និងសមត្ថភាពសម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ ....................... ២៥

ផ្នែកទី៤÷ ផែនការសកម្មភាព ........................................................................................... ២៨

ផ្នែកទី៥÷ ធនធានហិរញ្ញវត្ថុ .............................................................................................៧៦

ផ្នែកទី៦÷ ការពិនិត្យតាមដាន និងការវាយតម្លៃ .................................................................. ៧៧

# សេចក្តីផ្តើម

ក្រសួងកិច្ចការនារី និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី គឺជាយន្តការជាតិសម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ។ ក្រសួងកិច្ចការនារី ដើរតួនាទីជាអ្នកជំរុញ(កាតាលីករ) ស្វែងរកការគាំទ្រមតិ និងសម្របសម្រួលដើម្បីលើកទឹកចិត្តដល់ក្រសួង ស្ថាប័នរដ្ឋ សង្គមស៊ីវិល និងវិស័យឯកជន ក្នុងការបញ្ចូលសមភាពយេនឌ័រ ទៅក្នុងគោលនយោបាយ និងកម្មវិធីរបស់ខ្លួន ។ ក្រសួងទទួលខុសត្រូវក្នុងការត្រួតពិនិត្យតាមដាន និងវាយតម្លៃគោលនយោបាយ និងកម្មវិធីនានា ដើម្បីប៉ាន់ប្រមាណ និងវាស់វែងអំពីការចូលរួមចំណែកធ្វើឱ្យសម្រេចបាននូវគោលដៅរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនៅកម្ពុជា ។

ចាប់តាំងពីឆ្នាំ១៩៩៩ ក្រសួងកិច្ចការនារី បានរៀបចំ និងអនុវត្តនូវផែនការយុទ្ធសាស្ត្រ រយៈពេល៥ឆ្នាំដែលហៅថា **នារីរតនៈ** ។ នៅក្នុងឆ្នាំ២០១៣ ក្រសួងកិច្ចការនារី ក្នុងភាពជាដៃគូជាមួយក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងក្រោមជាតិ បានពិនិត្យលើប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រ**នារីរតនៈទី៣** និងបានរៀបចំផែនការយុទ្ធសាស្ត្រ**នារីរតនៈទី៤** ដែលជាផ្នែកមួយដ៏សំខាន់នៃការអនុវត្ត**យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨** ។

**នារីរតនៈទី៤** ផ្តោតសំខាន់លើការពង្រឹង និងពង្រីកមុខងាររបស់ក្រសួងកិច្ចការនារី ពីរបៀបនៃការអនុវត្តការងារ ដើម្បីឈានទៅការអនុវត្តការងារតាមអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងឈានជាបណ្តើរៗពីភ្នាក់ងារអនុវត្តន៍ផ្ទាល់ ឱ្យទៅជាអ្នកលើកកម្ពស់គណនេយ្យសង្គមសម្រាប់ស្ត្រី និងអ្នកផ្តល់សេវាពិគ្រោះយោបល់ផ្នែកគោលនយោបាយ ដល់ស្ថាប័នពាក់ព័ន្ធ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ។ ស្របជាមួយនឹងការវិវត្តន៍សេដ្ឋកិច្ចកម្ពុជា និងដំណើរឈានឡើងពីប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ក្នុងអនាគតដ៏ខ្លីខាងមុខនេះ និងបន្តឆ្ពោះទៅសម្រេចឱ្យបានជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ ក្នុងស្ថានភាពនេះក៏អាចនឹងបង្កឱ្យមានវិសមភាព និងភាពងាយរងគ្រោះនៃក្រុម និងតំបន់ដែលមិនសូវទទួលបានសេវាពេញលេញ ។ ក្នុងបរិបទនេះ**នារីរតនៈទី៤** ក៏នឹងបញ្ចូលនូវការឆ្លើយតបនឹងក្រុមដែលជាជនងាយរងគ្រោះ និងក្រុមពិការ រួមទាំងតាមតំបន់នានា ដោយផ្អែកលើការវិភាគយេនឌ័រជាក់លាក់តាមវិស័យ និងស្វែងយល់ឱ្យកាន់តែស៊ីជម្រៅលើតំបន់ ឬកន្លែងដែលត្រូវការវិធានការសមស្រប។

**នារីរតនៈទី៤** បង្ហាញសកម្មភាពលំអិតក្នុងការគាំទ្រនៃការឈានទៅរករបៀបធ្វើការងារជាលក្ខណៈអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ដែលផ្តោតសំខាន់លើការអភិវឌ្ឍសមត្ថភាពក្រសួង និងស្ថាប័នពាក់ព័ន្ធ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ ។

ផែនការយុទ្ធសាស្ត្រនេះ នឹងបង្ហាញអំពីចក្ខុវិស័យ បេសកកម្ម និងគោលបំណង រួមទាំងយុទ្ធសាស្ត្រដែលរៀបចំឡើងតាមវិស័យ និងកម្មវិធីអាទិភាពនីមួយៗ ។ នៅក្នុងវិស័យ និងកម្មវិធីអាទិភាពនីមួយៗរបស់**នារីរតនៈទី៤** នឹងមានបង្ហាញអំពីការវិភាគយុទ្ធសាស្ត្រ និងវិធីសាស្ត្រក្នុងការអនុវត្ត ដោយមានកម្មវិធីអភិវឌ្ឍន៍សមត្ថភាព និងស្ថាប័នជាក្របខណ្ឌទ្រទ្រង់ ។

# សមិទ្ធផលចម្បងៗ និងបញ្ហាប្រឈម

នៅក្នុងនីតិកាលទី៤ នៃរដ្ឋសភាកន្លងមកនេះ ក្នុងការជំរុញសមភាពយេនឌ័រ និងលើកស្ទួយស្ថានភាពស្ត្រី ដែលជា**ឆ្អឹងខ្នងនៃសេដ្ឋកិច្ចនិងសង្គមជាតិ** រាជរដ្ឋាភិបាលបានអនុវត្តផែនការយុទ្ធសាស្ត្រ**នារីរតនៈទី៣** ២០០៩-២០១៣ ដោយផ្តោតទៅលើការពង្រីកកាលានុវត្តភាពសេដ្ឋកិច្ច សង្គម និងអភិបាលកិច្ចនៅគ្រប់កម្រិត ។ យេនឌ័រត្រូវបានដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ដោយបានបញ្ចូលនូវសូចនាករជាក់លាក់មួយចំនួនសម្រាប់តាមដាន និងការអនុវត្ត ។

នៅក្នុងការអនុវត្ត**នារីរតនៈទី៣** រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងកិច្ចការនារី ក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធនានា ទទួលបានជោគជ័យគួរជាទីកត់សម្គាល់ ក្នុងការចូលរួមចំណែកលើកកម្ពស់គោលនយោបាយ ច្បាប់ និងកម្មវិធីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យឆ្លើយតបនឹងយេនឌ័រ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី រួមទាំងការចូលរួមក្នុងការគ្រប់គ្រងបម្រែបម្រួលអាកាសធាតុនិងបរិស្ថាន ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី ការចូលរួមធ្វើឱ្យប្រសើរឡើងនូវសុខភាព និងអាហារូបត្ថម្ភសម្រាប់ស្ត្រីនិងក្មេងស្រី ការទប់ស្កាត់ការរីករាលដាលជំងឺអេដស៍ និងការលើកកម្ពស់ការចូលរួមរបស់កុមារីនិងស្ត្រីក្នុងការអប់រំសិក្សា ជាមួយនឹងការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ រួមទាំងការបង្កើនការចូលរួមរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចគ្រប់កម្រិត ។

## ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

កម្ពុជាទទួលបានសមិទ្ធផលគួរជាទីកត់សម្គាល់ក្នុងការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។ រាជរដ្ឋាភិបាល មានគោលដៅរយៈពេលវែង ក្នុងការបង្កើតការងារ និងធានានូវលក្ខខណ្ឌការងារ[1] ដែលនឹងចូលរួមចំណែកដោយផ្ទាល់លើការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។សន្ទស្សន៍វិសមភាពយេនឌ័រ ក្នុងឆ្នាំ២០១៣ បានបង្ហាញថាការចូលរួមរបស់ស្ត្រី ក្នុងទីផ្សារការងារមាន ៧៩,២%។ នៅក្នុងសន្ទស្សន៍គម្លាតយេនឌ័រសកល ក្នុងឆ្នាំ២០១៣ ទាក់ទងនឹងការចូលរួមក្នុងផ្នែកសេដ្ឋកិច្ច កម្ពុជាទទួលបានចំណាត់ថ្នាក់ខ្ពស់មធ្យមសម្រាប់ការចូលរួមរបស់ស្ត្រី ក្នុងកម្លាំងពលកម្ម[2]។ ការរីកលូតលាស់នៃវិស័យពាណិជ្ជកម្ម សេវាកម្ម ផលិតកម្ម កសិកម្ម សណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋាន បានផ្តល់ការងារប្រមាណ ៨៩% នៃការងារសរុបរបស់ស្ត្រី[3]។ ឱកាសការងារមានទំហំកាន់តែច្រើនសម្រាប់ស្ត្រី និងបុរស ចំណែកឯការងារដែលងាយរងគ្រោះក៏មានការថយចុះ ។ អត្រានៃភាពក្រីក្រធ្លាក់ចុះពី ២៩,៩% ក្នុងឆ្នាំ២០០៨ មកនៅត្រឹម ១៩,៨% ក្នុងឆ្នាំ២០១១[4]។

រាជរដ្ឋាភិបាលបានផ្តោតលើការពង្រីកកាលានុវត្តភាពសេដ្ឋកិច្ចដល់ស្ត្រី និងផ្តល់ការគាំទ្រដល់ស្ត្រី ក្នុងការបង្កើនប្រាក់ចំណូលដល់គ្រួសារ រួមទាំងការបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីនៅក្នុងខេត្តចំនួន១៣ក្នុងការផ្តល់នូវ

1 ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨
2 វេទិកាពិភពលោក ស្តីពីសេដ្ឋកិច្ច ក្នុងរង្វាស់គម្លាតយេនឌ័រ ឆ្នាំ២០១៤
3 អង្កេតប្រជាសាស្ត្រចន្លោះជំរឿនកម្ពុជា ឆ្នាំ២០១៣ វិទ្យាស្ថានជាតិស្ថិតិ
4 បន្ទាត់អត្រាភាពក្រីក្រថ្នាក់ជាតិថ្មីនេះ គឺជាការប៉ាន់ប្រមាណដ៏ទាបលើការចំណាយសម្រាប់ជីវភាពរស់នៅ ដោយផ្អែកលើការចំណាយសម្រាប់កាឡូរី ២ ២០០ និងការចំណាយតូចៗផ្សេងៗទៀតមិនមែនសម្រាប់អាហារ ។ បន្ទាត់ភាពក្រីក្រថ្មីរបស់ប្រទេសកម្ពុជា គឺ ៣ ៨៧១រៀល ក្នុងមួយថ្ងៃ (សម្រាប់មនុស្សម្នាក់) នៅឆ្នាំ២០០៩ អត្រានេះមានកម្រិតខ្ពស់ជាងនៅទីក្រុងភ្នំពេញ និងតំបន់ជុំវិញទីក្រុង និងទាបជាងសម្រាប់តំបន់ឆ្ងាយដាច់ស្រយាល (ក្រសួងផែនការ ឆ្នាំ២០១៣)។

ជំនាញវិជ្ជាជីវៈ និងសេវាអភិវឌ្ឍន៍អាជីវកម្មជូនស្ត្រី ។ ជាលទ្ធផល ស្ត្រីប្រមាណ១៣ ១០២នាក់ ទទួលបានការវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈពីមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី។ សមាគមសហគ្រិនស្ត្រីកម្ពុជាបានបង្កើតឡើង ក្នុងឆ្នាំ២០១២ ដែលមានសមាជិក១៥០នាក់ ក្នុងគោលបំណងជួយអភិវឌ្ឍមុខរបរស្ត្រី ព្រមទាំងពង្រឹងសំឡេងស្ត្រីសហគ្រិននៅក្នុងវិស័យឯកជន ។

ក្របខណ្ឌពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលផ្តោតលើការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រី ក៏បានរៀបចំឡើងដើម្បីកៀរគរការចូលរួមពីបណ្តាដៃគូពាក់ព័ន្ធពីស្ថាប័នរដ្ឋ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ក្នុងការសម្រេចនូវយុទ្ធសាស្ត្របីសំខាន់ៗ គឺ ១. ការពង្រឹងជំនាញវិជ្ជាជីវៈដល់ស្ត្រីទៅតាមតម្រូវការទីផ្សារ ២. ការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យមសម្រាប់ស្ត្រី និង៣. ការបង្កើនជីវភាពរស់នៅតាមជនបទ ជាពិសេសដល់ស្ត្រី ។

ទោះបីជាមានការប្តេជ្ញាចិត្តខ្ពស់ និងការប្រឹងប្រែងជាច្រើនក៏ដោយ ក៏នៅក្នុងដំណើរការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី នៅជួបបញ្ហាប្រឈមមួយចំនួន÷

- ការងារមានប្រាក់កម្រៃផ្តល់ឱកាសជាច្រើនសម្រាប់ស្ត្រី ប៉ុន្តែប្រាក់ឈ្នួលនៅមានកម្រិតទាប លក្ខខណ្ឌការងារមិនសូវអំណោយផល គម្លាតរវាងតម្រូវការការងារ ជាមួយនឹងការផ្គត់ផ្គង់ការងារ និងសមាហរណកម្មអាស៊ាន ។
- ស្ត្រីមានសក្តានុពលជាច្រើនក្នុងការបង្កើត និងពង្រីកអាជីវកម្មខ្នាតតូច មីក្រូ និងមធ្យម ប៉ុន្តែពួកគេជួបឧបសគ្គជាទាក់ទងនឹងលទ្ធភាពទទួលបានធនធាន និងសេវាអភិវឌ្ឍន៍អាជីវកម្ម រួមទាំងធនធានហិរញ្ញវត្ថុ ។ លើសពីនេះ សហគ្រាសរបស់ស្ត្រីភាគច្រើន ស្ថិតក្នុងវិស័យឧស្សាហកម្មដែលមានផលិតកម្មទាប ។
- ខណៈដែលឱកាសការងារនៅក្នុងស្រុក និងវិស័យសហគ្រាសខ្នាតតូច និងមធ្យមមានការកើនឡើង ស្ត្រីកាន់តែច្រើនកំពុងចំណាកស្រុកពីជនបទមកទីក្រុង និងទៅក្រៅប្រទេស ដើម្បីស្វែងរកការងារ ។ ជាទូទៅពួកគាត់ជួបហានិភ័យច្រើនជាងបុរស រួមទាំងអំពើហិង្សាលើរាងកាយ ។
- កិច្ចសហការរវាងស្ថាប័នពាក់ព័ន្ធនៅមិនទាន់មានប្រសិទ្ធភាពពេញលេញនៅឡើយ ក្នុងការផ្តល់សេវាពាក់ព័ន្ធនឹងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក៏ដូចជាការផ្តល់អន្តរាគមន៍នានា ដើម្បីជំរុញឱ្យស្ត្រីទទួលបាននូវកាលានុវត្តភាពការងារ ឬអភិវឌ្ឍន៍សហគ្រិនភាពរបស់ស្ត្រី ។
- កិច្ចសហការ ឬការទុកចិត្តរវាងវិស័យសាធារណៈ និងវិស័យឯកជន នៅមានការខ្វះខាតនៅឡើយ ដើម្បីបង្កើនសេវាកម្មរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ។

## ការអប់រំសម្រាប់ស្ត្រី និងក្មេងស្រី និងការផ្លាស់ប្តូរឥរិយាបថ

គម្លាតយេនឌ័រ ក្នុងវិស័យអប់រំបានកាត់បន្ថយគួរគប់កម្រិត តាមរយៈការបង្កើនចំនួនអាហារូបករណ៍ដល់សិស្ស និស្សិតក្រីក្រ ពិសេសនារី បង្កើនចំនួនគ្រឹះស្ថានអប់រំនៅមូលដ្ឋាន បង្កើនចំនួនអន្តេវាសិកដ្ឋានដែលផ្តល់សេវាសមរម្យ និងសុវត្ថិភាពសម្រាប់សិស្សស្រីជាដើម ។

ចាប់តាំងពីឆ្នាំ២០០៨យេនឌ័របានបន្តបញ្ជ្រាបទៅក្នុងគោលនយោបាយ កម្មវិធី និងផែនការក្នុងវិស័យអប់រំ យុវជន និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចជាផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣ ផែនការគោលស្តីពីការអភិវឌ្ឍកម្មវិធីសិក្សា ២០១០-២០១៤ ផែនការអភិវឌ្ឍន៍គ្រូបង្រៀន ២០១០-២០១៤ ផែនការគោលសម្រាប់ការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ ២០១១-២០១៥ ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ២០១១-២០១៥

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន គោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ គោលនយោបាយស្តីពីសាលាកុមារមេត្រីសម្រាប់អប់រំមូលដ្ឋាន គោលនយោបាយស្តីពីគ្រូបង្រៀន ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨ និងយុទ្ធសាស្ត្រសមធម៌យេនឌ័រ ក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៤ ជាដើម ។

ច្បាប់ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រទាំងនេះ បាន និងកំពុងរួមចំណែកក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យអប់រំ និងបណ្តុះបណ្តាល តាមរយៈការផ្តល់បរិយាកាសល្អផ្នែករូបវ័ន្ត ការបង្កើនកាលានុវត្តភាពក្នុងការទទួលបាននូវការអប់រំ និងបណ្តុះបណ្តាល ការកែប្រែឥរិយាបថសង្គមដែលរើសអើងលើនារី និងការផ្តល់បរិយាកាសអំណោយផលដល់ការចូលរួមរបស់ស្ត្រីនៅគ្រប់ផ្នែក និងកម្រិត ។ នៅកម្រិតមត្តេយ្យសិក្សា ការចូលរៀនរបស់កុមារតូចទាំងពីរភេទមានការកើនឡើងជាបន្តបន្ទាប់ ដែលបានរួមចំណែកក្នុងការបង្កើនភាពវៃឆ្លាត និងទំនុកចិត្តរបស់កុមារនៅពេលចូលរៀននៅបឋមសិក្សា[5]។ នៅបឋមសិក្សា និងមធ្យមសិក្សា ការចុះឈ្មោះចូលរៀនសិស្សស្រីមានចំនួនប្រហាក់ប្រហែលគ្នានឹងសិស្សប្រុស[6]។ ក្នុងឆ្នាំ២០១២ កុមារីបានចុះឈ្មោះចូលរៀនច្រើនជាងកុមារា និងចំនួនសរុបច្រើនជាងកុមារា នៅកម្រិតមធ្យមសិក្សាបឋមភូមិ[7] ។ នៅឧត្តមសិក្សា សមាមាត្រនិស្សិតស្រីកំពុងមានការកើនឡើងជាបណ្តើរៗ ពី៣៣% ក្នុងឆ្នាំ២០០៨ ដល់៣៧,៦% ក្នុងឆ្នាំ២០១១[8]។ ការចូលរួមរបស់ស្ត្រីនៅក្នុងការអប់រំ ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ។

គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ បានអនុវត្តការងារតាមយុទ្ធសាស្ត្រពហុវិស័យលើការងារសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ក្នុងគោលបំណងថែរក្សាការងារវប្បធម៌ជាតិ ធានាដល់ការគោរពសីលធម៌សង្គម និងសុភមង្គលនៅក្នុងគ្រួសារ ដោយលើកកម្ពស់ស្ថានភាពតួនាទី និងសុខុមាលភាពស្ត្រីខ្មែរ ។ គ្រប់ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងក្រោមជាតិ បានសហការអនុវត្តដើម្បីកាត់បន្ថយភាពអសីលធម៌ក្នុងសង្គម ឈានដល់ការបង្ក្រាបបទល្មើសរំលោភបំពានដល់សិទ្ធិស្ត្រី និងកុមារ អំពើហិង្សាគ្រប់រូបភាព ការជួញដូរមនុស្ស ការឆក់ប្លន់ និងការប្រព្រឹត្តគ្រឿងញៀន ។

ទទ្ទឹមនឹងការរីកចម្រើន បញ្ហាប្រឈមមួយចំនួន ក៏នៅបន្តកើតមានដូចខាងក្រោម÷

- ផ្នត់គំនិតសង្គមដែលផ្តល់តម្លៃដល់ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ក្មេងប្រុស ច្រើនជាងក្មេងស្រី អនក្ខរភាពរបស់មាតាបិតា អំពើហិង្សាក្នុងគ្រួសារ ការរៀបអាពាហ៍ពិពាហ៍របស់ក្មេងស្រីដែលមិនទាន់គ្រប់អាយុ និងកត្តាជីវភាពគ្រួសារនៅតែបន្តកើតមានដែលនាំឱ្យប៉ះពាល់ជាអវិជ្ជមានដល់ការសិក្សារបស់កូនស្រី ។
- កិច្ចគាំពារដល់កុមារនៅមានកម្រិត ជាពិសេសសម្រាប់កុមារី ទាក់ទងនឹងការធ្វើដំណើរទៅមកដោយសុវត្ថិភាព និងសុខភាពអនាម័យ ។
- ការចូលរួមរបស់សហគមន៍ និងមាតាបិតាក្នុងសកម្មភាពរបស់សាលា ក៏ដូចជាការសិក្សាសិស្សនៅមានកម្រិត ។
- កំណើនឧស្សាហកម្ម និងសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ក្នុងឆ្នាំ២០១៥ ទាមទារឱ្យមានជំនាញសមស្រប

5 UIS online database UNESCO Institute for Statistics. Available online at: *data.uis.unesco.org*
6 ក្រសួងអប់រំ យុវជន និងកីឡា ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ឆ្នាំ (២០០៨ ២០០៩ ២០១០ ២០១១)
7 ក្រសួងអប់រំ យុវជន និងកីឡា ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ឆ្នាំ២០១២
8 ក្រសួងអប់រំ យុវជន និងកីឡា ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ឆ្នាំ (២០០៨ ២០០៩ ២០១០ ២០១១)

សម្រាប់ក្មេងស្រី និងក្មេងប្រុស ដើម្បីចូលក្នុងទីផ្សារការងារ ស្របពេលជាមួយគ្នានៃការកើនឡើងនូវសម្ភារនិយមក្នុងសង្គម។

- កូនរបស់ស្ត្រីដែលរងគ្រោះពីអំពើហិង្សាទាក់ទងយេនឌ័រ កុមារីពិការ ស្ត្រីស្រឡាញ់ភេទដូចគ្នា និងក្រុមមនុស្សកែភេទ មានអត្រាអវត្តមាន និងបោះបង់ចោលការសិក្សាច្រើនជាងគេ ដោយសារតែស្ថានភាពផ្ទាល់ខ្លួន និងស្ថានភាពគ្រួសាររបស់ពួកគេ ឬដោយសារមានការរើសអើងពីមិត្តរួមថ្នាក់ ។

## យេនឌ័រ និងសុខភាព

អត្រាមរណភាពមាតា (MMR) មានការថយចុះច្រើនជាងពាក់កណ្ដាល គឺពី ៤៧២ ក្នុងចំណោម ១០០ ០០០ កំណើតរស់ ក្នុងឆ្នាំ២០០៥ មកត្រឹម ២០៦ ក្នុងចំណោម១០០ ០០០ កំណើតរស់ ក្នុងឆ្នាំ២០១០[9]។ ជាមួយគ្នានេះដែរ ការទទួលបានការថែទាំសុខភាពមាតាក៏មានភាពប្រសើរឡើងជាលំដាប់ ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ[10]។ និន្នាការវិជ្ជមានទាំងនេះបានបន្តដោយសារមានអន្តរាគមន៍ជាច្រើនរបស់ក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី ព្រមទាំងស្ថាប័ន និងដៃគូពាក់ព័ន្ធ ក្នុងការពង្រីកការផ្ដល់សេវាថែទាំសុខភាពនៅតាមមណ្ឌលសុខភាព កម្មវិធីអប់រំ និងផ្សព្វផ្សាយដោយភ្នាក់ងារអប់រំសុខភាពភូមិ។ អត្រាជំងឺក្រិនចំពោះកុមារមានការថយចុះពី ៥០% ក្នុងឆ្នាំ២០០០ មកត្រឹម ៤០% ក្នុងឆ្នាំ២០១០ ។ អត្រាស្គមស្លាំងថយចុះពី ១៧% ក្នុងឆ្នាំ២០០០ មក១១% ក្នុងឆ្នាំ២០១០ ។ អត្រាកុមារមានជំងឺខ្វះទម្ងន់ថយចុះពី ៣៩% ក្នុងឆ្នាំ២០០០ មក២៨% ក្នុងឆ្នាំ២០១០[11]។

ព័ត៌មាន ស្ដីពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ គឺមានសារៈសំខាន់សម្រាប់ផ្ដល់ដល់យុវវ័យឱ្យយល់ដឹងពីសិទ្ធិបន្តពូជ និងសិទ្ធិផ្លូវភេទរបស់ពួកគេ។ ក្នុងឆ្នាំ២០១៣ រាជរដ្ឋាភិបាលបានអនុម័តនូវកម្មវិធីសិក្សាដ៏ទូលំទូលាយមួយសម្រាប់យុវវ័យនៅថ្នាក់បឋម និងមធ្យមសិក្សា និងយុវវ័យនៅក្រៅសាលា ដោយរួមបញ្ចូលនូវព័ត៌មានស្ដីពីសិទ្ធិសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ភ្ជាប់នឹងអាយុ យេនឌ័រ អំពើហិង្សាទាក់ទងនឹងយេនឌ័រ គ្រឿងញៀន ការអប់រំបំណិនជីវិត និងមេរោគអេដស៍ ជំងឺអេដស៍ ។

ស្របជាមួយនឹងការរីកចម្រើនជាបន្តបន្ទាប់ ក៏បញ្ហាប្រឈមមួយចំនួននៅបន្តកើតមាន÷

- បញ្ហាមួយចំនួននៅតែកើតមាន គឺការខ្វះខាតអ្នកផ្ដល់សេវាដែលមានជំនាញនៅតំបន់ដាច់ស្រយាល ការខ្វះខាតឱសថ និងសម្ភារៈបរិក្ខារទំនើបនៅក្នុងមូលដ្ឋានសុខាភិបាល និងការយល់ដឹង និងឥរិយាបថរបស់ស្ត្រីក្នុងការស្វែងរកព័ត៌មាន និងសេវាព្យាបាលមានកម្រិតទាប ដោយសារតែកត្តាសង្គម វប្បធម៌ និងសេដ្ឋកិច្ច[12]។
- ទោះបីជាអត្រាមរណភាពមាតាមានការថយចុះគួរកត់សម្គាល់ក៏ដោយ ប៉ុន្តែនៅមានវិសមភាពនៅឡើយទាក់ទងនឹងការទទួលបានសេវាសុខភាព ហើយអត្រានេះនៅតែមានកម្រិតខ្ពស់ បើធៀបនឹងប្រទេសនានាក្នុងតំបន់ ។ ទោះបីជាអត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់មធ្យោបាយពន្យាកំណើតមានការកើនឡើងជាបន្តបន្ទាប់ក៏ដោយ ប៉ុន្តែពុំទាន់គ្រប់តាមតម្រូវការនៅឡើយ (នៅខ្វះ១៧%)[13]។
- ជំងឺមួយចំនួនទៀតដែលកំពុងមានការកើនឡើងគួរជាទីបារម្ភ ហើយស្ត្រីជួបប្រទះនូវការខ្វះខាតក្នុងការ

---

9 អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០១០

10 Wang, Wenjuan (2013) *Assessing Trends in Inequalities in Maternal and Child Health and Health Care in Cambodia. DHS* Further Analysis Reports No. 86. Calverton, Maryland, USA: ICF International.

11 អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ២០១០

12 Frieson et al ឆ្នាំ២០១០

13 អង្កេតប្រជាសាស្ត្រ និងសុខភាព ២០១០

ទទួលបានសេវាពិនិត្យសុខភាព ដូចជាជំងឺមហារីកសុដន់ និងសុដន់ជាដើម ។

- ផលប៉ះពាល់អវិជ្ជមាន នៃស្ថានភាពអាហារូបត្ថម្ភ អាចជាប់ទាក់ទងនឹងលទ្ធភាពទទួលបានទឹកស្អាត និងបង្គន់អនាម័យនៅមានកម្រិត។
- អត្រាប្រេវ៉ាឡង់នៃភាពពិការភ្នែក គឺមានកម្រិតខ្ពស់ក្នុងចំណោមស្ត្រី អាយុលើសពី៥០ឆ្នាំ គឺ ៣,៤% ធៀបទៅនឹង២% ក្នុងចំណោមបុរសនៅក្នុងក្រុមអាយុដូចគ្នា ។ មិនមានការពន្យល់ពីភាពខុសគ្នានៃអត្រាប្រេវ៉ាឡង់ នៃភាពពិការភ្នែកក្នុងចំណោមបុរស និងស្ត្រីនៅឡើយ ដែលចំណុចនេះទាមទារឱ្យមានការសិក្សាស្រាវជ្រាវជាបន្តទៀត និងពង្រីកការផ្តល់សេវាគាំទ្រឱ្យបានទូលំទូលាយផងដែរ[14] ។
- ឧបសគ្គមួយដែលនៅតែបន្តកើតមានក្នុងប្រទេសជាច្រើន ក៏ដូចជានៅកម្ពុជា គឺភាពរុញរាក្នុងការនិយាយដោយបើកចំហ អំពីរឿងរ៉ាវផ្លូវភេទ ជាពិសេសរវាងមាតា និងយុវវ័យ ។

## យេនឌ័រ និងមេរោគអេដស៍

អត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមបុរស និងស្ត្រីអាយុពី១៥ទៅ៤៩ឆ្នាំ បានថយចុះគួរឱ្យកត់សម្គាល់ពី ១,៧០% ក្នុងឆ្នាំ១៩៩៨ មកនៅត្រឹមប្រមាណ ០,៧% ក្នុងឆ្នាំ២០១៤[15] ។ ដោយសារមានការថយចុះនូវការឆ្លងថ្មីតាមរយៈកិច្ចខិតខំប្រឹងប្រែងក្នុងការបង្ការដែលមានគោលដៅច្បាស់លាស់ ជាពិសេសក្នុងចំណោមក្រុមដែលប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់ក្នុងការឆ្លងមេរោគអេដស៍ ការកើនឡើងអត្រាអ្នកធ្វើតេស្តឈាមរកមេរោគអេដស៍ ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និងភាពកាន់តែប្រសើរឡើងក្នុងការផ្តល់សេវាព័ត៌មាន និងទំនាក់ទំនងរបស់ក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ ។ កម្ពុជាសម្រេចបាននូវគោលដៅទាក់ទងនឹងលទ្ធភាពទទួលបានសេវាជាសកលសម្រាប់ព្យាបាលស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុស ក្នុងអត្រាមួយខ្ពស់ គឺរហូតដល់ទៅ៨៩,៥% នៃក្រុមប្រជាជនដែលមានតម្រូវការ[16]។ ជាលទ្ធផលដែលកើតចេញពីសមិទ្ធផលនេះ ចំនួនប៉ាន់ស្មានអ្នកស្លាប់ដោយសារជំងឺអេដស៍ និងការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ក៏មានការថយចុះគួរឱ្យកត់សម្គាល់ នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ។ ដោយមានការចូលរួមពីក្រសួង និងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៣ ២០១១-២០១៥ រួមទាំងកម្មវិធីបណ្តុះបណ្តាល និងគោលការណ៍ណែនាំ ស្តីពីការ បញ្ជ្រាបយេនឌ័រទៅក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ។ ក្រសួងកិច្ចការនារី ក៏បានរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រ ស្តីពីស្ត្រី ក្មេងស្រី និងមេរោគជំងឺអេដស៍ ២០០៨-២០១២ និងកម្មវិធីបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ទៅក្នុងដំណើរការលើកកម្ពស់សមភាពយេនឌ័រ ។

បញ្ហាប្រឈមមួយចំនួនក៏នៅបន្តកើតមាន ដូចខាងក្រោម÷

- ការរួមភេទរវាងមនុស្សដែលមានភេទដូចគ្នា គឺជាបែបផែនចម្បងនៃការចម្លងមេរោគអេដស៍ ។
- ការឆ្លងមេរោគអេដស៍មកលើស្ត្រីច្រើនជាងពាក់កណ្តាល នៃមនុស្សពេញវ័យ អាចបណ្តាលមកពីកត្តាជីវសាស្ត្ររបស់ស្ត្រីដែលងាយទទួលការឆ្លង និងដោយសារភាពទន់ខ្សោយរបស់ពួកគាត់ ព្រមទាំងបរិបទផ្នត់គំនិតសង្គម និងកង្វះសិទ្ធិអំណាចក្នុងការចរចាពីសុវត្ថិភាពផ្លូវភេទ ឬការប្រើប្រាស់ស្រោមអនាម័យ ។

---

[14] Seiha D, Limburg H. Report of the Rapid Assessment for Avoidable Blindness in Cambodia - 2007 កម្មវិធីជាតិសុខភាពភ្នែក ២០០៩

[15] National Centre for HIV/AIDS, Dermatology and STIs, (2011). HIV Estimates and Projections of HIV/AIDS in Cambodia 2011-2015: Report of a Census Workshop. Phnom Penh: Ministry of Health Surveillance Unit, 2011.

[16] របាយការណ៍វឌ្ឍនភាព ឆ្នាំ២០១២ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍

ស្ត្រី និងក្មេងស្រីមួយចំនួនទទួលរងគ្រោះខ្លាំងនូវអំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងការរំលោភសេពសន្ថវៈ ហើយក៏អាចជាហេតុនាំឱ្យឆ្លងមេរោគអេដស៍ផងដែរ ។

- កង្វះថវិកា ការខ្វាចអ្នកដទៃដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ និងឥរិយាបថអវិជ្ជមានក្នុងចំណោមអ្នកផ្ដល់សេវាមួយចំនួនដែលគ្មានឯកទេសខាងជំងឺអេដស៍ បានបង្កជាឧបសគ្គដល់ស្ត្រីដែលផ្ទុកមេរោគអេដស៍ក្នុងការទទួលបានសេវា និងព័ត៌មានត្រឹមត្រូវ អំពីផែនការគ្រួសារ និងការថែទាំទារក ។
- ក្រុមគោលដៅមួយចំនួនងាយរងគ្រោះខ្លាំងក្នុងការឆ្លង និងចម្លងមេរោគអេដស៍ ដូចជាស្ត្រីបំរើការតាមកន្លែងកំសាន្ត ស្ត្រីប្រើប្រាស់ ឬចាក់គ្រឿងញៀន និងស្ត្រីជាប់ពន្ធនាគារ ក្រុមស្រឡាញ់ភេទដូចគ្នា និងក្រុមយុវវ័យ[17] ។ កង្វះការយល់ដឹងទូលំទូលាយ ស្តីពីមេរោគអេដស៍ ការប្រព្រឹត្តរួមភេទប្រកបដោយគ្រោះថ្នាក់ ការប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀន រួមជាមួយនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័របានបង្កើនគ្រោះថ្នាក់នៃការចម្លងមេរោគអេដស៍ក្នុងចំណោមក្រុមគោលដៅទាំងនេះ ។
- គោលនយោបាយ និងគោលការណ៍ណែនាំគ្លីនិកសម្រាប់ឆ្លើយតបនឹងអំពើហិង្សាដែលកើតមានដោយសារដៃគូរួមភេទ និងអំពើហិង្សាផ្លូវភេទកំពុងរៀបចំ ប៉ុន្តែនាបច្ចុប្បន្ន ពុំទាន់មានការផ្ដល់នូវការបង្ការការចម្លងមេរោគអេដស៍ដោយមិនបង់ប្រាក់នៅឡើយទេ ក្នុងករណីដែលមានការបំពានផ្លូវភេទជាពិសេសក្នុងចំណោមស្ត្រីដែលប្រឈមមុខខ្ពស់នឹងការចម្លងមេរោគអេដស៍ ។ សេវាជំនួយផ្លូវច្បាប់សម្រាប់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកដែលប្រឈមមុខខ្ពស់នឹងការចម្លងមេរោគអេដស៍នៅមានកម្រិតនៅឡើយ ។

## អំពើហិង្សាលើស្ត្រី និងក្មេងស្រី

តាមការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០០៥ បង្ហាញថាស្ត្រីដែលធ្លាប់ទទួលរងនូវអំពើហិង្សាលើផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្តពីដៃគូរបស់ខ្លួន មានការថយចុះពី២៥% ក្នុងឆ្នាំ២០០០ មកត្រឹម២២% ក្នុងឆ្នាំ២០០៥[18] ។ តាមទិន្នន័យឃុំ សង្កាត់ ចំនួនគ្រួសារ[19]ដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារដែលស្វែងរកជំនួយពីអាជ្ញាធរមូលដ្ឋាន បានបង្ហាញថា ចំនួនគ្រួសារដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារបានថយចុះពី១,៦៣% ក្នុងឆ្នាំ២០០៦ មកត្រឹម០,៨៨% ក្នុងឆ្នាំ២០១០[20] ។ សរុបមក ការប្រៀបធៀបការអង្កេតតាមដានដែលធ្វើឡើងដោយក្រសួងកិច្ចការនារី ឆ្នាំ២០០៥ និងឆ្នាំ២០០៩ បានបង្ហាញថាប្រជាជនភាគតិចបានទទួលស្គាល់អំពើហិង្សា ជាអំពើដែលអាចទទួលយកបាន និងប្រជាជនភាគច្រើនបានទទួលស្គាល់ថាការប្រព្រឹត្តអំពើហិង្សាជាការល្មើសច្បាប់[21]។

តាមការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០១០ បានបង្ហាញថាស្ត្រីដែលយល់ស្របថាមានហេតុផលយ៉ាងតិចមួយដែលបុរសអាចវាយប្រពន្ធរបស់គាត់បាន មានការថយចុះពី ៥៥% ក្នុងឆ្នាំ២០០៥

---

17 Liu, K. L. & Chhorvann, C. (2010). Bros Khmer: Behavioral Risks On-site Serosurvey among At-risk Urban Men in Cambodia. Phnom Penh: FHI 360 & National Centre for HIV/AIDS, Dermatology and STIs. National AIDS Authority, (2012a). Cambodia Country Progress Report 2012: Monitoring the Progress towards the Implementation of the Declaration of Commitment on HIV and AIDS. Phnom Penh.

18 អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ឆ្នាំ២០០៥

19 The reports to the CDB are of families not individuals and therefore not disaggregated by type of violence, perpetrator or victim

20 CDB Online. 2013. http://db.ncdd.gov.kh/cdbonline/home/index.castle (accessed November, December 2013).

21 អង្កេតតាមដាន អំពើហិង្សាលើស្ត្រី ឆ្នាំ២០០៩ ក្រសួងកិច្ចការនារី Ministry of Women"s Affairs (2009) *Violence Against Women, Follow Up Survey.* Phnom Penh.

មកត្រឹម ៤៥,៧% ក្នុងឆ្នាំ២០១០[22]។ ក្របខណ្ឌគោលនយោបាយក្នុងការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រី កាន់តែមានភាពប្រសើរឡើងក្នុងរយៈពេលកន្លងមក ។ ផែនការសកម្មភាពជាតិទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-២០១៨ បានរៀបចំឡើងដោយគ្របដណ្តប់លើវិស័យជាយុទ្ធសាស្ត្រចំនួនប្រាំ រួមមាន ១.កិច្ចការពារបឋម ២.កិច្ចការពារពហុវិស័យនិងសេវាផ្នែកច្បាប់ ៣.ច្បាប់ និងគោលនយោបាយ ៤.ការអភិវឌ្ឍសមត្ថភាព និង ៥.ការត្រួតពិនិត្យ និងវាយតម្លៃ ។

នៅឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដែលនៅក្នុងចំណោមវិធានការសំខាន់ៗ មានចំណុចដែលពាក់ព័ន្ធនឹងគ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានការជួញដូរស្ត្រី និងកុមារ ។

ការយល់ដឹងពីភាពងាយរងគ្រោះរបស់ស្ត្រី និងកុមារីពីអំពីហិង្សា ឬបញ្ហាប្រឈមនានា និងការទទួលបាននូវកិច្ចការពារ និងសេវាសង្គមមានការកើនឡើងជាងមុន ។ កន្លងមក ការអង្កេតស្រាវជ្រាវជាច្រើនបានធ្វើឡើង និងបានជួយបង្កើនចំណេះដឹងពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីនៅកម្ពុជា ។ ការយកចិត្តទុកដាក់បានបង្កើន តាមរយៈការផ្តល់នូវសេវាសង្គមពហុវិស័យ ក៏ដូចជាការគាំទ្រផ្នែកច្បាប់ ដើម្បីជួយដល់ស្ត្រី និងកុមារដែលជាជនរងគ្រោះដោយអំពើហិង្សា ។

ទោះជាយ៉ាងណា បញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី ក៏នៅបន្តកើតមាន÷

- ទោះបីមានទិន្នន័យមួយចំនួនដែលបញ្ជាក់ថា អំពើហិង្សារវាងប្តីនឹងប្រពន្ធមានការថយចុះក៏ដោយ ប៉ុន្តែអត្រាប្រេវ៉ាឡង់នៅតែមានកម្រិតខ្ពស់ ។ ចំណុចនេះ តម្រូវឱ្យមានទិន្នន័យថ្មីៗដើម្បីស្វែងយល់បានកាន់តែច្បាស់ អំពីស្ថានភាពបច្ចុប្បន្ន ។
- ទិន្នន័យដែលផ្តល់ដោយជនរងគ្រោះទាក់ទងនឹងអំពើរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទនៅមានកម្រិត ប៉ុន្តែរបាយការណ៍អំពីអំពើរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទទាំងនៅក្នុងគ្រួសារ និងនៅកន្លែងផ្សេងទៀត គឺមានការកើតឡើងច្រើន ។
- ទោះបីក្របខណ្ឌច្បាប់កាន់តែមានភាពប្រសើរ ប៉ុន្តែមធ្យោបាយរបស់អាជ្ញាធរពាក់ព័ន្ធ រួមទាំងជំនាញ និងសម្ភារៈស៊ើបអង្កេត និងគោលការណ៍ណែនាំក្នុងការអនុវត្តច្បាប់នៅមានកម្រិត ។
- សេវាសង្គមកិច្ច និងផ្លូវច្បាប់សម្រាប់ជនរងគ្រោះច្រើនមាននៅតែទីប្រជុំជន និងមិនទាន់បានផ្តល់ជាលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធនៅឡើយ ហើយការផ្តល់និងការទទួលបានសេវា ក៏នៅមានកម្រិតផងដែរ។
- ស្ត្រីពិការទំនងជាងាយទទួលរងគ្រោះច្រើនជាងគេ ដោយសារអំពើហិង្សាក្នុងគ្រួសារ ដែលប្រព្រឹត្តដោយអ្នកមិនមែនជាដៃគូ បើប្រៀបធៀបជាមួយស្ត្រីដែលមិនពិការ ។ ម្យ៉ាងវិញទៀត ស្ត្រីស្រឡាញ់ស្ត្រី និងក្រុមមនុស្សប្តូរភេទទំនងជាធ្លាប់ទទួលរងគ្រោះច្រើនជាងគេ ដោយសារការរើសអើង ហើយការឆ្លើយតបនៅមានកម្រិត[23]។ មួយភាគប្រាំនៃស្ត្រីបម្រើការក្នុងរោងចក្រកាត់ដេរធ្លាប់ទទួលនូវការបៀតបៀនផ្លូវភេទនៅក្នុងនិងក្បែររោងចក្ររបស់ខ្លួន[24] ហើយ៨០%នៃស្ត្រីបម្រើការជាអ្នកផ្សព្វផ្សាយស្រាបៀរ ធ្លាប់ទទួលរងនូវការបៀតបៀនដោយប៉ះពាល់រាងកាយ។ ចំពោះក្រុមងាយរងគ្រោះផ្សេងៗទៀត ពុំទាន់មានទិន្នន័យបញ្ជាក់ពីស្ថានភាពរបស់ពួកគេនៅឡើយ[25] ។

---

22 អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ឆ្នាំ២០០៥

23 *ផែនការសកម្មភាពជាតិទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-២០១៨*

24 ដូចខាងលើ

25 ដូចខាងលើ

## ស្ត្រីក្នុងការធ្វើសេចក្ដីសម្រេច ក្នុងវិស័យសាធារណៈ និងនយោបាយ

ដើម្បីលើកកម្ពស់សមភាពយេនឌ័រ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការជាក់លាក់ជាច្រើន ក្នុងការបញ្ជ្រាបយេនឌ័រ និងបង្កើនតួនាទីស្ត្រីក្នុងការធ្វើសេចក្ដីសម្រេច រួមទាំងការបញ្ចូលទៅក្នុងច្បាប់ ក្របខណ្ឌគតិយុត្ត គោលនយោបាយ លិខិតបទដ្ឋាន និងកម្មវិធីផ្សេងៗ ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ បាននាំមកនូវការកើនឡើងជាបណ្ដើរៗនូវសមាមាត្រស្ត្រីជាអ្នកដឹកនាំ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ ឧបសគ្គនានាដែលរារាំងដល់ការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្ដីសម្រេចត្រូវបានកំណត់ និងចងក្រងដោយអ្នកពាក់ព័ន្ធ ដើម្បីស្វែងរកដំណោះស្រាយរួមគ្នា ។

ក្នុងឆ្នាំ២០១២ សមាជិកព្រឹទ្ធសភាជាស្ត្រីទទួលបានអាសនៈ១៤,៧៥%[26] ។ តំណាងស្ត្រីនៅក្នុងស្ថាប័នរដ្ឋសភាបានកើនឡើងច្រើនជាងបីដង ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ[27]។ ចំនួនស្ត្រីក្នុងមុខតំណែងជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមានការកើនឡើង ក្នុងឆ្នាំ២០១៣[28] ធៀបនឹងអាណត្តិមុនៗ ។ ចំណែកឯ សមាមាត្រស្ត្រី ក្នុងស្ថាប័នតុលាការក៏មានការកើនឡើងផងដែរ ចាប់ពីឆ្នាំ២០០៨មក[29]។ អភិបាលរងជាស្ត្រី នៃគណៈអភិបាលរាជធានី ខេត្ត កើនឡើង២០% ដែលលើសពីការរំពឹងទុកក្នុងគោលដៅទី៣ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។ ស្ត្រីជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត មានការកើនឡើងពី១០% ក្នុងឆ្នាំ២០០៩ ដល់១៣,២៣% ក្នុងឆ្នាំ២០១៤ ។ ចំណែកឯស្ត្រីជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានការកើនឡើងពី១២,២៣% ក្នុងឆ្នាំ២០០៩ ដល់១៣,៨៥% ក្នុងឆ្នាំ២០១៤ ។ អត្រាស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ កើនឡើងពី១៥,១% ក្នុងឆ្នាំ២០០៧ ដល់ ១៧,៧៨% ក្នុងឆ្នាំ២០១២[30]។

សមាមាត្រស្ត្រីជាមន្ត្រីរាជការកើនឡើងពី ៣២% ក្នុងឆ្នាំ២០០៧ ដល់៣៧% ក្នុងឆ្នាំ២០១៣[31]។ ក្រសួង ស្ថាប័នចំនួន២០ ក្នុងចំណោមក្រសួង ស្ថាប័នទាំង២៧ បានរាយការណ៍អំពីការកើនឡើងនូវចំនួនមន្ត្រីរាជការជាស្ត្រី ពី០,២៧% ក្នុងឆ្នាំ២០០៨ ដល់៧,៩% ឆ្នាំ២០១៣[32]។ នៅសាលាភូមិន្ទរដ្ឋបាល សមាមាត្រស្ត្រីដែលបានចូលរៀនមានការកើនឡើង ជាពិសេសក្នុងកម្មវិធីបណ្ដុះបណ្ដាលដំបូង[33]។ បន្ថែមពីនេះ ក៏មានព្រះរាជក្រឹត្យ ស្ដីពីការកែសម្រួលអាយុចូលនិវត្តន៍របស់មន្ត្រីរាជការជាស្ត្រី ដល់អាយុ ៦០ឆ្នាំ តាមការស្ម័គ្រចិត្ត ។

ទន្ទឹមនឹងការរីកចម្រើនគួរទឹកត់សម្គាល់ បញ្ហាប្រឈមមួយចំនួន ក៏នៅបន្តកើតមាន ដូចខាងក្រោម÷

- ចំនួនស្ត្រីដែលមានតួនាទីធ្វើសេចក្ដីសម្រេចនៅមានកម្រិត ក្នុងវិស័យនយោបាយ សាធារណៈ និងតុលាការ។
- ការរើសអើងចំពោះស្ត្រីនៅបន្តកើតមាន និងជាឧបសគ្គដល់ការទទួលបានការតែងតាំងក្នុងមុខតំណែងនានា។
- ស្ត្រីមានចំនួនច្រើននៅក្នុងការងារដែលខ្លួនធ្លាប់ធ្វើជាប្រពៃណី និងនៅក្នុងតួនាទីកម្រិតទាបតាមក្រសួងស្ថាប័ន ។

---

26 គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
27 ដូចខាងលើ
28 ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
29 តារាងស្ថិតិមន្ត្រីរាជការស៊ីវិល ឆ្នាំ២០១៣ ក្រសួងមុខងារសាធារណៈ ថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០១៤
30 គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឆ្នាំ ២០១២
31 តារាងស្ថិតិមន្ត្រីរាជការស៊ីវិល ឆ្នាំ២០១៣ ក្រសួងមុខងារសាធារណៈ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤
32 ដូចខាងលើ
33 សាលាភូមិន្ទរដ្ឋបាល ឆ្នាំ ២០១៣

- ស្ត្រីជួបប្រទះបញ្ហាប្រឈមជាច្រើនក្នុងការចូលរួមក្នុងថ្នាក់ធ្វើសេចក្តីសម្រេច ក្នុងវិស័យសាធារណៈ និងនយោបាយនៅថ្នាក់ក្រោមជាតិ ជាពិសេសការរើសអើងនៅកន្លែងធ្វើការ ។
- មិនទាន់មានវិធានការវិជ្ជមានបណ្តោះអាសន្នសមស្របនៅឡើយ ដើម្បីពន្លឿនការចូលរួមរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ និងនយោបាយ ។
- កត្តាមួយចំនួននៅក្នុងប្រព័ន្ធបោះឆ្នោតអាចជួយជំរុញឱកាសរបស់ស្ត្រី ក្នុងការចូលរួមធ្វើសេចក្តីសម្រេច ដូចជាការជ្រើសរើសបេក្ខជន ការដាក់ស្ត្រីនៅលេខរៀងលើនៃបញ្ជី និងការកំណត់កម្រិតចំនួនសម្រាប់ស្ត្រីជាដើម ។
- ការលើកកម្ពស់សមភាពយេនឌ័រ ក្នុងតួនាទីធ្វើសេចក្តីសម្រេចនៅតែជាការទទួលខុសត្រូវ ដ៏ធំធេងរបស់ស្ត្រី ទោះបីជាការងារនេះជាការទទួលខុសត្រូវរួមគ្នារវាងស្ត្រី និងបុរសក៏ដោយ ។
- ស្ត្រីភាគច្រើនស្ថិតនៅក្នុងមុខតំណែងទាបនៅក្នុងវិស័យសាធារណៈ ជាពិសេសក្នុងមុខតំណែងគ្រប់គ្រង ស្ត្រីភាគច្រើនជាអនុប្រធាន ។
- មិនទាន់មានកិច្ចសហការរវាងដៃគូពាក់ព័ន្ធ ក្នុងការរៀបចំក្របខណ្ឌ ឬកម្មវិធីរួមក្នុងការលើកកម្ពស់ការចូលរួមរបស់ស្ត្រី ក្នុងថ្នាក់ធ្វើសេចក្តីសម្រេចនៅឡើយ ។

## ការបញ្ជ្រាបយេនឌ័រ ក្នុងគោលនយោបាយ និងវិស័យពាក់ព័ន្ធ

ច្បាប់ និងគោលនយោបាយជាច្រើនបានអនុម័ត និងដាក់ចេញក្នុងការការពារសិទ្ធិរបស់ស្ត្រីមានដូចជា ក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ជាដើម។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ បានបញ្ចូលសូចនាករទាក់ទងនឹងសមភាពយេនឌ័រ និងជំរុញបន្ថែមទៀតដល់ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការបញ្ជ្រាបយេនឌ័រនៅតាមវិស័យ ។

យេនឌ័របានបញ្ជ្រាបក្នុងកម្មវិធីកំណែទម្រង់ជាតិសំខាន់ៗ ដូចជាកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងនៅក្នុងកម្មវិធីជាតិ១០ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផែនការអនុវត្ត៣ឆ្នាំដំបូង ។

ការរីកចម្រើនគួរជាទីកត់សម្គាល់ ក្នុងការពង្រឹងយន្តការក្នុងការបញ្ជ្រាបយេនឌ័រ ដែលរួមបញ្ចូលទាំងក្រុមការងារបច្ចេកទេសយេនឌ័រ ដែលជាផ្នែកមួយនៃរបស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ និងដំណើរការរបស់ក្រុមការងារយេនឌ័រតាមក្រសួង ស្ថាប័នពាក់ព័ន្ធ ។ ស្ទើរគ្រប់ក្រសួង ស្ថាប័នបានរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យ ។ នៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅថ្នាក់រាជធានី ក្រុង ស្រុក ខណ្ឌ បានបង្កើត និងកំពុងដំណើរការ ។ គណៈកម្មាធិការនេះ កំពុងដើរតួនាទី ក្នុងការផ្តល់យោបល់ និងលើកជាអនុសាសន៍ជូនដល់ក្រុមប្រឹក្សា គណៈអភិបាល អភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា លើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី និងកុមារ នៅក្នុងដែនសមត្ថកិច្ច មុខងារ និងសិទ្ធិអំណាចរបស់ខ្លួន ។

ស្របជាមួយនឹងការរីកចម្រើននានាក្នុងការបញ្ជ្រាបយេនឌ័រ ក្នុងគោលនយោបាយ កម្មវិធី និងយន្តការនានានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏បញ្ហាប្រឈមនៅបន្តមានដូចជា÷

- សមត្ថភាពរបស់ក្រសួង ស្ថាប័ន ក្នុងការវិភាគ ការស្វែងរកការគាំទ្រមតិ និងការបញ្ជ្រាបយេនឌ័រឱ្យបានស៊ីជម្រៅនៅមានកម្រិត ។
- ការអនុវត្តគោលនយោបាយ ផែនការ និងកម្មវិធីនានា នៅមិនទាន់បានពេញលេញគ្រប់ជ្រុងជ្រោយ ។
- សកម្មភាពបញ្ជ្រាបយេនឌ័រនៅពុំទាន់បានប្រមូលផ្តុំជាលក្ខណៈអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីនៅឡើយ ។
- ការសម្របសម្រួលរវាងអ្នកពាក់ព័ន្ធ ក្នុងការបញ្ជ្រាបយេនឌ័រតាមវិស័យនៅមានកម្រិត ។
- ទំនាក់ទំនងរវាងនាយកដ្ឋានជំនាញរបស់ក្រសួងកិច្ចការនារី ជាមួយនឹងក្រុមការងារយេនឌ័ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាជាមួយនឹងក្រុមការងារបច្ចេកទេសផ្សេងៗទៀតនៅមានកម្រិត ។
- ថវិកាសម្រាប់អនុវត្តការបញ្ជ្រាបយេនឌ័ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនៅមានកម្រិត ។
- គោលនយោបាយ និងកម្មវិធីយេនឌ័រតាមក្រសួង ស្ថាប័នពុំសូវមានការត្រួតពិនិត្យ តាមដាន វាយតម្លៃទៅតាមតម្រូវការបញ្ជ្រាបយេនឌ័រជាក់ស្តែង។
- នៅក្នុងគោលនយោបាយគ្រប់វិស័យ ក៏ដូចជាគោលនយោបាយ និងកម្មវិធីស្តីពីសមភាពយេនឌ័រនៅមិនទាន់បានលើកឡើងពីតម្រូវការឱ្យស៊ីជម្រៅរបស់ជនដែលងាយរងគ្រោះជាស្ត្រី និងក្មេងស្រីនៅឡើយ[34] ។

[34] ក្រុមស្ត្រីនិងក្មេងស្រីដែលងាយរងគ្រោះមានដូចជា ស្ត្រីចាស់ជរា ស្ត្រីនិងក្មេងស្រីពិការ ស្ត្រីផ្ទុកមេរោគអេដស៍ ស្ត្រីក្រីក្រ ស្ត្រីជនជាតិដើមភាគតិច ។ល។

ផ្នែកទី១

# ចក្ខុវិស័យ និងបេសកកម្ម

## ចក្ខុវិស័យ

ប្រជាពលរដ្ឋខ្មែរទាំងស្ត្រី បុរសមានសិទ្ធិស្មើគ្នា ស្របតាមច្បាប់ ជាពិសេសស្ត្រី និងក្មេងស្រីទទួលបាននូវសុវត្ថិភាពផ្ទាល់ខ្លួន ព្រមទាំងអាចចូលរួមយ៉ាងពេញលេញនៅក្នុងសកម្មភាពសង្គម ការធ្វើសេចក្តីសម្រេចសាធារណៈដោយស្មើភាពជាមួយបុរសនិងក្មេងប្រុស និងមានភាពអង់អាចផ្នែកសេដ្ឋកិច្ច ដើម្បីធានាបាននូវភាពម្ចាស់ការលើខ្លួនឯង និងសុខុមាលភាពក្នុងគ្រួសារ និងសហគមន៍។

ដើម្បីសម្រេចនូវចក្ខុវិស័យនេះ ក្រសួងកិច្ចការនារី ចាំបាច់ត្រូវឆ្លើយតបនឹងតម្រូវការរបស់ស្ត្រី និងបុរសនៅក្នុងសង្គម និងផ្តោតពង្រឹងលើការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធី និងគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល ។ ក្រសួងកិច្ចការនារី បន្តដើរតួជាអ្នករៀបចំនូវគោលនយោបាយ និងដឹកនាំការសម្របសម្រួលជាមួយក្រសួង និងស្ថាប័នដៃគូពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ រួមទាំងការសម្របសម្រួលដំណើការតាក់តែង និងរៀបចំផែនការ កម្មវិធី កៀរគរធនធាន ព្រមទាំងការអនុវត្ត និងការជំរុញឱ្យមានគំនិតផ្តួចផ្តើមនានា ។

## បេសកកម្ម

**នារីរតនៈទី៤** មានបេសកកម្មឆ្ពោះទៅរកការសម្រេចនូវសមភាពយេនឌ័រនៅក្នុងសង្គម តាមរយៈ÷

១) បញ្ជ្រាបយេនឌ័រក្នុងដំណើរការរៀបចំតាក់តែង អនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃលើគោលនយោបាយ និងកម្មវិធីថ្នាក់ជាតិ ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រតាមវិស័យពាក់ព័ន្ធ ។

២) បញ្ជ្រាបយេនឌ័រក្នុងកម្មវិធីកំណែទម្រង់នានា ដូចជាកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ រួមទាំងកម្មវិធីការប្រែប្រួលអាកាសធាតុ និងស្ត្រីជាជនក្រុមងាយរងគ្រោះ។

៣) សម្របសម្រួលក្នុងការរៀបចំ និងអនុវត្តកម្មវិធីជាក់លាក់ ដូចជាការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងស្ត្រីក្នុងវិស័យសាធារណៈជាដើម ព្រមទាំងការត្រួតពិនិត្យ ។

៤) ពង្រឹងដំណើរការបញ្ជ្រាបយេនឌ័រតាមវិស័យ និងគាំទ្រគណនេយ្យភាពសង្គមដែលឆ្លើយតបយេនឌ័រ និងកិច្ចគាំពារសង្គមក្នុងការផ្តល់សេវា ដូចជាអប់រំ សុខភាព កិច្ចការពារផ្លូវច្បាប់ និងសិទ្ធិពលរដ្ឋ ។

៥) ផ្តោតលើការពង្រឹង និងអភិវឌ្ឍសមត្ថភាពស្ថាប័នឱ្យទូលំទូលាយ ដើម្បីលើកកម្ពស់សមភាពយេនឌ័រក្នុងតាមក្រសួង ស្ថាប័ន និងកម្មវិធីរបស់រាជរដ្ឋាភិបាល ។

៦) កំណត់ក្រុមគោលដៅ ជាពិសេសតំបន់ និងក្រុមដែលពុំទាន់ទទួលបានសេវាគ្រប់គ្រាន់ដែលមានគម្លាតយេនឌ័រខ្ពស់ រួមទាំងជនពិការ ដើម្បីរៀបចំកម្មវិធីឆ្លើយតប ។

## ផ្នែកទី២

# គោលបំណង

ក្នុងគោលដៅដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ក្នុងបរិបទកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម និងអភិបាលកិច្ច **នារីរតនៈទី៤** មានគោលបំណងសំខាន់ៗ ដូចខាងក្រោម÷

- ជំរុញឱ្យមានបរិកាសអំណោយផល ដើម្បីបង្កើនលទ្ធភាពដល់ស្ត្រីក្នុងការទទួលបាននូវជំនាញ ការងារ ធនធានផលិតកម្ម កិច្ចគាំពារសង្គម សម្លេង និងការធ្វើសេចក្តីសម្រេចក្នុងវិស័យសេដ្ឋកិច្ច ។
- បង្កើនលទ្ធភាពរបស់ស្ត្រី និងកុមារីក្នុងការទទួលបានសេវាអប់រំ តាមរយៈការលើកកម្ពស់ការចូលរួម ការយល់ដឹង និងការបង្កលក្ខណៈងាយស្រួលដល់ស្ត្រី និងក្មេងស្រី ក្នុងការទទួលបានសេវា ។
- លើកកម្ពស់សមភាពយេនឌ័រក្នុងការផ្តល់ និងការទទួលបានសេវាសុខាភិបាល ស្របតាមតម្រូការ ជាក់ស្តែង ។
- ធានាសុវត្ថិភាពដល់ស្ត្រី និងក្មេងស្រីក្នុងគ្រួសារ និងសង្គម តាមរយៈការបង្កើនការយល់ដឹង និងការអនុវត្ត ផែនការសកម្មភាព និងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ ។
- ជំរុញការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត តាមរយៈការបង្កើនចំនួនមន្ត្រីរាជការ ជាស្ត្រី ការពង្រឹងសមត្ថភាព និងតម្លើងឋានៈតួនាទីនៅគ្រប់កម្រិត ។
- បង្កើនប្រសិទ្ធភាពជំនួយ និងចីរភាពនៃកិច្ចអភិវឌ្ឍ តាមរយៈការពង្រឹងសមត្ថភាពស្ថាប័ន ភាពជាម្ចាស់ និងភាពជាដៃគូ ។

ផ្នែកទី៣

# ក្របខណ្ឌយុទ្ធសាស្ត្រ

នៅក្នុងដំណើរឆ្ពោះទៅមុខ ដើម្បីសមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី **នារីរតនៈទី៤** ផ្តោតលើកម្មវិធីការពង្រឹងស្ថាប័ន និងការអភិវឌ្ឍសមត្ថភាពសម្រាប់ការឆ្ពោះទៅរកសមភាពយេនឌ័រ ជាស្នូលក្នុងការគាំទ្រដល់កម្មវិធីបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ក្នុងបរិបទកំណើនសេដ្ឋកិច្ច ការទទួលបានសេវា និងកិច្ចគាំពារសង្គម និងអន្តរវិស័យ មានវិស័យជាយុទ្ធសាស្ត្រអាទិភាព ដូចខាងក្រោម÷

**១. កំណើនសេដ្ឋកិច្ច**

១.១. ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

**២. លទ្ធភាពទទួលបានសេវាសង្គម និងកិច្ចគាំពារសង្គម**

២. ១. ការអប់រំស្ត្រី និងក្មេងស្រី និងការផ្លាស់ប្តូរឥរិយាបថ

២.២. ការលើកកម្ពស់សុខភាព អាហារូបត្ថម្ភសម្រាប់ស្ត្រីនិងកុមារី និងទប់ស្កាត់មេរោគអេដស៍ និងជំងឺអេដស៍

២.៣. កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងកុមារី

**៣. បញ្ហាអន្តរវិស័យ**

៣.១. ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេច និងការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល

៣.២. យេនឌ័រនិងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ

**៤. ការអភិវឌ្ឍស្ថាប័ន និងសមត្ថភាពសម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ**

# ១. កំណើនសេដ្ឋកិច្ច

## ១.១. ការផ្ដល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

### ការវិភាគជាយុទ្ធសាស្ត្រ

ការផ្ដល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថា ជាមូលដ្ឋានគ្រឹះដ៏សំខាន់មួយសម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ ។ តាមសវតារបស់កម្ពុជា បានបង្ហាញថា ស្ត្រីបានដើរតួនាទីដ៏សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ប៉ុន្តែពួកគេពុំទាន់ទទួលបាននូវកាលានុវត្តភាព និងផលប្រយោជន៍ពេញលេញពីវិស័យនេះនៅឡើយ ជាពិសេសពាក់ព័ន្ធនឹងលទ្ធភាពទទួលបាន និងការគ្រប់គ្រងធនធានសេដ្ឋកិច្ច កាលានុវត្តភាពសម្រាប់ការបង្កើនជំនាញ ការធ្វើសេចក្ដីសម្រេច និងការងារកម្រិតខ្ពស់ ។ នៅឆ្នាំ២០១៣ កម្ពុជាបានអនុម័តក្របខណ្ឌពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលផ្ដោតលើការផ្ដល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ។ ក្រសួងកិច្ចការនារី កំពុងបន្តរៀបចំយុទ្ធសាស្ត្រ ស្ដីពីការបង្កើនភាពអង់អាចដល់ស្ត្រី ដែលជាផែនទីបង្ហាញផ្លូវរយៈពេលវែង ក្នុងការអនុវត្តកម្មវិធីផ្ដល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ។

រាជរដ្ឋាភិបាល នីតិកាលទី៥ នឹងផ្ដោតលើបន្តការអនុវត្តគោលនយោបាយធ្វើពិពិធកម្មសេដ្ឋកិច្ចមូលដ្ឋានកំណើនសេដ្ឋកិច្ច ដោយផ្អែកលើមូលដ្ឋានភាពប្រកួតប្រជែងនៃសេដ្ឋកិច្ច និងការផ្សារភ្ជាប់សេដ្ឋកិច្ចកម្ពុជាទៅក្នុងបណ្ដាញផលិតកម្មក្នុងតំបន់ ក្នុងនោះយកចិត្តទុកដាក់ជាពិសេសដល់ការបន្តអនុវត្តគោលនយោបាយជំរុញផលិតផលស្រូវ និងការនាំចេញអង្ករ ការអនុវត្តគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្មន្តសាល និងកសិឧស្សាហកម្ម និងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍២០១១-២០២០ ព្រមទាំងការលើកកម្ពស់សហគ្រិនភាព រួមទាំងសហគ្រាសធុនតូច និងមធ្យម ។ អាទិភាពសំខាន់ៗក្នុងបរិបទនេះ គឺការលើកកម្ពស់សមធម៌យេនឌ័រនៅក្នុងការទទួលបានការងារក្នុងឧស្សាហកម្មទាំងនោះ រួមទាំងការលើកកម្ពស់សហគ្រិនភាពរបស់ស្ត្រី ។ ជាទូទៅការអប់រំ ចំណេះដឹង និងជំនាញវិជ្ជាជីវៈរបស់ស្ត្រីនៅមានកម្រិត ដែលធ្វើឱ្យស្ត្រីមានការលំបាកក្នុងការទទួលបានការងារទាំងនេះ ។

**នារីរតនៈទី៤** នឹងផ្ដោតលើការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ដោយរៀបចំអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ដែលដឹកនាំដោយក្រសួងកិច្ចការនារី ជាមួយនឹងដៃគូអភិវឌ្ឍន៍ និងក្រសួងពាក់ព័ន្ធ ដើម្បីគាំទ្រកម្មវិធីផ្ដល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី តាមរយៈក្រុមការងារបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៃក្រុមការងារបច្ចេកទេសយេនឌ័រ (TWG-G WEE) ។ កម្មវិធីនេះនឹងមានការចូលរួមពីបណ្ដាក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ រួមមានក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងពាណិជ្ជកម្ម ក្រសួងទេសចរណ៍ និងក្រសួងផ្សេងទៀត រួមទាំងវេទិកាស្ដីពីវិស័យឯកជន សភាពាណិជ្ជកម្ម និងអង្គការសង្គមស៊ីវិល ។ អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី នឹងផ្អែកលើគោលការណ៍ សកម្មភាពនិងចំណុចដៅដែលបានព្រមព្រៀងក្នុងចំណោមភាគីពាក់ព័ន្ធ ។ ភាពជោគជ័យនៃកិច្ចការនេះក៏ត្រូវពឹងផ្អែកលើកិច្ចសហការ និងកិច្ចខិតខំប្រឹងប្រែងរបស់ដៃគូពាក់ព័ន្ធ ។

ក្រសួងកិច្ចការនារី នឹងផ្ដោតលើការឈានពីរបៀបអនុវត្តការងារដែលពាក់ព័ន្ធច្រើនមានលក្ខណៈជាគម្រោង និងផ្ដល់សេវា ឱ្យទៅជាអ្នកសម្របសម្រួល ជំរុញ (កាតាលីករ) និងផ្ដល់ការគាំទ្របច្ចេកទេស រួមទាំង

អភិវឌ្ឍសមត្ថភាពលើការបញ្ជ្រាបយេនឌ័រក្នុងវិស័យសេដ្ឋកិច្ច ។ កិច្ចការនេះ គឺជាការជំរុញឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ និងភ្នាក់ងារក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច ឆ្លើយតបនឹងបញ្ហា ឬគម្លាតយេនឌ័រជាក់លាក់ក្នុងកិច្ចការរបស់ខ្លួន ដូចជាសេវាសេដ្ឋកិច្ច ធុរកិច្ចនិងហិរញ្ញវត្ថុ ។ ក្រសួងកិច្ចការនារី ក៏នឹងគាំទ្របច្ចេកទេសដល់ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការបញ្ជ្រាបយេនឌ័រ និងតាមដាននៅក្នុងកម្មវិធីរបស់ពួកគេ ជាពិសេសក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងពាណិជ្ជកម្ម ក្រសួងទេសចរណ៍ និងក្រសួងផ្សេងទៀត ។

## គោលបំណងនៃយុទ្ធសាស្ត្រ

លើកកម្ពស់ស្ថានភាពស្ត្រីក្នុងវិស័យសេដ្ឋកិច្ច តាមរយៈការអភិវឌ្ឍសហគ្រាស និងចូលរួមបង្កើនប្រាក់ចំណូល លើកកម្ពស់ជីវភាពរស់នៅ និងកិច្ចគាំពារសង្គមដល់ស្ត្រី ។

## យុទ្ធសាស្ត្រ

១. រៀបចំ និងអនុវត្តកម្មវិធី និងផែនការយុទ្ធសាស្ត្រ ស្តីពីការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ដោយស្របជាមួយនឹងក្របខណ្ឌពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។

២. បញ្ជ្រាបយេនឌ័រក្នុងការប៉ាន់ប្រមាណ អំពីតម្រូវការអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់សមាហរណកម្មអាស៊ាន រួមទាំងការឆ្លើយតបនឹងក្រុមស្ត្រីងាយរងគ្រោះ ។

៣. រៀបចំ និងអនុវត្តគំរូផ្តួចផ្តើមនៃកិច្ចសហការជាមួយវិស័យឯកជន ជាពិសេសការអភិវឌ្ឍសហគ្រាសបៃតងដែលផ្តល់ផលប្រយោជន៍ផ្នែកសង្គមកិច្ច ។

៤. លើកកម្ពស់ការតាក់តែង និងអនុវត្តគោលនយោបាយ និងកម្មវិធីជាតិ ស្តីពីការងារ ដែលមានបញ្ចូលការផ្តល់កាលានុវត្តភាពដល់ស្ត្រី ។

៥. ពង្រីកលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានផលប្រយោជន៍ពីលក្ខខណ្ឌការងារ កិច្ចគាំពារសង្គម និងបទដ្ឋានការងារឱ្យកាន់តែមានភាពប្រសើរ ។

៦. សម្របសម្រួលក្នុងការផ្តល់លទ្ធភាពដល់ស្ត្រី ដើម្បីទទួលបាននូវសេវាកម្មលើការដោះស្រាយវិវាទការងារស្មើនឹងបុរស ។

៧. សម្របសម្រួលក្នុងការផ្តល់លទ្ធភាពដល់ស្ត្រី ដើម្បីទទួលកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដែលផ្តល់ដោយស្ថាប័នសាធារណៈ វិស័យឯកជន ឬអង្គការក្រៅរដ្ឋាភិបាល ។

៨. បង្កើនការយល់ដឹង អំពីការបង្កើត និងអភិវឌ្ឍអាជីវកម្មដែលមានលក្ខណៈស្របច្បាប់ដល់ស្ត្រីជាអាជីវករ ។

៩. សម្របសម្រួល ក្នុងការផ្តល់លទ្ធភាពដល់ស្ត្រី ដើម្បីទទួលបានសេវាអភិវឌ្ឍន៍អាជីវកម្មពាក់ព័ន្ធសហគ្រាសខ្នាត មីក្រូ តូច និងមធ្យមដល់ស្ត្រីជាអាជីវករ ។

១០. អភិវឌ្ឍសមត្ថភាពក្នុងការបង្កើតបណ្តាញសហគ្រិនស្ត្រី ។

១១. អភិវឌ្ឍសមត្ថភាព និងជំនាញដល់ស្ត្រីក្នុងការគ្រប់គ្រងសង្គមគ្រួសារ និងលំនៅដ្ឋាន ដែលមានបរិស្ថានល្អប្រកបដោយចិរភាព ។

១២. ពង្រីកលទ្ធភាពដល់ស្ត្រី ក្នុងការទទួលសេវាហិរញ្ញវត្ថុដែលមានលក្ខខណ្ឌសមរម្យ ។

១៣. ពង្រីកកាលានុវត្តភាពសេដ្ឋកិច្ចដល់ស្ត្រី ក្នុងការប្រកបមុខរបរ និងវិនិយោគក្នុងការអភិវឌ្ឍជីវភាពរស់នៅ ។

១៤. លើកកម្ពស់ និងឆ្លើយតបនឹងបញ្ហារបស់ស្ត្រីពាក់ព័ន្ធនឹងការធ្វើចំណាកស្រុក នៅក្នុងដំណើរការតាក់តែង គោលនយោបាយ និងកម្មវិធីនានា ។

១៥. ពង្រីកការកាត់បន្ថយគ្រោះថ្នាក់ និងបញ្ហាផ្សេងៗ ដែលពាក់ព័ន្ធនឹងការធ្វើចំណាកស្រុករបស់ពលករស្ត្រី ។

# ២. លទ្ធភាពទទួលបានសេវាសង្គម និងកិច្ចគាំពារសង្គម

## ២.១. ការអប់រំស្ត្រី និងក្មេងស្រី និងការផ្លាស់ប្តូរឥរិយាបថ

### ការវិភាគជាយុទ្ធសាស្ត្រ

យុទ្ធសាស្ត្រស្តីពីការអប់រំស្ត្រីនិងក្មេងស្រីនឹងជួយបំពេញនិងជាបុរេលក្ខខណ្ឌចាំបាច់ដើម្បីធានាឱ្យមានភាពជោគជ័យសម្រាប់ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ។ ខណៈដែលកម្ពុជាកំពុងបោះជំហានទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យម និងឆ្ពោះទៅរកការធ្វើសមាហរណកម្មក្នុងតំបន់ កត្តានេះតម្រូវឱ្យមានការបង្កើនលទ្ធភាពក្នុងការទទួលបានការអប់រំដោយស្មើភាព ដែលមានគុណភាពខ្ពស់ និងស្របតាមតម្រូវការទីផ្សារការងារ ។ គម្លាតយេនឌ័រ ជាពិសេសក្នុងកម្រិតមធ្យមសិក្សានិងឧត្តមសិក្សា ដែលបណ្តាលមកពីកង្វះសម្ភារៈរូបវន្ត ក៏ដូចជាផ្នត់គំនិតដែលមិនទាន់ផ្តល់តម្លៃពេញលេញដល់ក្មេងស្រី និងស្ត្រី តម្រូវឱ្យមានការឆ្លើយតបឱ្យបានកាន់តែប្រសើរឡើង ។

ក្នុងនីតិកាលទី៥ នៃរដ្ឋសភា រាជរដ្ឋាភិបាល តាមរយៈក្រសួងអប់រំ យុវជន និងកីឡា នឹងបន្តជំរុញការអនុវត្តគោលការណ៍ការអប់រំសម្រាប់ទាំងអស់គ្នា សំដៅធានាសមធម៌ក្នុងការទទួលបានសេវាអប់រំ បន្តលើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំគ្រប់កម្រិត ព្រមទាំងបន្តអភិវឌ្ឍស្ថាប័ន និងសមត្ថភាពមន្ត្រីអប់រំ ។ ក្រសួងកិច្ចការនារី នឹងបន្តសហការ និងផ្តល់ជំនួយបច្ចេកទេសដល់ក្រុមការងារយេនឌ័រនៃក្រសួងអប់រំ យុវជននិងកីឡា ដើម្បីវិភាគគម្លាតយេនឌ័រ គាំទ្រ និងជំរុញឱ្យមានការកែលំអ និងត្រួតពិនិត្យដំណើរការទាំងនេះ ។ ក្រសួងកិច្ចការនារី ក៏ដើរតួទៅជាអ្នកបង្កើនគណនេយ្យភាពសង្គម និងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិទទួលបានសេវា និងកិច្ចគាំពារសង្គមដល់ស្ត្រី និងក្មេងស្រី ព្រមទាំងពិនិត្យមើលលទ្ធភាពរបស់ពួកគេលើការទទួលបានសេវាទាំងនេះផងដែរ ។

តាមរយៈកម្មវិធីលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ក្រសួងកិច្ចការនារី នឹងបន្តសម្របសម្រួលជាមួយនឹងដៃគូពាក់ព័ន្ធ ដែលជាសមាជិកនៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌ សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ក្នុងការអនុវត្តការងារតាមយុទ្ធសាស្ត្រពហុវិស័យ ក្នុងគោលបំណងអភិរក្ស និងអភិវឌ្ឍនូវវប្បធម៌អហិង្សា ផ្តល់តម្លៃដល់ស្ត្រី បណ្តុះនូវឥរិយាបថ និងអាកប្បកិរិយាវិជ្ជមានក្នុងការលើកកម្ពស់សមភាពយេនឌ័រ ដើម្បីធានាដល់ការគោរពសីលធម៌សង្គម និងសុភមង្គលនៅក្នុងគ្រួសារ និងសង្គមជាតិ ។

### គោលបំណងនៃយុទ្ធសាស្ត្រ

លើកកម្ពស់ការសម្រេចបាននូវសមភាពយេនឌ័រក្នុងវិស័យអប់រំ ជាពិសេសការបង្កើនការទទួលបាននូវសេវាអប់រំដល់ស្ត្រី និងកុមារី ក្នុងក្រុមដែលងាយរងគ្រោះ តាមរយៈវិធានការបង្កើនការយល់ដឹង គណនេយ្យភាពសង្គម អាហារូបករណ៍ និងជំនួយហិរញ្ញវត្ថុផ្សេងទៀត និងបង្កើនការចូលរួមរបស់ស្ត្រីដែលជាអ្នកផ្តល់ និងគ្រប់គ្រងសេវាអប់រំនៅគ្រប់ផ្នែកព្រមទាំងលើកកម្ពស់សីលធម៌សុខមាលភាពសង្គមអាកប្បកិរិយានិងឥរិយាបថសង្គមដែលឆ្លើយតបនឹងយេនឌ័រ ។

## យុទ្ធសាស្ត្រ

១. បង្កើនសមត្ថភាពបច្ចេកទេស និងការប្តេជ្ញាចិត្តរបស់មន្ត្រីពាក់ព័ន្ធក្នុងការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ កម្មវិធី និងផែនការពាក់ព័ន្ធនឹងវិស័យអប់រំ ។
២. ពង្រីក និងពង្រឹងកម្មវិធី និងមធ្យោបាយថែទាំកុមារតូច និងមត្តេយ្យសិក្សាសហគមន៍ ។
៣. សម្របសម្រួលការធ្វើបច្ចុប្បន្នភាព និងអនុវត្តផែនការ ស្តីពីការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រីនិងគ្រួសារខ្មែរ។
៤. រៀបចំ និងអនុវត្តកម្មវិធីរូបភាព និងខ្លឹមសារជាវិជ្ជមាន នៃស្ត្រី និងក្មេងស្រីដែលគំរូ និងភាពជាគំរូរបស់បុរស និងក្មេងប្រុសដែលគាំទ្រសមភាពយេនឌ័រ។
៥. សិក្សាស្រាវជ្រាវលើបញ្ហាថ្មីៗពាក់ព័ន្ធនឹងតម្រូវការរបស់ក្រុមស្ត្រី និងក្មេងស្រីដែលងាយរងគ្រោះ ដូចជា ស្ត្រីចាស់ជរា ស្ត្រីនិងក្មេងស្រីពិការ ផ្ទុកមេរោគអេដស៍ ក្រីក្រ និងជនជាតិដើមភាគតិច ។
៦. លើកកម្ពស់ការចូលរួម និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់សេវាអប់រំប្រកបដោយសមភាព និងគ្រប់ជ្រុងជ្រោយ ។

# ២.២. សុខភាពស្ត្រី និងក្មេងស្រី រួមទាំងមេរោគអេដស៍ និង អាហារូបត្ថម្ភ

## ការវិភាគយុទ្ធសាស្ត្រ

ក្រសួងកិច្ចការនារីទទួលស្គាល់ថា មូលហេតុចម្បងដែលបង្កឱ្យមានបញ្ហាសុខភាពដល់ស្ត្រី ភាគច្រើនគឺបណ្តាលមកពីវិសមភាពយេនឌ័រ ហើយកម្រិតនៃប្រព័ន្ធផ្តល់ព័ត៌មានសុខភាព រួមទាំងមេរោគអេដស៍និងជំងឺអេដស៍ ក៏បានបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានដល់ស្ត្រី ច្រើនជាងបុរស ។ បច្ចុប្បន្ននេះ មានការប្តេជ្ញាចិត្តរបស់ស្ថាប័ន និងដៃគូពាក់ព័ន្ធជាច្រើន ក្នុងវិស័យសុខាភិបាល ក្នុងការគិតគូរអំពីបញ្ហាយេនឌ័រក្នុងយុទ្ធសាស្ត្រលើកកម្ពស់សេវាសុខាភិបាល និងមូលនិធិសមធម៌សុខាភិបាល ដើម្បីជាប្រយោជន៍ដល់ស្ត្រី និងឆ្ពោះទៅសម្រេចសមភាពយេនឌ័រ ។

ក្នុងនីតិកាលទី៥ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសុខាភិបាល នឹងបន្តជំរុញការអនុវត្ត និងធ្វើបច្ចុប្បន្នកម្ម ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៨-២០១៥ ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាពនៃវិស័យសុខាភិបាល សំដៅលើកស្ទួយអនាម័យ សុខភាព សុខុមាលភាព និងអាហារូបត្ថម្ភរបស់ប្រជាជនឱ្យកាន់តែល្អប្រសើរឡើង ពិសេសសម្រាប់ប្រជាជនក្រីក្រ ជនងាយរងគ្រោះ ស្ត្រី និងកុមារ ។ ក្រសួងកិច្ចការនារីនឹងបន្តសហការ និងផ្តល់ជំនួយបច្ចេកទេសដល់ក្រុមការងារយេនឌ័រនៃក្រសួងសុខាភិបាល ដើម្បីវិភាគគម្លាតយេនឌ័រដែលនៅសេសសល់ គាំទ្រ និងជំរុញឱ្យមានការកែសម្រួល (ក្នុងករណីចាំបាច់) នៅក្នុងដំណើរការអនុវត្ត និងធ្វើបច្ចុប្បន្នកម្មនៃផែនការយុទ្ធសាស្ត្រនេះ ។ ក្រសួងកិច្ចការនារី ដើរតួនាទីជាអ្នកបង្កើនគណនេយ្យភាពសង្គម និងជំរុញឱ្យមានការយល់ដឹងពីសិទ្ធិទទួលបានសេវា និងកិច្ចគាំពារសង្គមដល់ស្ត្រី និងក្មេងស្រី ព្រមទាំងត្រួតពិនិត្យលទ្ធភាពរបស់ស្ត្រី និងក្មេងស្រីក្នុងការទទួលបានសេវាទាំងនោះផងដែរ ។

ក្រសួងកិច្ចការនារីនឹងបន្តចូលរួមសហការជាមួយនឹងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ជាស្ថាប័នជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ដែលមានតួនាទី ដឹកនាំ ចាត់ចែង និងសម្របសម្រួលការឆ្លើយតបនឹងជំងឺអេដស៍ ក្នុងគោលដៅដើម្បីលើកកម្ពស់សមភាពយេនឌ័រក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យ

ឆ្លើយតបនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៣ ២០១១-២០១៥ និងការរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រជាតិលើកទី៤ ២០១៦-២០២០ ។

ក្រសួងកិច្ចការនារី ក៏បន្តចូលរួមចំណែកក្នុងនាមជាសមាជិកនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្នុងការរៀបចំនិងអនុវត្តយុទ្ធសាស្ត្រជាតិ ស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ២០១៤-២០១៨ ។

## គោលបំណងនៃយុទ្ធសាស្ត្រ

លើកកម្ពស់សមភាពយេនឌ័រក្នុងការផ្តល់ និងទទួលបានសេវាសុខាភិបាល តាមរយៈការពង្រីកទទួលបានព័ត៌មាន និងសេវាថែទាំសុខភាពសមស្រប និងប្រកបដោយគុណភាព រួមមានសុខភាពបន្តពូជ សុខភាពផ្លូវភេទ សុខភាពផ្លូវចិត្ត អាហារូបត្ថម្ភ ព្រមទាំងបង្ការ និងការប្រយុទ្ធទប់ស្កាត់ជំងឺឆ្លងនានា ដូចជាជំងឺគ្រុនចាញ់ មេរោគអេដស៍ ជំងឺអេដស៍ ជំងឺកាមរោគ និងជំងឺមិនឆ្លង ដូចជាសុខភាពភ្នែក និងជំងឺមហារីកជាដើម ។

## យុទ្ធសាស្ត្រ

១. អភិវឌ្ឍសមត្ថភាពបច្ចេកទេស និងការប្តេជ្ញាចិត្តរបស់មន្ត្រី និងដៃគូពាក់ព័ន្ធ ក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ ផែនការ និងថវិកាវិស័យសុខាភិបាល ។
២. វិភាគ និងលើកកម្ពស់ការឆ្លើយតបនឹងវិសមភាពយេនឌ័រ ក្នុងវិស័យសុខាភិបាលឱ្យកាន់តែមានភាពប្រសើរ ។
៣. វិភាគ និងលើកកម្ពស់ការឆ្លើយតបនឹងគម្លាតយេនឌ័រ ក្នុងវិស័យសុខាភិបាលជាក់លាក់ និងតាមតំបន់នីមួយៗ នៅក្នុងកម្មវិធី ផែនការ និងថវិកានៅថ្នាក់ក្រោមជាតិ ។
៤. ចូលរួមចំណែកក្នុងការបង្កើនការយល់ដឹងជាសាធារណៈ អំពីសុខភាពបន្តពូជ សុខភាពផ្លូវភេទ សុខភាពផ្លូវចិត្ត អាហារូបត្ថម្ភ ព្រមទាំងបង្ការ និងប្រយុទ្ធទប់ស្កាត់ជំងឺឆ្លងនានា ដូចជាជំងឺគ្រុនចាញ់ មេរោគអេដស៍ ជំងឺអេដស៍ ជំងឺកាមរោគ និងជំងឺមិនឆ្លង ដូចជាសុខភាពភ្នែក និងជំងឺមហារីកជាដើម ។
៥. បញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ក្នុងផែនការយុទ្ធសាស្ត្រ និងកម្មវិធីជាតិពាក់ព័ន្ធនឹងសុខាភិបាល។

## ២.៣. កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី

## ការវិភាគយុទ្ធសាស្ត្រ

ទោះបីជាមានក្របខណ្ឌគតិយុត្ត និងយុទ្ធសាស្ត្រជាតិសម្រាប់ការការពារស្ត្រីពីអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ និងការជួញដូរក៏ដោយ ក៏តម្រូវឱ្យមានវិធានការសំខាន់ៗបន្ថែមទៀតនៅគ្រប់កម្រិត និងក្នុងចំណោមអ្នកពាក់ព័ន្ធទាំងឡាយ ដើម្បីអនុវត្តកិច្ចការទាំងនេះ ក្នុងគោលបំណងធានាថា ស្ត្រីនិងក្មេងស្រីមានសុវត្ថិភាព និងមិនទទួលរងនូវអំពើហិង្សាពាក់ព័ន្ធយេនឌ័រ និងការជួញដូរ ។

នារីរតនៈទី៤ នឹងផ្តោតលើការការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រី ដោយអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ដែលដឹកនាំដោយក្រសួងកិច្ចការនារី ជាមួយនឹងដៃគូអភិវឌ្ឍន៍ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីគាំទ្រការអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-២០១៨ តាមរយៈក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រនៃក្រុមការងារបច្ចេកទេសយេនឌ័រ (TWG-G GBV) ។ ក្រសួង ស្ថាប័ន និងដៃគូ

ពាក់ព័ន្ធដែលចូលរួមក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ មានដូចជាក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងយុត្តិធម៌ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងផែនការ និងក្រសួង ស្ថាប័នផ្សេងទៀត រួមទាំងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ។ អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី នឹងផ្អែកលើគោលការណ៍ សកម្មភាព និងចំណុចដៅដែលបានព្រមព្រៀងក្នុងចំណោមភាគីពាក់ព័ន្ធទាំងនេះ ។ ប្រសិទ្ធភាពនៃកិច្ចការនេះ គឺពឹងផ្អែកលើកិច្ចសហការ និងកិច្ចខិតខំប្រឹងប្រែងរបស់ដៃគូពាក់ព័ន្ធ ។

ក្រសួងកិច្ចការនារី នឹងចូលរួមរៀបចំ និងអនុវត្តផែនការសកម្មភាពជាតិប្រឆាំងនឹងអំពើជួញដូរនិងអំពើរត់ពន្ធ អំពើធ្វើអាជីវកម្មកម្លាំងពលកម្មលើមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ (NPA-FTSLS) ដែលដឹកនាំដោយក្រសួងមហាផ្ទៃ ។ ការលើកកម្ពស់សមភាពយេនឌ័រផ្សេងទៀតពាក់ព័ន្ធនឹងបញ្ហាច្បាប់ មានដូចជាការចុះអត្រានុកូលដ្ឋាន ការយល់ដឹងរបស់ស្ត្រីពីសិទ្ធិស្របច្បាប់ និងលទ្ធភាពទទួលបានយុត្តិធម៌ជាដើម ។

ក្រសួងកិច្ចការនារី មានតួនាទីជាអ្នកដឹកនាំការសម្របសម្រួល ជាកាតាលីករ និងអ្នកសហការដើម្បីលុបបំបាត់ការរើសអើងលើស្ត្រី និងដើម្បីធានាថា ស្ត្រីនឹងទទួលបានសិទ្ធិជាមូលដ្ឋាន និងកិច្ចគាំពារផ្លូវច្បាប់ដោយសមស្រប។

ដោយយេនឌ័រជាបញ្ហាអន្តរវិស័យ ក្រសួងកិច្ចការនារី មានការលំបាកជាច្រើនទាក់ទងនឹងការកំណត់ទំហំកម្មវិធី និងធនធានសម្រាប់អនុវត្តន៍ ជាពិសេសសម្រាប់ការងារដែលពាក់ព័ន្ធច្រើនជាមួយនឹងក្រសួង ស្ថាប័ន និងដៃគូនានា ។ ក្នុងបរិបទនេះ ក្រសួងកិច្ចការនារី ដើរតួនាទីជាអ្នកសម្របសម្រួល ត្រួតពិនិត្យ និងតាមដានលទ្ធផលជាទូទៅក្នុងកម្មវិធីទាំងមូល និងអនុវត្តដោយផ្ទាល់នូវការងារជាផ្នែករបស់ខ្លួន។ តួនាទីរបស់ក្រសួងស្ថាប័នពាក់ព័ន្ធដែលជាភ្នាក់ងារអនុវត្តផ្សេងទៀត គឺត្រូវធានាថាសកម្មភាពយេនឌ័រជាក់លាក់ត្រូវបានបញ្ចូលទៅក្នុងផែនការ និងកម្មវិធីជាប្រចាំ និងកៀរគរធនធានឱ្យបានគ្រប់គ្រាន់ ដើម្បីអនុវត្តសកម្មភាព នៃកម្មវិធីទាំងនោះ ។

ក្នុងនីតិកាលទី៥ នៃរដ្ឋសភា រាជរដ្ឋាភិបាល នឹងបន្តអនុវត្តឱ្យកាន់តែសកម្ម និងស៊ីជម្រៅថែមទៀតនូវបណ្តាសកម្មភាពសំខាន់ៗ ស្របតាមកម្មវិធីសកម្មភាពសម្រាប់យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ។ ក្រសួងកិច្ចការនារី នឹងបន្តចូលរួមក្នុងដំណើរការអនុវត្តសកម្មភាពសម្រាប់យុទ្ធសាស្ត្រកំណែទម្រង់នេះ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ ក្នុងដំណើរការតាក់តែងច្បាប់ បទដ្ឋានគតិយុត្ត និងគោលនយោបាយនានា និងការបង្កើនសមាសភាពស្ត្រី ក្នុងរចនាសម្ព័ន្ធតុលាការ និងប្រព័ន្ធយុត្តិធម៌ ។

## គោលបំណងយុទ្ធសាស្ត្រ

កាត់បន្ថយរាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី តាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី២០១៤-២០១៨ និងផែនការសកម្មភាពជាតិប្រឆាំងនឹងការជួញដូរមនុស្ស ២០១៤-២០១៨ ។

## យុទ្ធសាស្ត្រ

១. ពង្រឹងការបញ្ជ្រាបយេនឌ័រ ក្នុងដំណើរការរៀបចំ និងអនុវត្តច្បាប់ ក្របខណ្ឌគតិយុត្ត និងគោលនយោបាយសម្រាប់ប្រព័ន្ធយុត្តិធម៌ រួមទាំងការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងការធ្វើទេសន្តរប្រវេសន៍ការងារ

ដោយរាប់បញ្ចូលនូវក្រុមស្ត្រី និងក្មេងស្រីដែលងាយរងគ្រោះ។

២. កំណត់រកវិធានការជាក់លាក់ ក្នុងការដោះស្រាយបញ្ហាអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងភាពរើសអើងលើក្រុមស្ត្រីនិងក្មេងស្រីដែលងាយរងគ្រោះ និងការអនុវត្ត ដោយរួមសហការជាមួយនឹងដៃគូពាក់ព័ន្ធ ។

៣. សម្របសម្រួល ក្នុងការអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-២០១៨ តាមរយៈក្រុមការងារឆ្លើយតបនឹងអំពើហិង្សាទាក់ទងយេនឌ័រនៃក្រុមការងារបច្ចេកទេសយេនឌ័រ ក្នុងក្របខណ្ឌអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។

៤. រៀបចំ និងដំណើរការប្រព័ន្ធប្រមូល និងពិនិត្យតាមដានទិន្នន័យអំពើហិង្សាទាក់ទងនឹងយេនឌ័រ ។

៥. បង្កើនការយល់ដឹងជាសាធារណៈ អំពីច្បាប់ ក្របខណ្ឌគតិយុត្ត និងសេវាពាក់ព័ន្ធនឹងការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងទេសន្តរប្រវេសន៍ការងារ ។

៦. បង្កើនចំនួន និងអភិវឌ្ឍសមត្ថភាពរបស់ភ្នាក់ងារនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីជួយដល់ស្ត្រីទទួលរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ ។

៧. ពង្រឹង និងពង្រីកយន្តការឆ្លើយតបជាពហុវិស័យ ដែលមានលក្ខណៈសម្របសម្រួល ដើម្បីជួយស្ត្រីទទួលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ។

៨. រួមចំណែកអនុវត្តដោយប្រសិទ្ធភាពនូវផែនការសកម្មភាពជាតិប្រឆាំងនឹងការជួញដូរមនុស្ស ២០១៤-២០១៨ ។

៩. ចូលរួមរៀបចំ និងអនុវត្តផែនការសកម្មភាពប្រឆាំងនឹងអំពើជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គ លើកទី៣ និងផែនការសកម្មភាពប្រឆាំងនឹងអំពើជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គ លើកទី៤ ២០១៥-២០១៨ ។

## ៣. បញ្ហាអន្តរវិស័យ

នារីរតនៈទី៤ បានចាត់ទុក យុទ្ធសាស្ត្រក្នុងការលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងថ្នាក់ធ្វើសេចក្តីសម្រេច ការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងកម្មវិធីជាតិ ការគ្រប់គ្រងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងគ្រោះមហន្តរាយ រួមទាំងក្រុមស្ត្រីដែលងាយរងគ្រោះ ជាបញ្ហាអន្តរវិស័យ ដែលត្រូវយកចិត្តទុកដាក់ និងឆ្លើយតបឱ្យបានសមស្រប នៅក្នុងយុទ្ធសាស្ត្រ និងវិធានការនានា ។

### ៣.១. ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេច និងការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល

#### ការវិភាគយុទ្ធសាស្ត្រ

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា ការអភិវឌ្ឍប្រកបដោយចីរភាព និងអភិបាលកិច្ចល្អ អាស្រ័យលើការចូលរួមរបស់ស្ត្រីឱ្យបានសមស្របនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត។ នៅកម្ពុជា ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងការធ្វើសេចក្តីសម្រេចនៅមានកម្រិតនៅឡើយ ទាំងបរិមាណនិងគុណភាព ដោយសារវិសមភាពយេនឌ័រនៅក្នុងវិស័យនេះបានចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គម ។

ក្នុងនីតិកាលទី៥នៃរដ្ឋសភា រាជរដ្ឋាភិបាលផ្តោតអាទិភាពលើការបន្តលើកកម្ពស់តួនាទីស្ត្រី ក្នុងវិស័យសាធារណៈ តាមរយៈការបង្កើនសមាមាត្រ និងការពង្រឹងសមត្ថភាពស្ត្រី នៅក្នុងជួរថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ទាំងកម្រិតនយោបាយ ទាំងកម្រិតជំនាញ ។

អាទិភាពទាំងនេះអាចសម្រេចបាន តាមរយៈការចូលរួមដោយសកម្ម និងជាយុទ្ធសាស្ត្រក្នុងដំណើរការនៃកម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ គណៈកម្មាធិការរៀបចំការបោះឆ្នោត គណបក្សនយោបាយ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

ការគាំទ្រផ្នែកនយោបាយ និងការស្វែងរកការគាំទ្រមតិកម្រិតខ្ពស់របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ជាមធ្យោបាយក្នុងការជំរុញរបៀបវារៈនេះឱ្យមានដំណើរការកាន់តែមានប្រសិទ្ធភាព ។ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ជាសក្តានុពលក្នុងការបង្កើតឱ្យមាន និងការតាមដានការអនុវត្តប្រព័ន្ធវិធានការពិសេសនានាសម្រាប់ស្ត្រីក្នុងវិស័យមុខងារសាធារណៈ ។ ក្រសួងកិច្ចការនារី និងក្រសួងមុខងារសាធារណៈ សហការក្នុងការសម្របសម្រួល ក្នុងការធ្វើបច្ចុប្បន្នកម្មទិន្នន័យ ស្តីពីស្ត្រីនៅគ្រប់កម្រិតក្នុងមុខងារសាធារណៈ និងត្រួតពិនិត្យការប្រែប្រួល ព្រមទាំងការបញ្ជ្រាបយេនឌ័រ ក្នុងការអនុវត្តកម្មវិធីជាតិ ស្តីពីកំណែទម្រង់រដ្ឋបាលសាធារណៈ។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងក្រសួងកិច្ចការនារី ជាអ្នកស្វែងរកការគាំទ្រមតិជាមួយនឹងដៃគូពាក់ព័ន្ធ រួមទាំងគណបក្សនយោបាយ ក្នុងការបង្កើតវិធានការពិសេសនានា និងការជំរុញឱ្យមានការប្តេជ្ញាចិត្ត ក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងច្បាប់និងលិខិតបទដ្ឋានរបស់គណបក្សនយោបាយជាពិសេសដើម្បីបង្កើនសមាសភាពស្ត្រីក្នុងបញ្ជីឈ្មោះបេក្ខជនរបស់គណបក្សនយោបាយ ។

ក្រសួងកិច្ចការនារី បន្ថែមលើមុខងារក្នុងការគាំទ្រផ្នែកគោលនយោបាយ ដោយការអនុវត្តវិធានការគាំទ្រក្នុងការបង្កើនទាំងបរិមាណ និងគុណភាព តាមរយៈការសម្របសម្រួលក្នុងការរៀបចំ និងអនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាពក្នុងការដឹកនាំ និងគ្រប់គ្រងសម្រាប់បេក្ខនារី ថ្នាក់ដឹកនាំជាស្ត្រី ព្រមទាំងមន្ត្រីរាជការជាស្ត្រី និងពង្រីកលទ្ធភាពរបស់ស្ត្រី ក្នុងការទទួលបានការអប់រំថ្នាក់ឧត្តមសិក្សា ។ ជាមួយគ្នានេះ ក្រសួងកិច្ចការនារី និងក្រសួងមុខងារសាធារណៈ នឹងចូលរួមធានាថាស្ត្រីបានចូលរួមដោយស្មើភាព ក្នុងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការ តាមរយៈការចូលរួមក្នុងការរៀបចំនិងអនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាពយ៉ាងទូលំទូលាយសម្រាប់មន្ត្រីរាជការ ។

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩ គឺជាក្របខណ្ឌដ៏សំខាន់សម្រាប់ការបង្កើនការចូលរួមរបស់ស្ត្រី ក្នុងថ្នាក់ធ្វើសេចក្តីសម្រេចនៅថ្នាក់ក្រោមជាតិ និងការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ ។ ការអនុវត្តកម្មវិធីជាតិនេះ មានសក្តានុពលក្នុងការបង្កើនភាពជាអ្នកដឹកនាំ និងការធ្វើសេចក្តីសម្រេចរបស់ស្ត្រី ទាំងបរិមាណ និងគុណភាព ក្នុងនៅថ្នាក់ក្រោមជាតិ តាមរយៈការគាំទ្របច្ចេកទេស ការអភិវឌ្ឍសមត្ថភាព និងការពង្រីកបណ្តាញទំនាក់ទំនងក្នុងចំណោមអ្នកដឹកនាំជាស្ត្រីនៅថ្នាក់ក្រោមជាតិ ។ ក្រសួងកិច្ចការនារី ក្នុងនាមជាសមាជិករបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) នឹងបន្តការលើកកម្ពស់សមភាពយេនឌ័រ តាមរយៈកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ នៃកម្មវិធីជាតិ និងនៅក្នុងដំណើរការអភិបាលកិច្ចនៅថ្នាក់មូលដ្ឋាន ។

តាមរយៈការបន្តជំរុញការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលនីតិកាលទី៥ មានគោលដៅលើកកម្ពស់ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្ពុជាឱ្យស្របតាមបទដ្ឋានអន្តរជាតិ[35]។ ក្រសួងកិច្ចការនារី និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងបន្តជំរុញឱ្យមានការបែងចែងថវិកាជាតិដែលយកចិត្តទុកដាក់សមភាពយេនឌ័រ តាមរយៈសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ឱ្យពិចារណា និងឆ្លើយតបនឹងតម្រូវការធនធានសម្រាប់ការបញ្ជ្រាបយេនឌ័រទៅក្នុងកម្មវិធីរបស់ខ្លួន និងធានាថាធនធានទាំងនេះត្រូវបានស្នើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នៅក្នុងដំណាក់កាលទីពីរ នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងកិច្ចការនារី និងក្រុមការងារបញ្ជ្រាបយេនឌ័រនៃក្រសួងស្ថាប័នពាក់ព័ន្ធ នឹងធ្វើការត្រួតពិនិត្យដើម្បីធានាថាវិធានការសមភាពយេនឌ័រត្រូវបានបញ្ចូលទៅក្នុងផែនការសកម្ម និងថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ។

## គោលបំណងនៃយុទ្ធសាស្ត្រ

លើកកម្ពស់សមភាពយេនឌ័រ ក្នុងថ្នាក់ធ្វើសេចក្តីសម្រេចគ្រប់កម្រិត និងការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ ផែនការ និងកម្មវិធីតាមវិស័យ រួមទាំងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល ។

## យុទ្ធសាស្ត្រ

១. បង្កើនសមាមាត្រ នៃការចូលរួមរបស់ស្ត្រី ក្នុងវិស័យសាធារណៈ។

២. អភិវឌ្ឍសមត្ថភាព និងពង្រីកលទ្ធភាពបំពេញភារកិច្ចរបស់ស្ត្រីនៅក្នុងមុខងារសាធារណៈ និងថ្នាក់ធ្វើសេចក្តីសម្រេច ។

៣. បង្កើនសមាមាត្រ នៃការចូលរួមរបស់ស្ត្រីក្នុងតួនាទីនយោបាយ ។

៤. រៀបចំ និងផ្សព្វផ្សាយការប៉ាន់ប្រមាណស្ថានភាពយេនឌ័រនៅកម្ពុជា និងប្រព័ន្ធស្ថិតិជាតិសំខាន់ៗដែលឆ្លើយតបនឹងយេនឌ័រ ។

៥. លើកកម្ពស់ការឆ្លើយតបនឹងយេនឌ័រ នៅក្នុងផែនការយុទ្ធសាស្ត្រជាតិ និងតាមវិស័យ ។

៦. លើកកម្ពស់ការរៀបចំ និងអនុវត្តផែនការអនុវត្តន៍ នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩ ដែលមានការឆ្លើយតបនឹងយេនឌ័រ ។

៧. ចូលរួមរៀបចំ និងអនុវត្តគោលនយោបាយ ផែនការ កម្មវិធី និងលិខិតបទដ្ឋានដែលទាក់ទងនឹងកំណែទម្រង់រដ្ឋបាលសាធារណៈ ឱ្យឆ្លើយតបនឹងយេនឌ័រ ។

៨. សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការធានាការទទួលបានថវិកាសម្រាប់បញ្ជ្រាបយេនឌ័រតាមរយៈកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

៩. បញ្ជ្រាបយេនឌ័រក្នុងកម្មវិធីកំណែទម្រង់ដីធ្លី និងជំរុញឱ្យស្ត្រីទទួលបាននូវសិទ្ធិស្មើភាពក្នុងការទទួល និងគ្រប់គ្រងដីធ្លីឱ្យកាន់តែប្រសើរឡើង ។

# ៣.២. យេនឌ័រ និងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ

## ការវិភាគយុទ្ធសាស្ត្រ

កម្មវិធីទាក់ទងនឹងបម្រែបម្រួលអាកាសធាតុ ជារបៀបវារៈថ្មីសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ដែលកន្លងមកពុំទាន់មានបទពិសោធន៍ក្នុងការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីនេះ ។ គណៈកម្មាធិការជាតិបម្រែបម្រួលអាកាសធាតុ ដែល

[35] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨

ក្រសួងកិច្ចការនារី ជាសមាជិក នឹងចូលរួមដើម្បីស្វែងយល់ឱ្យកាន់តែស៊ីជម្រៅអំពីរបៀបវារៈ ស្តីពីបម្រែបម្រួលអាកាសធាតុ និងប្រព័ន្ធការងាររបស់គណៈកម្មាធិការនេះ រួមទាំងដំណើរការបង្កើតដោះស្រាយផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ និងរបៀបកាត់បន្ថយផលប៉ះពាល់ទាំងនោះ ។

ក្រសួងបរិស្ថាន គណៈកម្មាធិការជាតិបម្រែបម្រួលអាកាសធាតុ និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង បានរៀបចំផែនការយុទ្ធសាស្ត្រជាតិបម្រែបម្រួលអាកាសធាតុ២០១៤-២០២៨គោលនយោបាយជាតិស្តីពីអភិវឌ្ឍន៍បៃតង និងផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍបៃតង ២០១៣-២០៣០ ។ ក្នុងដំណើរការអនុវត្តន៍នូវក្របខណ្ឌគោលនយោបាយទាំងនេះ គួរបញ្ចូលការយកចិត្តទុកដាក់បន្ថែមទៀតនូវយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ។ ក្រសួងកិច្ចការនារី បន្តសហការជាមួយនឹងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិបម្រែបម្រួលអាកាសធាតុ ក្នុងការជំរុញលើការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ក្នុងបរិបទទាំងនេះ រួមទាំងក្នុងការងាររបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ។

ក្រសួងកិច្ចការនារីបានបង្កើត នៃការយុទ្ធសាស្ត្រស្តីពីបម្រែបម្រួលអាកាសធាតុនិងយេនឌ័រ ដែលជាការរួមចំណែកដល់ការបង្កើត និងអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងការឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ ។ យុទ្ធសាស្ត្រនេះពុំមែនជាយុទ្ធសាស្ត្រមួយដោយឡែកនោះទេ ប៉ុន្តែជាបញ្ហាអន្តរវិស័យ យេនឌ័រត្រូវដាក់បញ្ចូលទៅក្នុងដំណើរការអនុវត្តន៍ផែនការយុទ្ធសាស្ត្រជាតិបម្រែបម្រួលអាកាសធាតុ និងផែនការយុទ្ធសាស្ត្រស្តីពីបម្រែបម្រួលអាកាសធាតុរបស់វិស័យនានា និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

ក្រសួងកិច្ចការនារី នឹងបន្តចូលរួមយ៉ាងសកម្មនៅក្នុងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងការអនុវត្ត នូវផែនការសកម្មភាព និងយុទ្ធសាស្ត្រជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៤-២០១៨ ។

## គោលបំណងយុទ្ធសាស្ត្រ

លើកកម្ពស់សមភាពយេនឌ័រក្នុងដំណើរការតាក់តែង និងអនុវត្តន៍គោលនយោបាយ និងកម្មវិធីជាតិពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងគ្រប់គ្រងគ្រោះមហន្តរាយរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងក្រោមជាតិ ជាពិសេសក្នុងការកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមានមកលើស្ត្រី និងជនដែលងាយរងគ្រោះ ព្រមទាំងចូលរួមចំណែកក្នុងដំណើរការអភិវឌ្ឍន៍បៃតង ។

## យុទ្ធសាស្ត្រ

១. បង្កើនសមត្ថភាពបច្ចេកទេស និងការគាំទ្រពីថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធ ស្តីពីយេនឌ័រ និងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ ។

២. បញ្ជ្រាបយេនឌ័រ ក្នុងដំណើរការតាក់តែង និងអនុវត្តន៍គោលនយោបាយ កម្មវិធី និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយមានភាពប្រសើរឡើង ។

៣. លើកកម្ពស់ការចូលរួមដោយស្មើភាពរបស់ស្ត្រីក្រុមស្ត្រីក្មេងស្រីងាយរងគ្រោះក្នុងដំណើរការសម្របសម្រួល និងស្វែងរកការគាំទ្រមតិ ស្តីពីបម្រែបម្រួលអាកាសធាតុនៅថ្នាក់អន្តរជាតិ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីផលប្រយោជន៍ដល់ស្ត្រី ។

៤. កាត់បន្ថយផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ និងគ្រោះមហន្តរាយនានាមកលើស្ត្រី និងក្រុមស្ត្រីក្មេងស្រីដែលងាយរងគ្រោះ ។
៥. បង្កើនការចូលរួមរបស់ស្ត្រី ក្នុងកម្មវិធី និងសកម្មភាពអភិវឌ្ឍន៍បៃតង ។
៦. ផ្តួចផ្តើមគំនិត និងសកម្មភាពថ្មីៗដែលឆ្លើយតបនឹងយេនឌ័រ ក្នុងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ ដោយសាកល្បង និងទទួលយកពីក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការដាក់បញ្ចូលទៅក្នុងកម្មវិធីដែលកំពុងដំណើរការ ។

## ៤. ការពង្រឹងស្ថាប័ន និងការអភិវឌ្ឍសមត្ថភាព ដើម្បីឆ្ពោះទៅសមភាពយេនឌ័រ

### ការវិភាគយុទ្ធសាស្ត្រ

អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី គឺជាឧបករណ៍មួយដែលរាជរដ្ឋាភិបាលបានជ្រើសរើសសម្រាប់ប្រើប្រាស់ក្នុងការអនុវត្តយុទ្ធសាស្ត្រតាមវិស័យ និងកម្មវិធីកំណែទម្រង់នានា ។ អភិក្រមនេះត្រូវបានចាត់ទុកជាយន្តការមួយក្នុងការលើកកម្ពស់ភាពម្ចាស់ការរបស់រាជរដ្ឋាភិបាល ក្នុងកម្មវិធីអភិវឌ្ឍន៍ និងជាយន្តការផ្តល់ការនៃប្រសិទ្ធភាពជំនួយ នៅកម្ពុជា ដើម្បីធានាឱ្យមានការបង្កើតកម្មវិធីដែលមានភាពស៊ីសង្វាក់គ្នា និងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ការអភិវឌ្ឍសមត្ថភាព និងការពង្រឹងប្រព័ន្ធជាតិ ហើយសំខាន់បំផុត គឺដើម្បីទទួលបានលទ្ធផលនៃការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ ។ កិច្ចប្រជុំលើកទីបីនៃវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា កាលពីខែមិថុនា ឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ បានអនុម័តទទួលយកអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ព្រមទាំងបានឯកភាពគ្នាក្នុងការបង្កើនឱ្យបានជាអតិបរមានូវលទ្ធផល នៃការប្រើប្រាស់ធនធានក្នុងប្រទេស និងជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេស។ អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី គឺជាក្របខណ្ឌគោលនយោបាយដ៏ទូលំទូលាយមួយដែលរាជរដ្ឋាភិបាល ជាអ្នកដឹកនាំ និងសម្របសម្រួលជាមួយដៃគូពាក់ព័ន្ធ។ ក្របខណ្ឌគោលនយោបាយនេះ មានជាអាទិ៍កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងគម្រោងទ្រទ្រង់វិស័យសុខាភិបាល ដំណាក់កាលទី២ ជាដើម ។

យេនឌ័រត្រូវបានកំណត់ថាជាប្រធានបទសំខាន់មួយ ក្នុងចំណោមប្រធានបទសំខាន់នានា ដែលត្រូវអនុវត្តតាមអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី នៅកម្ពុជា និងជាសសរស្តម្ភមួយក្នុងចំណោមសសរស្តម្ភអន្តរវិស័យទាំងបីនៃកិច្ចអភិវឌ្ឍជាតិ ។ ក្នុងឆ្នាំ២០១២ ក្រសួងកិច្ចការនារីបានបង្កើតគណៈកម្មាធិការនិងលេខាធិការដ្ឋានអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ដើម្បីគាំទ្រដល់ថ្នាក់ដឹកនាំ និងក្រុមបច្ចេកទេសនានា ក្នុងក្រសួងកិច្ចការនារី ក្នុងចាប់ផ្តើម និងដំណើរការអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ដើម្បីឆ្ពោះទៅសមភាពយេនឌ័រ ។ បច្ចុប្បន្ន ក្រសួងកិច្ចការនារីកំពុងប្រើប្រាស់អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី វិស័យពីរ គឺការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី។ អភិក្រមគ្រប់គ្រងទូទាំងតាមកម្មវិធី ដើម្បីឆ្ពោះទៅសមភាពយេនឌ័រ ទាមទារឱ្យក្រសួងកិច្ចការនារីដឹកនាំ ទាំងផ្នែកបច្ចេកទេស និងផ្នែកនយោបាយ ក្នុងការសម្របសម្រួលវិភាគ និងស្វែងរកការគាំទ្រមតិ ព្រមទាំងធានាថាយេនឌ័រត្រូវបានបញ្ជ្រាបក្នុងគ្រប់ដំណើរការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល។ នេះមានន័យថាក្រសួងកិច្ចការនារី នឹងកាត់បន្ថយជាបណ្តើរៗនូវការអនុវត្ត គម្រោងតូចៗជាលក្ខណៈផ្តល់សេវានិងបង្កើនការយល់ដឹងនៅកម្រិតសហគមន៍ លើកលែងតែសកម្មភាពថ្មីៗសំដៅសាកល្បង និងដក

ពិសោធន៍ ក៏ដូចជាការស្រាវជ្រាវបញ្ហាដែលកើតទើបលេចឡើងថ្មីៗ។ ជារួមក្រសួងកិច្ចការនារីនឹងតម្រង់ទិសឆ្ពោះទៅរកការបញ្ជ្រាបយេនឌ័រដែលកាន់តែទូលំទូលាយ ពោលគឺការសិក្សាស្រាវជ្រាវ ការបង្កើតគោលនយោបាយ ការត្រួតពិនិត្យ និងការវាយតម្លៃ ការសម្របសម្រួល និងការអភិវឌ្ឍសមត្ថភាព ។ ដូច្នេះកិច្ចការនេះទាមទារឱ្យមានការពង្រឹងសមត្ថភាពបច្ចុប្បន្នរបស់ក្រសួងកិច្ចការនារីសម្រាប់ការបញ្ជ្រាបយេនឌ័រតាមវិស័យ ការសម្របសម្រួល និងការដើរតួនាទីជាអ្នកគាំទ្រដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ។ ភាពរឹងមាំរបស់ក្រសួងកិច្ចការនារី នឹងផ្តល់ដល់ដៃគូពាក់ព័ន្ធនូវសមត្ថភាព ក្នុងការបញ្ជ្រាបយេនឌ័រ និងវិភាគបញ្ហាយេនឌ័រតាមវិស័យនានា ព្រមទាំងជួយដល់ក្រសួងស្ថាប័ននិងដៃគូអភិវឌ្ឍន៍ ក្នុងការផ្តួចផ្តើម និងអនុវត្តសកម្មភាពនានា ក្នុងវិស័យ និងអង្គភាពរបស់ខ្លួន ។

គណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ របស់អង្គការសហប្រជាជាតិក៏បានស្នើឱ្យមានការវាយតម្លៃ ដើម្បីត្រួតពិនិត្យយន្តការជាតិសម្រាប់ការលើកកម្ពស់ស្ត្រី និងស្ថាប័នពាក់ព័ន្ធដែលមានដូចជាក្រុមការងារបច្ចេកទេសយេនឌ័រ និងក្រុមការងារយេនឌ័រតាមក្រសួងពាក់ព័ន្ធ និងទំនាក់ទំនងនៃយន្តការទាំងនេះជាមួយអង្គភាពសំខាន់ៗផ្សេងទៀត ដូចជាក្រុមការងារបច្ចេកទេសផ្សេងៗទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រុមប្រឹក្សាអភិវឌ្ឍន៍ជាតិជាដើម និងដើម្បីផ្តល់អនុសាសន៍សម្រាប់ការកែលម្អ ។

ការវាយតម្លៃសមត្ថភាពរបស់ក្រសួងកិច្ចការនារីត្រូវបានធ្វើឡើង ក្នុងឆ្នាំ២០១០ ប៉ុន្តែសម្រាប់តែមន្ត្រីក្រសួងកិច្ចការនារីនៅកម្រិតកណ្តាលប៉ុណ្ណោះ បានបង្ហាញថាសកម្មភាពចម្បងសម្រាប់ឆ្នាំខាងមុខ គឺការស្វែងរកការគាំទ្រមតិជាមួយក្រសួងស្ថាប័នពាក់ព័ន្ធឱ្យមានវិធានការដែលឆ្លើយតបនឹងយេនឌ័រ (ក្រសួងពាក់ព័ន្ធសំខាន់ៗ និងលេខាធិការដ្ឋាននៃក្រុមប្រឹក្សា និងគណៈកម្មាធិការជាតិអន្តរក្រសួងនានា) ព្រមទាំងថ្នាក់ក្រោមជាតិ នៅពេលដែលមុខងារ និងធនធានហិរញ្ញវត្ថុត្រូវបានផ្ទេរ ។ ការបង្កើនការយកចិត្តទុកដាក់ក្នុងការវាយតម្លៃតម្រូវការនៃការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រី នៃមន្ទីរកិច្ចការនារីខេត្ត ការិយាល័យកិច្ចការនារីក្រុង ស្រុក ខណ្ឌ និងបណ្តាញថ្នាក់ឃុំសង្កាត់ ក៏មានសារៈសំខាន់ផងដែរ។

យុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពត្រូវបានបង្កើតឡើង ដោយមានការយកចិត្តទុកដាក់ជាពិសេសលើការពង្រឹងសមត្ថភាពមន្ត្រីរបស់ក្រសួងកិច្ចការនារី ដើម្បីបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យសំខាន់ៗ រួមទាំងការពង្រឹងសមត្ថភាពនាយកដ្ឋាន បច្ចេកទេសដើម្បីគាំទ្រ និងត្រួតពិនិត្យដំណើរការបញ្ជ្រាបយេនឌ័រ ការអភិវឌ្ឍសមត្ថភាពសម្រាប់ការផ្លាស់ប្តូរពីគម្រោងមួយទៅជាអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីមួយ និងការពង្រឹងសមត្ថភាពមន្ត្រីមន្ទីរកិច្ចការនារីខេត្ត និងការិយាល័យកិច្ចការនារីក្រុង ស្រុក ខណ្ឌ ដើម្បីចូលរួម និងគាំទ្រដំណើរការធ្វើផែនការ ការវិភាជន៍ថវិកា ការត្រួតពិនិត្យ និងគណនេយ្យភាពសង្គម ធ្វើយ៉ាងណាឱ្យការងារទាំងនេះឆ្លើយតបនឹងយេនឌ័រ និងមានប្រសិទ្ធភាព ។

កម្មវិធីស្នូលនេះនឹងដំណើរការជាលំដាប់លំដោយ ហើយផ្តល់ការអភិវឌ្ឍសមត្ថភាពដល់អ្នកពាក់ព័ន្ធសំខាន់ៗ ទាំងក្នុង និងក្រៅក្រសួងកិច្ចការនារី ទៅតាមមុខងារ និងតួនាទីក្នុងដំណើរការបញ្ជ្រាបយេនឌ័រ ។

## គោលបំណងយុទ្ធសាស្ត្រ

ពង្រឹងរចនាសម្ព័ន្ធស្ថាប័ន និងសមត្ថភាពសម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ តាមរយៈការអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងចូលរួមអនុវត្តគោលនយោបាយពង្រឹងអភិបាលកិច្ចល្អ ដែលរួមបញ្ចូលក្រុមស្ត្រី និងក្មេងស្រីងាយរងគ្រោះ ។

## យុទ្ធសាស្ត្រ

១. សិក្សាឡើងវិញនូវមុខងាររបស់ស្ថាប័ន និងយន្តការជាតិ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ ។

២. កែសម្រួលឱ្យកាន់តែប្រសើរឡើងនូវរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ស្ថាប័ន និងយន្តការជាតិក្នុងការលើកកម្ពស់សមភាពយេនឌ័រ ។

៣. ប៉ាន់ប្រមាណតម្រូវការអភិវឌ្ឍន៍សមត្ថភាពរបស់អង្គភាពនីមួយៗ (ដែលស្របតាមរចនាសម្ព័ន្ធ និងបណ្តាញការងារលើកកម្ពស់សមភាពយេនឌ័រ ដែលបានកែសម្រួល)។

៤. រៀបចំឯកសារសម្រាប់បណ្តុះបណ្តាល ក្នុងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពយន្តការ និងស្ថាប័នក្នុងការលើកកម្ពស់សមភាពយេនឌ័រ។

៥. អភិវឌ្ឍសមត្ថភាពរបស់ក្រសួងកិច្ចការនារី ក្នុងការប៉ាន់ប្រមាណ និងអភិវឌ្ឍសមត្ថភាពរបស់ក្រសួងស្ថាប័នក្នុងការលើកកម្ពស់សមភាពយេនឌ័រតាមវិស័យ ។

៦. អភិវឌ្ឍសមត្ថភាពក្រសួងកិច្ចការនារី ក្នុងការរៀបចំផែនការ តាមដាន វាយតម្លៃ និងផ្តល់អនុសាសន៍ទាក់ទងនឹងយេនឌ័រក្នុងគោលនយោបាយ ផែនការ និងកម្មវិធី ។

៧. ពង្រឹងសមត្ថភាពក្រុមការងារយេនឌ័រនៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការបញ្ចូលយេនឌ័រក្នុងគោលនយោបាយ ផែនការ និងថវិកាតាមវិស័យ ។

៨. អភិវឌ្ឍសមត្ថភាពក្រុមការងារយេនឌ័រនៅតាមមន្ទីរ ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ក្នុងការបញ្ចូលយេនឌ័រក្នុងគោលនយោបាយ ផែនការ និងថវិកាតាមវិស័យនៅថ្នាក់ក្រោមជាតិ។

៩. ពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ ដែលស៊ីចង្វាក់ជាមួយនឹងក្រុមប្រឹក្សាកម្ពុជាដើម្បីស្ត្រី ក្នុងការជំរុញការអនុវត្តច្បាប់ជាតិ គោលនយោបាយ និងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី ។

១០. រៀបចំ និងអនុវត្តអភិក្រមតាមកម្មវិធី ដើម្បីឆ្ពោះទៅសម្រេចសមភាពយេនឌ័រ ។

១១. បញ្ជ្រាបយេនឌ័រនៅក្នុងគ្រប់ក្រុមការងារបច្ចេកទេសតាមវិស័យពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ។

១២. ពង្រឹង និងពង្រីកប្រព័ន្ធនៃការផ្សព្វផ្សាយព័ត៌មាន ទំនាក់ទំនង និងរបាយការណ៍របស់ក្រសួងកិច្ចការនារី និងអ្នកពាក់ព័ន្ធ ក្នុងក្របខណ្ឌនារីរតនៈទី៤ និងអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីដើម្បីឆ្ពោះទៅសមភាពយេនឌ័រប្រកបដោយគុណភាព រួមទាំងនៅថ្នាក់ជាតិ និងក្រោមជាតិ។

១៣. រៀបចំអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ស្របតាមគោលការណ៍ណែនាំនៃកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ។

១៤. ពង្រឹងយន្តការ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងវាយតម្លៃលើវឌ្ឍនភាព និងដំណើរការយន្តការ ក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ។

ផ្នែកទី៤

# ផែនការសកម្មភាព

## ១. កំណើនសេដ្ឋកិច្ច

### ១.១.ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

គោលបំណង÷ លើកកម្ពស់ស្ថានភាពស្ត្រី ក្នុងវិស័យសេដ្ឋកិច្ច តាមរយៈការអភិវឌ្ឍសហគ្រាស និងពង្រីកកាលានុវត្តភាពការងារដើម្បីឈានទៅបង្កើនប្រាក់ចំណូល ការលើកកម្ពស់ជីវភាពរស់នៅ និងកិច្ចគាំពារសង្គម ។

| យុទ្ធសាស្ត្រ | សូចនាករ | សកម្មភាពគន្លឹះ | ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលវេលា | | | | | ធនធាន | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | 14 | 15 | 16 | 17 | 18 | ជាតិ | ដៃគូ |
| គោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធី ស្តីពីការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី បានរៀបចំ និងអនុវត្តជាមួយនឹងដៃគូពាក់ព័ន្ធ | | | | | | | | | | |
| ១. រៀបចំ និងអនុវត្តកម្មវិធី និងផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ដោយស្របជាមួយនឹងក្របខណ្ឌពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ | ផែនការនារីរតនៈទី៤ និងផែនការយុទ្ធសាស្ត្រ ស្តីពីការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីបានរៀបចំ និងផ្សព្វផ្សាយ | សម្របសម្រួលរៀបចំផែនការយុទ្ធសាស្ត្រ ស្តីពីការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ដោយដាក់បញ្ចូលអនុសាសន៍នៃការប៉ាន់ប្រមាណស្ថានភាពយេនឌ័រនៅកម្ពុជា | ក្រសួងកិច្ចការនារី<br>TWG-G WEE[36]<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ | × | × | | | | × | × |
| | មានប្រព័ន្ធតាមដាន និងវាយតម្លៃកម្មវិធីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី | រៀបចំ និងអនុវត្តប្រព័ន្ធតាមដាន និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ ស្តីពីការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី | ក្រសួងកិច្ចការនារី<br>TWG-G WEE<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ | × | × | × | × | × | × | × |
| | យន្តការបញ្ជ្រាបយេនឌ័រ នៃក្រសួងស្ថាប័នពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច (ក្រុមការងារបញ្ជ្រាបយេនឌ័រ) មានដំណើរការ | អភិវឌ្ឍសមត្ថភាពក្រសួងកិច្ចការនារី និងស្ថាប័នពាក់ព័ន្ធ ស្តីពីការវិភាគ និងបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធី និងគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច | ក្រសួងកិច្ចការនារី<br>TWG-G WEE<br>ក្រសួងពាក់ព័ន្ធ | × | × | × | × | × | × | × |

[36] ក្រុមការងារបច្ចេកទេសយេនឌ័រក្នុងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ពង្រឹងភាពជាដៃគូ ក្នុងការរៀបចំគោលនយោបាយ និងកម្មវិធីនានា ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ច | ក្រសួងកិច្ចការនារី ដៃគូពាក់ព័ន្ធ | × | × | × | × | × | × | × |
| | ការអនុវត្តក្របខណ្ឌពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍បានតាមដាន និងស្របជាមួយផែនការយុទ្ធសាស្ត្រ បង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី | សម្របសម្រួលការអនុវត្ត និងតាមដានក្របខណ្ឌពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ តាមរយៈ TWG-G WEE | TWG-G WEE | × | × | | | | × | × |
| ២.បញ្ជ្រាបយេនឌ័រក្នុងការប៉ាន់ប្រមាណ អំពីតម្រូវការអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់សមាហរណកម្មអាស៊ានរួមទាំងការឆ្លើយតបនឹងក្រុមស្ត្រីងាយរងគ្រោះ | លទ្ធផលសិក្សាអំពីផលប៉ះពាល់ នៃសមាហរណកម្មអាស៊ានបានចងក្រង និងផ្សព្វផ្សាយ | ចូលរួមសិក្សាស្រាវជ្រាវ និងដាក់បញ្ចូលយេនឌ័រក្នុងដំណើរការអភិវឌ្ឍន៍សហគ្រាសខ្នាតមីក្រូ តូច និងមធ្យម ការអប់រំកម្រិតខ្ពស់ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការងារមានប្រាក់កម្រៃ និងពលកម្មចំណាកស្រុក | ក្រសួងកិច្ចការនារី ក្រសួងពាក់ព័ន្ធ អង្គការអន្តរជាតិនានា | | × | × | × | × | × | × |
| | | ពង្រីកការផ្សព្វផ្សាយលទ្ធផល នៃការស្រាវជ្រាវ ការអនុវត្ត និងអនុសាសន៍គោលនយោបាយទាក់ទងនឹងការអភិវឌ្ឍធនធានមនុស្សដែលឆ្លើយតបនឹងយេនឌ័រ | ក្រសួងកិច្ចការនារី ក្រសួងពាក់ព័ន្ធ អង្គការអន្តរជាតិនានា | | × | × | × | × | × | × |
| | | ដាក់បញ្ចូលលទ្ធផលពីការសិក្សាស្រាវជ្រាវទៅក្នុងរបៀបវារៈ នៃកិច្ចប្រជុំ TWG-G WEE | TWG-G WEE | | | × | × | × | × | × |
| ៣.រៀបចំ និងអនុវត្តគំរូផ្តួចផ្តើមនៃកិច្ចសហការជាមួយនឹងវិស័យឯកជន ជាពិសេសការអភិវឌ្ឍសហគ្រាសបៃតងដែលផ្តល់ផលប្រយោជន៍ផ្នែកសង្គមកិច្ច | ចំនួនកិច្ចព្រមព្រៀងសហការ ឬអនុស្សារណៈយោគយល់រវាងក្រសួងកិច្ចការនារីជាមួយនឹងដៃគូពាក់ព័ន្ធ សហគ្រាសបៃតង និងសហគ្រាស ផ្តល់ផលប្រយោជន៍ ផ្នែកសង្គមកិច្ច ក្នុងការបង្កើតប្រាក់ចំណូល និងផ្តល់ការងារសម្រាប់ស្ត្រី និងគ្រួសារ | សិក្សា និងធ្វើសេចក្តីសម្រេច អំពីជម្រើសតាមផ្លូវច្បាប់សម្រាប់ការបង្កើតភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ក្រុមហ៊ុនសាធារណៈ ឬគំរូកិច្ចសន្យាផ្សេងៗ សម្រាប់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី | ក្រសួងកិច្ចការនារី វិស័យឯកជន អង្គការអន្តរជាតិនានា | | × | × | × | | × | × |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | កំណត់ និងជ្រើសរើសមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីទៅតាមតំបន់ និងក្រុមសក្តានុពលសេដ្ឋកិច្ច ដែលពាក់ព័ន្ធនឹងឱកាសរកប្រាក់ចំណូលសម្រាប់ស្ត្រី រួមមានអ្នកពាក់ព័ន្ធ ក្នុងវិស័យសាធារណៈ ឯកជន និងអង្គការដៃគូពាក់ព័ន្ធ | ក្រសួងកិច្ចការនារី ក្រសួងពាក់ព័ន្ធ វិស័យឯកជន អង្គការអន្តរជាតិនានា | | × | × | × | | × | × |
| | | រៀបចំឯកសារយោង និងទម្រង់កិច្ចសន្យា ក្នុងការចាប់ផ្តើមអនុវត្តកម្មវិធីភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជនដោយផ្អែកលើជម្រើសស្របច្បាប់ ដែលបានសម្រេចដោយក្រសួងកិច្ចការនារី | ក្រសួងកិច្ចការនារី វិស័យឯកជន និងអង្គការអន្តរជាតិនានា | | × | × | × | | × | × |
| កាលានុវត្តភាព និងលក្ខខ័ណ្ឌការងារសម្រាប់ស្ត្រី រួមទាំងស្ត្រីពិការ និងក្រុមស្ត្រីដែលងាយរងគ្រោះផ្សេងទៀតមានភាពប្រសើរឡើង | | | | | | | | | | |
| ៤.លើកកម្ពស់ការតាក់តែង និងអនុវត្តគោលនយោបាយ និងកម្មវិធីជាតិ ស្តីពីការងារ ដែលមានបញ្ចូលការផ្តល់កាលានុវត្តភាពដល់ស្ត្រី | កម្មវិធីជាតិ ស្តីពីការងារ បានយកចិត្តទុកដាក់ និងឆ្លើយតបនឹងការពង្រីកកាលានុវត្តភាពការងារសម្រាប់ស្ត្រី | សហការ និងសម្របសម្រួលជាមួយនឹងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងពង្រីកការដាក់បញ្ចូល និងតាមដានចំណុចដៅ នៃការងារដែលមានសមធម៌យេនឌ័រ | ក្រសួងកិច្ចការនារី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដៃគូអភិវឌ្ឍន៍ | | × | × | × | × | × | × |
| ៥.ពង្រីកលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានផលប្រយោជន៍ពីលក្ខខណ្ឌការងារកិច្ចគាំពារសង្គម និងបទដ្ឋានការងារឱ្យកាន់តែមានភាពប្រសើរ | វិធានការជាក់លាក់ និងអំណះអំណាងក្នុងគោលនយោបាយ និងកម្មវិធីពាក់ព័ន្ធនឹងការងារដែលឆ្លើយតបនឹងតម្រូវការរបស់ស្ត្រីនិងសមភាពយេនឌ័រ | ចូលរួមតាក់តែងគោលនយោបាយ និងកម្មវិធីសម្រាប់កែលម្អលក្ខខណ្ឌការងារ កិច្ចគាំពារសង្គម និងបទដ្ឋានការងារនៅក្នុងវិស័យឯកជន ដោយដាក់បញ្ចូលសមភាពយេនឌ័រ | ក្រសួងកិច្ចការនារី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដៃគូអភិវឌ្ឍន៍ | | × | × | × | × | × | × |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សម្របសម្រួល និងសហការជាមួយនឹងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការផ្តួចផ្តើមលើការជំរុញកម្មវិធីសន្តិសុខសង្គម (ការធានារ៉ាប់រងសង្គម) សម្រាប់អ្នកធ្វើការក្នុងប្រព័ន្ធឱ្យឆ្លើយតបនឹងយេនឌ័រ | ក្រសួងកិច្ចការនារី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដៃគូអភិវឌ្ឍន៍ | | × | × | × | × | × | × |
| | មានប្រព័ន្ធតាមដាន និងវាយតម្លៃលើការអនុវត្តលក្ខខណ្ឌការងារ កិច្ចគាំពារសង្គម និងបទដ្ឋានការងារដែលឆ្លើយតបនឹងយេនឌ័រ | ចូលរួមតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ និងកម្មវិធីនានាសម្រាប់កែលម្អលក្ខខណ្ឌការងារកិច្ចគាំពារសង្គម និងបទដ្ឋានការងារ ជាពិសេសពាក់ព័ន្ធនឹងយេនឌ័រ | ក្រសួងកិច្ចការនារី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដៃគូអភិវឌ្ឍន៍ | | × | × | × | × | × | × |
| ៦. សម្របសម្រួលក្នុងការផ្តល់លទ្ធភាពដល់ស្ត្រីដើម្បីទទួលបានសេវាកម្មលើដោះស្រាយវិវាទការងារដោយស្មើភាពនឹងបុរស | កំណត់ត្រា នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលឆ្លើយតបនឹងយេនឌ័រ | សហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អង្គការពលកម្មអន្តរជាតិ សហព័ន្ធនិយោជក និងសមាគមអាជីវកម្ម អំពីគោលនយោបាយ និងកម្មវិធីនានា ដើម្បីបង្កើនចំណេករបស់ស្ត្រីក្នុងការស្វែងរកដំណោះស្រាយវិវាទការងារ | ក្រសួងកិច្ចការនារី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដៃគូអភិវឌ្ឍន៍ អង្គការពលកម្មអន្តរជាតិ សហព័ន្ធនិយោជក សមាគមអាជីវកម្ម | | × | × | × | × | × | × |
| ៧. សម្របសម្រួលក្នុងការផ្តល់លទ្ធភាពដល់ស្ត្រី ដើម្បីទទួលកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដែលផ្តល់ដោយស្ថាប័នសាធារណៈវិស័យឯកជន ឬអង្គការក្រៅរដ្ឋាភិបាល | របាយការណ៍របស់ស្ថាប័នសាធារណៈ វិស័យឯកជន និងអង្គការក្រៅរដ្ឋាភិបាលស្តីពីការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដែលឆ្លើយតបនឹងយេនឌ័រ | ដាក់បញ្ចូលយេនឌ័រទៅក្នុងផែនការ និងដំណើរការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ | ក្រសួងកិច្ចការនារី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | × | | × | | × | × |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សហការ និងជំរុញឱ្យការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ស្ត្រី ស្របតាមតម្រូវការទីផ្សារការងាររបស់ក្រុមហ៊ុនឯកជន ស្ថាប័នសាធារណៈ និងអង្គការក្រៅរដ្ឋាភិបាល | ក្រសួងកិច្ចការនារី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | × | × | × | × | × | × |
| | ចំនួនសិក្ខាកាមរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីដែលប្រើប្រាស់ជំនាញទទួលបានពីការបណ្តុះបណ្តាល ដែលឆ្លើយតបនឹងតម្រូវការទីផ្សារការងារ | ពិនិត្យនិងធ្វើបច្ចុប្បន្នកម្មវិធីបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី | ក្រសួងកិច្ចការនារី មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី | | × | × | | | × | × |
| | | បង្ហាញពីវិធីសាស្ត្របង្រៀនវិជ្ជាជីវៈតាមបែបបច្ចេកទេសថ្មីៗ ដែលរួមទាំងការអភិវឌ្ឍសហគ្រិនភាព | ក្រសួងកិច្ចការនារីមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ដៃគូពាក់ព័ន្ធ | | × | × | × | × | × | × |
| | | បណ្តុះបណ្តាលមន្ត្រីនិងគ្រូមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីអំពីការអភិវឌ្ឍអាជីវកម្មសហគ្រិនភាព និងវិធីផ្សរផ្គងការងារដល់សិស្ស | ក្រសួងកិច្ចការនារី មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី | | × | × | × | × | × | × |
| | | រៀបចំ និងអនុវត្តកម្មវិធីពង្រឹងសមត្ថភាពប្រើប្រាស់ឧបករណ៍សម្រាប់តាមដាន និងវាយតម្លៃលទ្ធផលនៃការបណ្តុះបណ្តាលវិជ្ជាជីវៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី | ក្រសួងកិច្ចការនារី មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី | | × | × | × | × | × | × |
| | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមានសម្ភារៈរូបវន្ត សមស្របសម្រាប់ស្ត្រី | ពិនិត្យ និងស្វែងរកការគាំទ្រមតិ ក្នុងការផ្តល់នូវមធ្យោបាយ ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធសមស្របសម្រាប់ស្ត្រីនៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលដែលមានស្រាប់ និងថ្មី | ក្រសួងកិច្ចការនារី ក្រសួងពាក់ព័ន្ធ ក្រុមហ៊ុនឯកជន អង្គការក្រៅរដ្ឋាភិបាល | | × | × | × | × | × | × |

| សហគ្រាសខ្នាតមីក្រូ តូច និងមធ្យមដែលគ្រប់គ្រងដោយស្ត្រី បានបង្កើត និងមានការអភិវឌ្ឍកាន់តែប្រសើរឡើង | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៨. បង្កើនការយល់ដឹងអំពីការបង្កើត និងអភិវឌ្ឍអាជីវកម្មដែលមានលក្ខណៈស្របច្បាប់ដល់អាជីវករជាស្ត្រី | ការយល់ដឹង អំពីច្បាប់ និងបទដ្ឋានគតិយុត្តទាក់ទងនឹងសហគ្រាសខ្នាតមីក្រូ តូច និងមធ្យមដល់ក្រុមអាជីវករ និងសហគ្រិនជាស្ត្រី បានកើនឡើង | សហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការបង្កើនការយល់ដឹងអំពីប្រធានបទ ដែលពាក់ព័ន្ធនឹងសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម ដូចជាការចុះបញ្ជីធុរៈកិច្ច ពន្ធគយ និងពន្ធអាករជាដើម | ក្រសួងកិច្ចការនារី<br>ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>ក្រសួងពាណិជ្ជកម្ម<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>សមាគមអាជីវកម្មសហគ្រិនស្ត្រី | × | × | × | × | × | × | × |
| | បញ្ហារបស់អាជីវករជាស្ត្រី បានដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃវេទិការាជរដ្ឋាភិបាលរវាងវិស័យសាធារណៈ និងវិស័យឯកជន | ប្រមូលបញ្ហាចម្បងៗរបស់អាជីវករស្ត្រីវិភាគ និងដាក់បញ្ចូលក្នុងរបៀបវារៈនៃវេទិការាជរដ្ឋាភិបាលរវាងវិស័យសាធារណៈ និងវិស័យឯកជន | ក្រសួងកិច្ចការនារី<br>សមាគមអាជីវកម្មសហគ្រិនស្ត្រី | × | × | × | × | × | × | × |
| | | ជំរុញ និងគាំទ្របច្ចេកទេស ដើម្បីលើកទឹកចិត្តស្ត្រីឱ្យចូលរួមក្នុងក្រុមការងារនៃវេទិការាជរដ្ឋាភិបាលរវាងវិស័យសាធារណៈ និងវិស័យឯកជន | ក្រសួងកិច្ចការនារី<br>សមាគមអាជីវកម្មសហគ្រិនស្ត្រី<br>ក្រុមការងារនៃវេទិការាជរដ្ឋាភិបាលរវាងវិស័យសាធារណៈ និងវិស័យឯកជន | × | × | × | × | × | × | × |
| ៩. សម្របសម្រួល ក្នុងការផ្តល់លទ្ធភាពដល់ស្ត្រីដើម្បីទទួលសេវាអភិវឌ្ឍន៍អាជីវកម្មពាក់ព័ន្ធនឹងសហគ្រាសខ្នាតមីក្រូ តូច និងមធ្យមដល់ស្ត្រីជាអាជីវករ | ចំនួនស្ត្រី ដែលទទួលបានសេវាអភិវឌ្ឍន៍អាជីវកម្ម | រៀបចំព្រឹត្តការណ៍ និងកម្មវិធីបង្កើនការយល់ដឹងពីសេវាអភិវឌ្ឍន៍អាជីវកម្មសំខាន់ៗ សម្រាប់អាជីវករជាស្ត្រី តាមរយៈកិច្ចសហការ និងភាពជាដៃគូជាមួយអ្នកផ្តល់សេវាអភិវឌ្ឍន៍អាជីវកម្ម ទាំងផ្នែកសាធារណៈ និងឯកជន រួមទាំងស្ថាប័នមីក្រូហិរញ្ញវត្ថុ | ក្រសួងកិច្ចការនារី<br>ក្រសួងពាក់ព័ន្ធ<br>ស្ថាប័នមីក្រូហិរញ្ញវត្ថុ | | × | × | × | × | × | × |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១០. អភិវឌ្ឍសមត្ថភាពក្នុងការបង្កើតបណ្តាញសហគ្រិនស្ត្រី | ចំនួន និងសមាជិកភាពរបស់សមាគមអាជីវកម្មជាស្ត្រី | សហការជាមួយនឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីលើកកម្ពស់ការបង្កើត និងដំណើរការសមាគមស្ត្រីអាជីវករ និងក្រុមផលិតជាស្ត្រី | ក្រសួងកិច្ចការនារី<br>ក្រសួងពាក់ព័ន្ធ<br>ក្រុមហ៊ុនឯកជន | | × | × | × | × | × | × |
| | ចំនួនសមាជិកស្ត្រីនៃសមាគមអាជីវកម្ម | គាំទ្រ និងជំរុញលើកទឹកចិត្តស្ត្រី និងសម្របសម្រួលជាមួយនឹងសមាគមអាជីវកម្ម ក្នុងការបង្កើនសមាជិកស្ត្រី | ក្រសួងកិច្ចការនារី<br>ក្រសួងពាក់ព័ន្ធ<br>ក្រុមហ៊ុនឯកជន | | × | × | × | × | × | × |
| **ស្ត្រីក្រីក្រ និងស្ត្រីដែលងាយរងគ្រោះនៅជនបទ វិនិយោគប្រាក់ចំណូលរបស់គេទៅក្នុងការអភិវឌ្ឍជីវភាពរស់នៅ** | | | | | | | | | | |
| ១១. អភិវឌ្ឍសមត្ថភាព និងជំនាញដល់ស្ត្រីក្នុងការគ្រប់គ្រងសង្គមគ្រួសារនិងលំនៅដ្ឋាន ដែលមានបរិស្ថានល្អប្រកបដោយចីរភាព | ចំនួនស្ត្រីដែលប្រើប្រាស់ជំនាញបំណិនជីវិតទទួលបានពីស្ថាប័នសាធារណៈ ឯកជន និងអង្គការពាក់ព័ន្ធ | រៀបចំ និងសម្របសម្រួល ក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍន៍ជំនាញបំណិនជីវិត នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ឬនៅតាមសហគមន៍ តាមរយៈកិច្ចសហការជាមួយនឹងស្ថាប័នសាធារណៈ និងឯកជន | ក្រសួងកិច្ចការនារី<br>ក្រសួងពាក់ព័ន្ធ<br>អង្គការ និងវិស័យឯកជន | | × | × | × | × | × | × |
| ១២. ពង្រីកលទ្ធភាពដល់ស្ត្រីក្នុងការទទួលសេវាហិរញ្ញវត្ថុដែលមានលក្ខខ័ណ្ឌសមរម្យ | ចំនួនស្ត្រីមេគ្រួសារដែលទទួលបានសេវាហិរញ្ញវត្ថុមានលក្ខខ័ណ្ឌសមរម្យពីស្ថាប័នមីក្រូហិរញ្ញវត្ថុ | សម្របសម្រួល ក្នុងការផ្តល់កម្មវិធីបណ្តុះបណ្តាលស្តីពីការអប់រំហិរញ្ញវត្ថុដល់ស្ត្រី តាមរយៈកិច្ចសហការជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុ និងសមាគម ស្ថាប័នមីក្រូហិរញ្ញវត្ថុ | ក្រសួងកិច្ចការនារី<br>ស្ថាប័នមីក្រូហិរញ្ញវត្ថុ<br>សមាគមស្ថាប័នមីក្រូហិរញ្ញវត្ថុ | × | × | × | × | × | × | × |
| ១៣. ពង្រីកកាលានុវត្តភាពសេដ្ឋកិច្ចដល់ស្ត្រី ក្នុងការប្រកបមុខរបរ និងវិនិយោគក្នុងការអភិវឌ្ឍជីវភាពរស់នៅ | ចំនួនស្ត្រីដែលចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច ដូចជាការធ្វើស្រែចំការ ការលក់ដូរអាជីវកម្ម និងមុខរបរផ្សេងៗនៅតាមសហគមន៍ | សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន ក្នុងបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកវិទ្យាថ្មីៗ ព័ត៌មាន និងចំណេះដឹងថ្មីៗដល់ស្ត្រី និងសហគមន៍ | ក្រសួងកិច្ចការនារី<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>ក្រសួងអភិវឌ្ឍន៍ជនបទ<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>អង្គការដៃគូពាក់ព័ន្ធ | × | × | × | × | × | × | × |

| ស្ត្រីចំណាកស្រុកទទួលបានផលប្រយោជន៍ពីការធ្វើចំណាកស្រុកទៅក្រៅប្រទេស និងហានិភ័យនានាបានកាត់បន្ថយ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១៤.លើកកម្ពស់ និងឆ្លើយតបនឹងបញ្ហារបស់ស្ត្រីពាក់ព័ន្ធនឹងការធ្វើចំណាកស្រុកនៅក្នុងដំណើរការតាក់តែងគោលនយោបាយ និងកម្មវិធីនានា | ចំនួនស្ត្រីពលករចំណាកស្រុកក្នុងប្រទេសអាស៊ានប្រកបដោយសុវត្ថិភាព និងស្របច្បាប់ | ចូលរួមរៀបចំគោលនយោបាយ និងកម្មវិធីនានាសម្រាប់គាំទ្រស្ត្រីពលករចំណាកស្រុក | ក្រសួងកិច្ចការនារី<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ដៃគូអភិវឌ្ឍន៍<br>អង្គការក្រៅរដ្ឋាភិបាល | | × | × | × | × | × | × |
| | | សហការជាមួយនឹងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីផ្សព្វផ្សាយពីផលប្រយោជន៍ និងហានិភ័យនៃការធ្វើចំណាកស្រុក | ក្រសួងកិច្ចការនារី<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ដៃគូអភិវឌ្ឍន៍<br>អង្គការក្រៅរដ្ឋាភិបាល | | × | × | × | × | × | × |
| ១៥.លើកកម្ពស់ការកាត់បន្ថយគ្រោះថ្នាក់ និងបញ្ហាផ្សេងៗ ដែលពាក់ព័ន្ធនឹងការធ្វើចំណាកស្រុករបស់ពលករស្ត្រី | ចំនួនគ្រោះថ្នាក់ និងបញ្ហា ដែលពាក់ព័ន្ធនឹងចំណាកស្រុករបស់ពលករដែលបានលើកឡើងក្នុងរបាយការណ៍របស់ក្រសួងស្ថាប័នពាក់ព័ន្ធមានការថយចុះ | សហការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាល ក្នុងការតាមដានរបាយការណ៍ផ្លូវការអំពីបទល្មើសលើពលករចំណាកស្រុកជាស្ត្រី | ក្រសួងកិច្ចការនារី<br>ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងមហាផ្ទៃ | | × | × | × | × | × | × |
| | | សហការជាមួយនឹងក្រសួង ស្ថាប័ន ពាក់ព័ន្ធ ក្នុងការផ្សព្វផ្សាយវិធីស្វែងរកជំនួយស្របច្បាប់ និងការការពារនៅក្រៅប្រទេស សម្រាប់ពលករ ជាពិសេសសម្រាប់ស្ត្រី | ក្រសួងកិច្ចការនារី<br>ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងមហាផ្ទៃ<br>មជ្ឈមណ្ឌលធនធានពលករទេសន្តរប្រវេសន៍<br>ក្រុមហ៊ុនជ្រើសរើសពលករ<br>និងអង្គការក្រៅរដ្ឋាភិបាល | | × | × | × | × | × | × |

# ២. សេវាសង្គម និងកិច្ចគាំពារសង្គម

## ២.១. ការអប់រំស្ត្រីនិងក្មេងស្រី និងការផ្លាស់ប្តូរឥរិយាបថ

គោលបំណង៖ លើកកម្ពស់ការសម្រេចបាននូវសមភាពយេនឌ័រក្នុងវិស័យអប់រំ ជាពិសេសបង្កើនការទទួលបាននូវសេវាអប់រំដល់ស្ត្រីនិងកុមារី ក្នុងក្រុមដែលងាយរងគ្រោះ តាមរយៈវិធានការបង្កើនការយល់ដឹង គណនេយ្យភាពសង្គម អាហារូបករណ៍ និងជំនួយហិរញ្ញវត្ថុផ្សេងទៀត និងបង្កើនការចូលរួមរបស់ស្ត្រីដែលជាអ្នកផ្តល់ និងគ្រប់គ្រងសេវាអប់រំនៅគ្រប់ផ្នែក ព្រមទាំងលើកកម្ពស់សីលធម៌ សុខមាលភាពសង្គម អាកប្បកិរិយា និងឥរិយាបថសង្គមដែលឆ្លើយតបនឹងយេនឌ័រ ។

| យុទ្ធសាស្ត្រ | សូចនាករ | សកម្មភាពគន្លឹះ | ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលវេលា | | | | | ធនធាន | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | 14 | 15 | 16 | 17 | 18 | ជាតិ | ដៃគូ |
| គម្លាតយេនឌ័របានឆ្លើយតបនៅក្នុងដំណើរការតាក់តែង និងអនុវត្តគោលនយោបាយ កម្មវិធី និងផែនការពាក់ព័ន្ធនឹងវិស័យអប់រំ ដោយមានការគិតគូរដល់ក្រុមងាយរងគ្រោះ[37] | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | សមត្ថភាពក្នុងការបញ្ជ្រាបយេនឌ័ររបស់មន្ទីរកិច្ចការនារីរាជធានី ខេត្ត និងកិច្ចការនារីក្រុង ស្រុក ខណ្ឌ ត្រូវបានពង្រឹង | គាំទ្របច្ចេកទេស និងពង្រឹងសមត្ថភាពមន្ទីរកិច្ចការនារី និងអនុប្រធានអចិន្ត្រៃយ៍ គ.ក.ស.ក[50] និង គ.ក.ន.ក[51] ក្នុងការអនុវត្តការបញ្ជ្រាបយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី | ក្រសួងកិច្ចការនារី<br>គ.ជ.អ.ប<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ | × | × | × | × | × | × | × |
| | ករណីសិក្សាអំពីយេនឌ័រនៅថ្នាក់ក្រោមជាតិបានចងក្រង និងផ្សព្វផ្សាយ | ចងក្រង និងផ្សព្វផ្សាយករណីសិក្សា អំពីការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ ពិសេសសវនកម្មយេនឌ័រ | ក្រសួងកិច្ចការនារី<br>គ.ជ.អ.ប | × | × | × | | | × | × |
| ៧. ចូលរួមរៀបចំ និងអនុវត្តគោលនយោបាយ ផែនការ កម្មវិធី និងលិខិតបទដ្ឋានដែលទាក់ទងនឹងកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈឱ្យឆ្លើយតបនឹងយេនឌ័រ | ចំនួនគោលនយោបាយ កម្មវិធី និងឯកសារពាក់ព័ន្ធនឹងកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលឆ្លើយតបយេនឌ័រ | សហការជាមួយនឹងក្រសួងមុខងារសាធារណៈ និងស្ថាប័នពាក់ព័ន្ធដើម្បីបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ ផែនការជាតិ និងផែនការប្រចាំឆ្នាំរបស់កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ | ក្រសួងកិច្ចការនារី<br>ក្រសួងមុខងារសាធារណៈ<br>ក្រុមការងារយេនឌ័រ នៃក្រសួងស្ថាប័នពាក់ព័ន្ធ<br>សាលាភូមិន្ទរដ្ឋបាល | | × | × | × | × | × | × |
| | បញ្ហាប្រឈមនៃការបញ្ជ្រាបយេនឌ័រក្នុងកំណែទម្រង់រដ្ឋបាលសាធារណៈបានកំណត់ និងលើកអនុសាសន៍សម្រាប់អនុវត្តបន្ត | សហការរៀបចំធ្វើសវនកម្មយេនឌ័រក្នុងកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីវិភាគ និងរៀបចំយុទ្ធសាស្ត្រសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងអង្គភាព ផែនការ ដំណើរការ និងលទ្ធផលរំពឹងទុក | ក្រសួងកិច្ចការនារី<br>ក្រសួងមុខងារសាធារណៈ<br>ក្រុមការងារយេនឌ័រ នៃក្រសួងស្ថាប័នពាក់ព័ន្ធ | | | | × | × | × | × |
| | កម្រិតយល់ដឹងរបស់មន្ត្រីរដ្ឋបាលសាធារណៈ ក្នុងការឆ្លើយតបនឹងយេនឌ័រ | សហការ និងគាំទ្របច្ចេកទេស ក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងការគ្រប់គ្រង រដ្ឋបាលសាធារណៈ និងកម្មវិធីបណ្តុះបណ្តាលរបស់កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ | ក្រសួងកិច្ចការនារី<br>ក្រសួងមុខងារសាធារណៈ<br>ក្រុមការងារយេនឌ័រ នៃក្រសួងស្ថាប័នពាក់ព័ន្ធ<br>សាលាភូមិន្ទរដ្ឋបាល | × | × | × | × | × | × | × |

[50] គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
[51] គណៈកម្មាធិការកិច្ចការនារីនិងកុមារឃុំសង្កាត់

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | កម្មវិធីឯកសារបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីមុខងារសាធារណៈមានការឆ្លើយតបយេនឌ័រ | សហការជាមួយសាលាភូមិន្ទរដ្ឋបាល និងក្រសួងមុខងារសាធារណៈក្នុងការផ្តល់វគ្គបណ្តុះបណ្តាលស្តីពីយេនឌ័រ និងគាំទ្របច្ចេកទេសក្នុងការបណ្តុះបណ្តាលដល់សាលាគរុកោសល្យ និងគ្រឹះស្ថានសិក្សានានា | ក្រសួងកិច្ចការនារី<br>ក្រសួងមុខងារសាធារណៈ<br>សាលាភូមិន្ទរដ្ឋបាល<br>ក្រសួងអប់រំ យុវជននិងកីឡា | × | × | × | × | × | × | × |
| ៨. សហការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការធានាការទទួលបានថវិកាសម្រាប់បញ្ជ្រាបយេនឌ័រ តាមរយៈកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ចំនួនក្រសួង ស្ថាប័នទទួលបានថវិកាសម្រាប់ការបញ្ជ្រាបយេនឌ័រ | សហការជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងផែនការសកម្មភាព និងផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ និងធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រទៅក្នុងផែនការយុទ្ធសាស្ត្រ និងថវិការបស់ក្រសួង ដើម្បីធានាការទទួលបានការគាំទ្រថវិកាពីក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ | ក្រសួងកិច្ចការនារី<br>ក្រសួងសេដ្ឋកិច្ច<br>និងហិរញ្ញវត្ថុ<br>ក្រុមការងារយេនឌ័រ | × | × | × | × | × | × | × |
| | កម្រិតយល់ដឹងរបស់ក្រុមការងារយេនឌ័រ និងមន្ត្រីពាក់ព័ន្ធការរៀបចំថវិកាដែលឆ្លើយតបនឹងយេនឌ័រ | អភិវឌ្ឍសមត្ថភាពជំនាញស្តីពីការរៀបចំផែនការ និងថវិកាឆ្លើយតបនឹងយេនឌ័រដល់ក្រសួងពាក់ព័ន្ធ | ក្រសួងកិច្ចការនារី<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ក្រុមការងារយេនឌ័រ | × | × | × | × | × | × | × |
| ៩. បញ្ជ្រាបយេនឌ័រក្នុងកម្មវិធីកំណែទម្រង់ដីធ្លី និងជំរុញឱ្យស្ត្រីទទួលបាននូវសិទ្ធិស្មើភាពក្នុងការទទួល និងគ្រប់គ្រងដីធ្លីឱ្យកាន់តែប្រសើរឡើង | សមាមាត្រស្ត្រីជាម្ចាស់កម្មសិទ្ធិដីធ្លី | សហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងការអនុវត្តច្បាប់ និងគោលនយោបាយពាក់ព័ន្ធនឹងដីធ្លីដើម្បីផលប្រយោជន៍ស្ត្រី | ក្រសួងកិច្ចការនារី<br>ក្រសួងរៀបចំដែនដី<br>នគរូបនីយកម្ម និងសំណង់<br>ក្រុមប្រឹក្សាគោលនយោ-<br>បាយដីធ្លី | × | × | × | × | × | × | × |
| | ច្បាប់គោលនយោបាយ និងកម្មវិធីនានាដែលពាក់ព័ន្ធនឹងកម្មវិធីកំណែទម្រង់ដីធ្លីឆ្លើយតបយេនឌ័រនិងក្រុមជនងាយរងគ្រោះ | បន្តអភិវឌ្ឍសមត្ថភាព និងបញ្ជ្រាបយេនឌ័រក្នុងច្បាប់គោលនយោបាយ និងកម្មវិធីនានាដែលពាក់ព័ន្ធនឹងកម្មវិធីកំណែទម្រង់ដីធ្លី | ក្រសួងកិច្ចការនារី<br>ក្រសួងរៀបចំដែនដី<br>នគរូបនីយកម្ម និងសំណង់<br>ក្រុមប្រឹក្សាគោលនយោ-<br>បាយដីធ្លី | × | × | × | × | × | × | × |

## ៣.២. យេនឌ័រ និងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ

គោលបំណង៖ លើកកម្ពស់សមភាពយេនឌ័រ ក្នុងដំណើរការតាក់តែង និងអនុវត្តគោលនយោបាយ និងកម្មវិធីជាតិពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងគ្រប់គ្រងគ្រោះមហន្តរាយរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ នៅថ្នាក់ជាតិ និងក្រោមជាតិ ជាពិសេសក្នុងការកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមានមកលើស្ត្រី និងជនដែលងាយរងគ្រោះ ព្រមទាំងចូលរួមចំណែកក្នុងដំណើរការអភិវឌ្ឍន៍បៃតង ។

| យុទ្ធសាស្ត្រ | សូចនាករ | សកម្មភាពគន្លឹះ | ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលវេលា | | | | | ធនធាន | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | 14 | 15 | 16 | 17 | 18 | ជាតិ | ដៃគូ |
| គោលនយោបាយ កម្មវិធី និងផែនការយុទ្ធសាស្ត្រ ស្តីពីបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយដែលឆ្លើយតបនឹងយេនឌ័រ | | | | | | | | | | |
| ១. បង្កើនសមត្ថភាពបច្ចេកទេស និងការគាំទ្រពីថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធស្តីពីយេនឌ័រ និងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ | កម្មវិធីអភិវឌ្ឍសមត្ថភាព ស្តីពីយេនឌ័រនិងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយដល់ក្រុមការងារថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ បានរៀបចំ និងដាក់បញ្ចូលក្នុងកម្មវិធីនានាក្នុងវិស័យពាក់ព័ន្ធ | រៀបចំ និងអនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាពពាក់ព័ន្ធនឹងយេនឌ័រ និងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ<br><br>អភិវឌ្ឍសមត្ថភាព ស្តីពីយេនឌ័រ និងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ ដល់ក្រុមការងារមន្ត្រីបច្ចេកទេស និងដៃគូពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ | ក្រសួងកិច្ចការនារី<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង<br>គណៈកម្មាធិការជាតិគ្រប់គ្រងបម្រែបម្រួលអាកាសធាតុ<br>គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ<br>ក្រសួងមហាផ្ទៃ<br>គ.ជ.អ.ប | × | × | × | × | | × | × |
| ២. បញ្ជ្រាបយេនឌ័រ ក្នុងដំណើរការតាក់តែង និងអនុវត្តគោលនយោបាយ កម្មវិធី និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ | គោលនយោបាយ កម្មវិធី និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយដែលឆ្លើយតបនឹងយេនឌ័រ | ពិនិត្យឡើងវិញលើការឆ្លើយតបនឹងយេនឌ័រនៅក្នុងគោលនយោបាយកម្មវិធី ផែនការដែលមានស្រាប់ និងប្រព័ន្ធយន្តការការងារសំខាន់ៗ រួមបញ្ចូលទាំងផែនការយុទ្ធសាស្ត្រ គោលនយោបាយជាតិ និងកម្មវិធី | ក្រសួងកិច្ចការនារី<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង<br>គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ | × | × | × | × | × | × | × |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយមានភាពប្រសើរឡើង | | សម្របសម្រួល និងគាំទ្របច្ចេកទេស ក្នុងការបញ្ជ្រាបបញ្ហាយេនឌ័រ ទៅក្នុងដំណើរការរៀបចំ និងអនុវត្តគោលនយោបាយ កម្មវិធី ផែនការសកម្មភាព និងថវិកាវិស័យពាក់ព័ន្ធដោយមានការចូលរួមពីសង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍<br><br>សហការ និងសម្របសម្រួល ជាមួយនឹង លេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុកម្ពុជា ដើម្បីបញ្ជ្រាបគោលការណ៍ណែនាំ ស្តីពីការវាយតម្លៃផលប៉ះពាល់យេនឌ័រ ដែលបណ្តាលពីការប្រែប្រួលអាកាសធាតុ ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ<br><br>បង្កើតក្របខណ្ឌតាមដាន និងវាយតំលៃទៅលើយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីត្រួតពិនិត្យវាយតម្លៃ និងជំរុញការអនុវត្តកម្មវិធីបញ្ជ្រាបយេនឌ័រក្នុងក្រសួងស្ថាប័នពាក់ព័ន្ធ | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | | | | | | | |
| | បម្រែបម្រួលអាកាសធាតុ ត្រូវបានបញ្ជ្រាបក្នុងកម្មវិធីរបស់ ក្រសួងកិច្ចការនារី | បញ្ជ្រាបវិធានការពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយក្នុងកម្មវិធីរបស់ក្រសួងកិច្ចការនារី | ក្រសួងកិច្ចការនារី | × | × | × | × | × | × | × |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៣. លើកកម្ពស់ការចូលរួមដោយស្មើភាពរបស់ស្ត្រី ក្រុមស្ត្រី ក្មេងស្រីងាយរងគ្រោះ ក្នុងដំណើរការសម្របសម្រួល និងស្វែងរកការគាំទ្រមតិ ស្តីពីបម្រែបម្រួលអាកាសធាតុនៅថ្នាក់អន្តរជាតិ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីផលប្រយោជន៍ដល់ស្ត្រី | ភាគរយស្ត្រី និងក្រុមស្ត្រីងាយរងគ្រោះ ដែលបានចូលរួមក្នុងដំណើរការនៃកិច្ចពិគ្រោះយោបល់ ការអនុវត្ត តាមដានសកម្មភាពទាក់ទងនឹងបម្រែបម្រួលអាកាសធាតុនៅថ្នាក់អន្តរជាតិ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | បង្កើនការចូលរួមជាតំណាងស្ត្រី នៅក្នុងសន្និសីទ វេទិកា បណ្តាញថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ<br><br>រៀបចំសវនកម្មយេនឌ័រ ជាពិសេសពិនិត្យលើគម្លាតនៃភាពអង់អាចក្នុងការចូលរួមរបស់ស្ត្រី និងក្រុមស្ត្រីងាយរងគ្រោះ ក្នុងដំណើរការនៃការគ្រប់គ្រងបម្រែបម្រួលអាកាសធាតុ ដើម្បីរៀបចំវិធានការនានា<br><br>បញ្ជ្រាបយេនឌ័រ និងបម្រែបម្រួលអាកាសធាតុនៅក្នុងផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ | លេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រងបម្រែបម្រួលអាកាសធាតុ<br><br>ក្រសួងបរិស្ថាន<br>ក្រសួងកិច្ចការនារី<br>គ.ជ.អ.ប<br>ដៃគូអភិវឌ្ឍន៍ | × | × | × | × | × | × | × |
| ៤. កាត់បន្ថយផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ និងគ្រោះមហន្តរាយនានាមកលើស្ត្រី និងក្រុមស្ត្រីក្មេងស្រីដែលងាយរងគ្រោះ | តម្រូវការជាក់លាក់របស់ស្ត្រី និងក្រុមស្ត្រីងាយរងគ្រោះបានដោះស្រាយនៅក្នុងដំណើរការឆ្លើយតបទៅនឹងបម្រែបម្រួលអាកាសធាតុ និងគ្រប់គ្រងគ្រោះមហន្តរាយ | សហការ និងសម្របសម្រួលជាមួយគណៈកម្មាធិការជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ក្នុងការបញ្ជ្រាបយេនឌ័រក្នុងយុទ្ធសាស្ត្រជាតិឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ ការកាត់បន្ថយហានិភ័យ និងយន្តការពាក់ព័ន្ធនានា ដូចជាបង្កើតយន្តការផ្តល់ព័ត៌មានត្រឡប់ប្រកបដោយប្រសិទ្ធភាព ដើម្បីធានាតម្លាភាព គណនេយ្យភាព និងសមភាពក្នុងការឆ្លើយតបនឹងគ្រោះមហន្តរាយឱ្យបានដល់ស្ត្រី និងក្រុមស្ត្រីងាយរងគ្រោះ | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ<br>គណៈកម្មាធិការជាតិគ្រប់គ្រងបម្រែបម្រួលអាកាសធាតុ<br>ក្រសួងកិច្ចការនារី | × | × | × | × | × | × | × |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | គំនិតផ្តួចផ្តើម ក្នុងការរៀបចំកម្មវិធីនិងសកម្មភាពឆ្លើយតបនឹងតម្រូវការជាក់ស្តែង ដូចជាសុវត្ថិភាពនិងសន្តិសុខផ្ទាល់ខ្លួន ការទទួលបានទឹកស្អាត ឱសថ សេវាថែទាំនិងព្យាបាលសុខភាព ស្បៀង ជំរកសុវត្ថិភាពនិងអនាម័យប្រើប្រាស់ សម្រាប់ស្ត្រីនិងក្រុមស្ត្រីងាយរងគ្រោះបានដាក់បញ្ចូលទៅក្នុងកម្មវិធីគ្រប់គ្រងនិងឆ្លើយតបគ្រោះមហន្តរាយ | | × | × | × | × | × | × | × |
| ៥. បង្កើនការចូលរួមរបស់ស្ត្រី ក្នុងកម្មវិធី និងសកម្មភាពអភិវឌ្ឍន៍បៃតង | ចំនួនស្ត្រីចូលរួមក្នុងសកម្មភាពដែលពាក់ព័ន្ធនឹងការអភិវឌ្ឍបៃតង | សហការ និងសម្របសម្រួលជាមួយនឹងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងបរិស្ថាន ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីធានាស្ត្រីបានចូលរួមកាន់តែច្រើននៅក្នុងសកម្មភាពអភិវឌ្ឍន៍បៃតង | ក្រសួងកិច្ចការនារី<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង<br>គណៈកម្មាធិការជាតិគ្រប់គ្រងបម្រែបម្រួលអាកាសធាតុ<br>ក្រសួងបរិស្ថាន<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ<br>ដៃគូអភិវឌ្ឍន៍<br>វិស័យឯកជន | × | × | × | × | × | × | × |

| ការសិក្សាស្រាវជ្រាវថ្មីៗ ស្តីពីបញ្ហាយេនឌ័រក្នុងកម្មវិធីបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៦. ផ្តួចផ្តើមគំនិត និងសកម្មភាពថ្មីៗដែលឆ្លើយតបនឹងយេនឌ័រ ក្នុងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ ដោយសាកល្បង និងទទួលយកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការដាក់បញ្ចូលទៅក្នុងកម្មវិធីដែលកំពុងដំណើរការ | ចំនួននៃការសិក្សាស្រាវជ្រាវ ស្តីពីយេនឌ័រ និងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ | សហការ ក្នុងការអនុវត្ត និងវាយតម្លៃ គម្រោងសាកល្បងថ្មីៗ ដើម្បីដោះស្រាយបញ្ហាយេនឌ័រ និងបម្រែបម្រួលអាកាសធាតុ មានជាអាទិ៍ថាមពលជំនួស ដំណើរការនៃការផលិត និងការគ្រប់គ្រងគ្រោះមហន្តរាយ (អនាម័យ សុវត្ថិភាពផ្ទាល់ខ្លួន និងសន្តិសុខស្បៀង)<br><br>រៀបចំការស្រាវជ្រាវ ស្តីពីគ្រោះធម្មជាតិលើស្ត្រី និងក្រុមស្ត្រីងាយរងគ្រោះ បុរស កុមារី និងកុមារា ដោយសហការជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ<br><br>រៀបចំការស្រាវជ្រាវ ស្តីពីតួនាទី និងការរួមចំណែករបស់ស្ត្រី ជាពិសេសក្រុមស្ត្រីងាយរងគ្រោះ ក្នុងការគ្រប់គ្រងព្រៃឈើ និងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ព្រមទាំងស្ថាប័នពាក់ព័ន្ធ | ក្រសួងកិច្ចការនារី<br>គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង<br>គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>ក្រសួងបរិស្ថាន<br>ដៃគូអភិវឌ្ឍន៍<br>អង្គការសង្គមស៊ីវិល | × | × | × | × | × | × | × |

## ៤. ការពង្រឹងស្ថាប័ន និងការអភិវឌ្ឍសមត្ថភាព ដើម្បីឆ្ពោះទៅសមភាពយេនឌ័រ

គោលបំណង៖ ពង្រឹងរចនាសម្ព័ន្ធស្ថាប័ន និងសមត្ថភាពសម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ តាមរយៈការអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងចូលរួមអនុវត្តគោលនយោបាយពង្រឹងអភិបាលកិច្ចល្អ ដែលរួមបញ្ចូលក្រុមស្ត្រី និងក្មេងស្រីងាយរងគ្រោះ ។

| យុទ្ធសាស្ត្រ | សូចនាករ | សកម្មភាពគន្លឹះ | ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលវេលា | | | | | ធនធាន | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | 14 | 15 | 16 | 17 | 18 | ជាតិ | ដៃគូ |
| ក្រសួងកិច្ចការនារី និងរចនាសម្ព័ន្ធយន្តការជាតិ បានឆ្លុះបញ្ចាំងពីមុខងារជាអ្នកជំរុញ ស្វែងរកការគាំទ្រមតិ ពិគ្រោះយោបល់ និងអ្នកសម្របសម្រួល | | | | | | | | | | |
| ១. សិក្សាឡើងវិញនូវមុខងាររបស់ស្ថាប័ន និងយន្តការជាតិ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ | របាយការណ៍ ស្តីពីការសិក្សាមុខងារស្ថាប័ន និងយន្តការជាតិ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងដោយរួមបញ្ចូលអនុសាសន៍ទាក់ទងនឹងការធ្វើសុខដុមនីយកម្ម និងការពង្រឹងយន្តការទាំងនេះ | រៀបចំសិក្សាមុខងារ និងភារកិច្ចរបស់ស្ថាប័ន និងយន្តការក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចស្ត្រី | ក្រសួងកិច្ចការនារី<br>ក. ជ. ក. ស<br>TWG-G<br>ក្រុមការងារយេនឌ័ររដ្ឋបាលថ្នាក់ក្រោមជាតិ | | × | | | | × | × |
| | របាយការណ៍សិក្សាពីផែនទីមុខងាររបស់ដៃគូ អ្នកពាក់ព័ន្ធ ក្នុងការលើកកម្ពស់យេនឌ័រ | រៀបចំផែនទីមុខងាររបស់ដៃគូសំខាន់ៗពាក់ព័ន្ធនឹងការលើកកម្ពស់សមភាពយេនឌ័រថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយរួមបញ្ចូលទាំងស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល | ក្រសួងកិច្ចការនារី<br>ក. ជ. ក. ស<br>TWG-G<br>ក្រុមការងារយេនឌ័ររដ្ឋបាលថ្នាក់ក្រោមជាតិ | | × | | | | × | × |
| ២. កែសម្រួលឱ្យកាន់តែប្រសើរឡើងនូវរចនាសម្ព័ន្ធតួនាទី និងភារកិច្ចរបស់ស្ថាប័ន និងយន្តការជាតិក្នុងការលើកកម្ពស់សមភាពយេនឌ័រ | រចនាសម្ព័ន្ធស្ថាប័នយន្តការ និងបណ្តាញការងារជាតិ ដែលបានកែសម្រួល និងអនុវត្តជាមួយនឹងតួនាទី និងភារកិច្ចជាក់លាក់សម្រាប់អង្គភាពនីមួយៗ | រៀបចំ និងផ្សព្វផ្សាយលិខិតបទដ្ឋាន និងសេចក្តីណែនាំក្នុងការកែសម្រួលរចនាសម្ព័ន្ធ យន្តការ និងបណ្តាញការងារលើកកម្ពស់សមភាពយេនឌ័រ ដែលកំណត់ពីតួនាទី និងភារកិច្ច ច្បាស់លាស់ស្របតាមស្ថានភាពបច្ចុប្បន្ន | ក្រសួងកិច្ចការនារី<br>TWG-G<br>ក. ជ. ក. ស<br>ក្រុមការងារយេនឌ័រ | | × | × | | | × | × |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សម្របសម្រួល គាំទ្របច្ចេកទេស និងជំរុញការអនុវត្តរចនាសម្ព័ន្ធ និងបណ្តាញការងារ (ដែលបានកែសម្រួល) រួមទាំងតួនាទី និងភារកិច្ចរបស់យន្តការក្នុងការលើកកម្ពស់សមភាពយេនឌ័រ | ក្រសួងកិច្ចការនារី<br>TWG-G<br>ក.ជ.ក.ស<br>ក្រុមការងារយេនឌ័រ | | | × | × | × | × | × |
| ក្រសួងកិច្ចការនារី និងយន្តការជាតិមានសមត្ថភាពបំពេញមុខងារជាកតាលីករ ស្វែងរកការគាំទ្រមតិ ពិគ្រោះយោបល់ និងសម្របសម្រួលក្នុងការលើកកម្ពស់សមភាពយេនឌ័រ | | | | | | | | | | |
| ៣.ប៉ាន់ប្រមាណតម្រូវការអភិវឌ្ឍសមត្ថភាពរបស់អង្គភាពនីមួយៗ (ដែលស្របតាមរចនាសម្ព័ន្ធ និងបណ្តាញការងារលើកកម្ពស់សមភាពយេនឌ័រដែលបានកែសម្រួល) | របាយការណ៍នៃការប៉ាន់ប្រមាណតម្រូវការ និងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពក្រសួងកិច្ចការនារី ក.ជ.ក.ស ក្រុមការងារយេនឌ័រ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើត | រៀបចំក្រុមអ្នកជំនាញអភិវឌ្ឍស្ថាប័ន ដើម្បីសម្របសម្រួលកម្មវិធីប៉ាន់ប្រមាណ តម្រូវការអភិវឌ្ឍសមត្ថភាពរបស់អង្គភាព និងយន្តការនីមួយៗ | ក្រសួងកិច្ចការនារី<br>ក.ជ.ក.ស<br>TWG-G<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ | | × | × | | | × | × |
| | | អនុវត្តកម្មវិធីប៉ាន់ប្រមាណ និងរៀបចំកម្មវិធី ផែនការអភិវឌ្ឍសមត្ថភាពលម្អិត តាមជំហានៗរបស់អង្គភាពនីមួយៗ | ក្រសួងកិច្ចការនារី<br>ក.ជ.ក.ស<br>TWG-G<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ | | × | × | × | | × | × |
| ៤.រៀបចំឯកសារសម្រាប់បណ្តុះបណ្តាល ក្នុងកម្មវិធីអភិវឌ្ឍសមត្ថភាពយន្តការ និងស្ថាប័នលើកកម្ពស់សមភាពយេនឌ័រ | ឯកសារបណ្តុះបណ្តាល ក្នុងកម្មវិធីអភិវឌ្ឍសមត្ថភាព បានរៀបចំ | រៀបចំឯកសារណែនាំ និងសម្រាប់បណ្តុះបណ្តាលក្នុងការអភិវឌ្ឍសមត្ថភាពទៅតាមយន្តការ និងមុខជំនាញនីមួយៗ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ | ក្រសួងកិច្ចការនារី<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ | | | × | × | × | × | × |
| ៥.អភិវឌ្ឍសមត្ថភាពរបស់ក្រសួងកិច្ចការនារី ក្នុងការប៉ាន់ប្រមាណ និងអភិវឌ្ឍសមត្ថភាពរបស់ក្រសួងស្ថាប័ន ក្នុងការលើកកម្ពស់សមភាពយេនឌ័រតាមវិស័យ | ក្រសួងកិច្ចការនារីមានសមត្ថភាព ក្នុងការប៉ាន់ប្រមាណ និងអភិវឌ្ឍសមត្ថភាពនៃការបញ្ជ្រាបយេនឌ័ររបស់ក្រសួងស្ថាប័នតាមវិស័យនានា | ពង្រឹងសមត្ថភាពក្រសួងកិច្ចការនារី ក្នុងជំនាញប៉ាន់ប្រមាណតម្រូវការអភិវឌ្ឍន៍សមត្ថភាព និងរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពបញ្ជ្រាបយេនឌ័រតាមវិស័យ | ក្រសួងកិច្ចការនារី<br>ក្រុមការងារយេនឌ័រ | | × | × | × | | × | × |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ជ្រើសរើសអ្នកជំនាញយេនឌ័រតាមវិស័យ ក្នុងការគាំទ្របច្ចេកទេសដល់នាយកដ្ឋានជំនាញរបស់ក្រសួងកិច្ចការនារី និងក្រុមការងារយេនឌ័រតាមវិស័យ រួមទាំងការផ្តល់ប្រឹក្សាពីតម្រូវការយុទ្ធសាស្រ្តសម្រាប់ស្រ្តី និងក្មេងស្រីងាយរងគ្រោះ | ក្រសួងកិច្ចការនារី<br>ក្រុមការងារយេនឌ័រ | | × | × | × | × | × | × |
| | | បន្តបង្កើត និងគាំទ្រក្រុមការងារតាមវិស័យ និងក្រុមការងារបច្ចេកទេសយេនឌ័រ ក្នុងការពង្រឹងសុខុមនីយកម្មនៃកិច្ចខិតខំប្រឹងប្រែងរបស់អ្នកពាក់ព័ន្ធផ្សេងៗ ក្នុងវិស័យជាយុទ្ធសាស្រ្តដែលឆ្លើយតបនឹងយេនឌ័រ | ក្រសួងកិច្ចការនារី<br>ក្រុមការងារយេនឌ័រ | × | × | × | × | × | × | × |
| | | បង្កើតកម្មវិធី ឬយន្តកាធ្វើការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីបន្សី ( ដាក់បញ្ចូល)ផែនការយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រទៅក្នុងផែនការយុទ្ធសាស្រ្ត តាមវិស័យ និងផែនការសកម្មភាពថ្នាក់ជាតិពាក់ព័ន្ធ | ក្រសួងកិច្ចការនារី<br>ក្រុមការងារយេនឌ័រ | × | × | × | × | × | × | × |
| ៦.អភិវឌ្ឍសមត្ថភាពក្រសួងកិច្ចការនារី ក្នុងការរៀបចំផែនការតាមដាន វាយតម្លៃនិងផ្តល់អនុសាសន៍ទាក់ទងនឹងយេនឌ័រក្នុង គោលនយោ-បាយផែនការ និងកម្មវិធី | សមត្ថភាពក្រសួងកិច្ចការនារីក្នុងការរៀបចំផែនការតាមដាន និងវាយតម្លៃ និងផ្តល់អនុសាសន៍ទាក់ទងនឹងយេនឌ័រ ក្នុងគោលនយោបាយ ផែនការ និងកម្មវិធី | ពង្រឹងសមត្ថភាពក្រសួងកិច្ចការនារី រួមទាំងមន្ទីរកិច្ចការនារី ស្តីពីការវិភាគយេនឌ័រ និងគោលនយោបាយ (រួមមានការប្រមូល និងវិភាគទិន្នន័យ ព្រមទាំងការបង្កើតគោលនយោបាយ) | ក្រសួងកិច្ចការនារី | × | × | × | × | × | × | × |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ក្រសួងកិច្ចការនារីមានសមត្ថភាពក្នុងការវិភាគយេនឌ័រ និងរៀបចំរបាយការណ៍ប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា | ពង្រឹងសមត្ថភាពក្រសួងកិច្ចការនារីក្នុងការប្រមូល និងវិភាគទិន្នន័យ និងព័ត៌មានយេនឌ័រតាមវិស័យ និងក្នុងគោលនយោបាយ ជាពិសេសការរៀបចំការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា ដែលរួមបញ្ចូលទាំងការធ្វើរបាយការណ៍ពីគម្រោងផែនការអាទិភាពយេនឌ័រចំណូល និងចំណាយក្នុងការបញ្ជ្រាបយេនឌ័ររបស់ក្រសួងពាក់ព័ន្ធ | ក្រសួងកិច្ចការនារី<br>ក្រុមការងារយេនឌ័រ | × | × | × | × | × | × | × |
| **ក្រសួង ស្ថាប័ននានារបស់រដ្ឋាភិបាល មានសមត្ថភាព និងលទ្ធភាពក្នុងការបញ្ចូលវិធានការលើកកម្ពស់សមភាពយេនឌ័រទៅក្នុងកម្មវិធី និងថវិកាវិស័យរបស់ខ្លួន** | | | | | | | | | | |
| ៧. ពង្រឹងសមត្ថភាពក្រុមការងារយេនឌ័រនៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការបញ្ចូលយេនឌ័រក្នុងគោលនយោបាយ ផែនការ និងថវិកាតាមវិស័យ | គោលនយោបាយ ផែនការ និងថវិកាតាមវិស័យឆ្លើយតបនឹងយេនឌ័រ និងជាពិសេសក្រុមស្ត្រីក្នុងក្រុមងាយរងគ្រោះ | សិក្សា និងប៉ាន់ប្រមាណតម្រូវការសមត្ថភាពក្រុមការងារយេនឌ័រ (GMAG) របស់មន្ត្រីអំពីចំណេះដឹង ជំនាញ កាវិភាគយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ រួមបញ្ចូលទាំងតម្រូវជាយុទ្ធសាស្ត្ររបស់ស្ត្រី និងក្មេងស្រី និងក្រុមងាយរងគ្រោះ | ក្រសួងកិច្ចការនារី<br>ក្រុមការងារយេនឌ័រ<br>ក្រសួងពាក់ព័ន្ធ | | × | × | × | × | × | × |
| | | អភិវឌ្ឍសមត្ថភាពដល់ក្រុមការងារយេនឌ័រ និងដៃគូពាក់ព័ន្ធ មន្ត្រីក្រសួងកិច្ចការនារី ក្នុងបញ្ជ្រាបនិងវិភាគយេនឌ័រតាមវិស័យ | ក្រសួងកិច្ចការនារី<br>ក្រុមការងារយេនឌ័រ<br>ក្រសួងពាក់ព័ន្ធ | | × | × | × | × | × | × |
| ៨. អភិវឌ្ឍសមត្ថភាពក្រុមការងារយេនឌ័រនៅតាមមន្ទីរស្ថាប័នពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ក្នុងការបញ្ចូលយេនឌ័រក្នុងគោលនយោបាយ ផែនការ និងថវិកាតាមវិស័យនៅថ្នាក់ក្រោមជាតិ | មន្ទីរពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិក្នុងការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ ផែនការ និងថវិកាតាមវិស័យឆ្លើយតបនឹងយេនឌ័រ | សិក្សា និងប៉ាន់ប្រមាណអំពីតម្រូវការបណ្តុះបណ្តាលក្រុមការងារយេនឌ័រនៅថ្នាក់ក្រោមជាតិ | ក្រសួងកិច្ចការនារី<br>ក្រុមការងារយេនឌ័រ<br>ក្រសួងពាក់ព័ន្ធ | | | × | × | × | × | × |
| | | អភិវឌ្ឍសមត្ថភាព ដល់មន្ត្រីមន្ទីរពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ តាមរយៈក្រុមការងារយេនឌ័រ តាមវិស័យពាក់ព័ន្ធការបញ្ជ្រាបយេនឌ័រ និងតាមដាន | ក្រសួងកិច្ចការនារី<br>ក្រុមការងារយេនឌ័រ<br>ក្រសួងពាក់ព័ន្ធ | | | × | × | × | × | × |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៩.ពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រដែលស៊ីចង្វាក់ជាមួយនឹងក្រុមប្រឹក្សាកម្ពុជាដើម្បីស្ត្រីក្នុងការជំរុញការអនុវត្តច្បាប់ជាតិ គោលនយោបាយ និងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី | យន្តការថ្នាក់ជាតិ និងក្រោមជាតិ និងបានកំណត់យ៉ាងជាក់លាក់ និងមានដំណើរការយ៉ាងរលូនក្នុងកិច្ចប្រជុំសមាជិកសមាជិកា ក.ជ.ក.ស | រៀបចំ និងសម្របសម្រួលការអនុវត្តផែនការសកម្មភាព ក.ជ.ក.ស | ក.ជ.ក.ស | × | × | × | × | × | × | × |
| | ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធក្នុងការអនុវត្ត CEDAW នឹងនៅតែបន្តអនុវត្តឱ្យកាន់តែបានប្រសើរឡើងតាមផែនការដែលបានគ្រោងទុក | រៀបចំកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ ក.ជ.ក.ស និងកិច្ចប្រជុំបូកសរុបប្រចាំឆ្នាំ ក្នុងការពង្រឹង និងជំរុញការអនុវត្តច្បាប់ និងគោលនយោបាយសមភាពយេនឌ័រ និងការអនុវត្តសេចក្តីសន្និដ្ឋានរបស់ CEDAW | ក.ជ.ក.ស | × | × | × | × | × | × | × |
| | | យុទ្ធនាការផ្សព្វផ្សាយ និងស្វែងរកការគាំទ្រមតិជាមួយនឹងថ្នាក់ដឹកនាំ នៅថ្នាក់ជាតិ និងក្រោមជាតិ ក្នុងជំរុញការអនុវត្តអនុសញ្ញា CEDAW ដល់ថ្នាក់ដឹកជាតិ និងថ្នាក់ក្រោមជាតិ | ក.ជ.ក.ស | × | × | × | × | × | × | × |
| | | សម្របសម្រួល និងជំរុញលើភាពស៊ីចង្វាក់ និងពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ក្នុងរបៀបវារៈ ក.ជ.ក.ស | ក.ជ.ក.ស | × | × | × | × | × | × | × |
| | | តាមដានការអនុវត្តច្បាប់ជាតិ ការអនុវត្តសេចក្តីសន្និដ្ឋានរបស់ CEDAW និងលើកអនុសាសន៍ជូនរដ្ឋាភិបាល | ក.ជ.ក.ស | × | × | × | × | × | × | × |
| ការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ ដែលស៊ីសង្វាក់ជាមួយនឹងវិស័យពាក់ព័ន្ធ តាមរយៈការប្រើប្រាស់អភិក្រមតាមកម្មវិធី ស្តីពីសមភាពយេនឌ័រ | | | | | | | | | | |
| ១០.រៀបចំ និងអនុវត្តអភិក្រមគ្រប់គ្រងតាមកម្មវិធីដើម្បីឆ្ពោះទៅសម្រេចសមភាពយេនឌ័រ | កម្មវិធីបានប៉ាន់ប្រមាណចំណាយសម្រាប់ការអភិវឌ្ឍសមត្ថភាពអភិក្រមតាមកម្មវិធីការបង្កើនភាពអង់អាចផ្នែក សេដ្ឋកិច្ចដល់ស្ត្រីផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី | រៀបចំ និងព្រមព្រៀងលើកម្មវិធីដែលប៉ាន់ប្រមាណចំណាយលម្អិត ដែលប្រើប្រាស់ជាមូលដ្ឋានសម្រាប់អភិក្រមគ្រប់គ្រងតាមកម្មវិធី ជាពិសេសការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី | ក្រសួងកិច្ចការនារី TWG-G | × | × | × | × | | × | × |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | អនុស្សារណៈនៃការយោគយល់គ្នាជាមួយទីភ្នាក់ងារអនុវត្ត ក្នុងឯកភាពលើការងារលើកកម្ពស់សមភាព យេនឌ័រ | កំណត់តួនាទី និងការទទួលខុសត្រូវ ច្បាស់លាស់សម្រាប់អ្នកពាក់ព័ន្ធនីមួយៗ (ក្រសួងកិច្ចការនារី ក្រសួង ពាក់ព័ន្ធ អង្គការសង្គមស៊ីវិល) ក្នុងអភិក្រមតាមកម្មវិធី ដូចជាអ្នកពាក់ព័ន្ធនីមួយៗ នឹងមានផែនការចំណាយតូចៗផ្ទាល់ខ្លួន និងថវិកាដែលពាក់ព័ន្ធ ដើម្បីធានាថាផែនការទាំងនេះត្រូវបានបញ្ចូលយ៉ាងពេញលេញ ទៅក្នុងផែនការ និងថវិកាជាប្រចាំឆ្នាំ | ក្រសួងកិច្ចការនារី<br>លេខាធិការដ្ឋាន គណៈកម្មាធិការអភិក្រមគ្រប់គ្រងតាមកម្មវិធី<br>TWG-G<br>ដៃគូអភិវឌ្ឍន៍ | | × | × | × | × | × | × |
| | | រៀបចំអនុស្សារណៈនៃការយោគយល់គ្នាជាមួយអ្នកពាក់ព័ន្ធដទៃទៀត (ក្រសួងស្ថាប័នពាក់ព័ន្ធ សង្គមស៊ីវិល) | ក្រសួងកិច្ចការនារី<br>TWG-G<br>ដៃគូអភិវឌ្ឍន៍ | | × | × | × | × | × | × |
| | អនុស្សារណៈនៃការយោគយល់គ្នាជាមួយដៃគូអភិវឌ្ឍន៍ និងជាមួយក្រសួង ស្ថាប័ន | បញ្ជាក់អះអាងអំពីការគាំទ្រ និងរៀបចំទម្រង់នៃការផ្តល់ហិរញ្ញប្រទានពីដៃគូអភិវឌ្ឍន៍ និងរៀបចំកិច្ចព្រមព្រៀង ឬអនុស្សារណៈនៃការយោគយល់គ្នាជាមួយដៃគូអភិវឌ្ឍន៍ និងជាមួយនឹងក្រសួង ស្ថាប័ន | ក្រសួងកិច្ចការនារី<br>TWG-G<br>ដៃគូអភិវឌ្ឍន៍ | | × | × | × | × | × | × |
| | គោលការណ៍នៃភាពជាដៃគូសម្រាប់អភិក្រមតាមកម្មវិធីនីមួយៗ | រៀបចំបង្កើតយន្តការសម្របសម្រួល និងពិនិត្យតាមដានរួម (អភិក្រមតាមកម្មវិធីនីមួយៗមានការគ្រប់គ្រងផ្សេងៗគ្នា ប៉ុន្តែប្រើប្រាស់វិធីសាស្ត្ររួមសម្រាប់ការសម្របសម្រួល និងការវាយតម្លៃ) | ក្រសួងកិច្ចការនារី<br>TWG-G<br>ដៃគូអភិវឌ្ឍន៍ | × | × | × | × | × | × | × |
| | ក្របខណ្ឌ និងយន្តការ ពិនិត្យតាមដាន និងវាយតម្លៃតែមួយសម្រាប់ការប្រើប្រាស់រួមក្របខណ្ឌអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីដ៏ទូលំទូលាយ ដែលដឹកនាំក្រសួងកិច្ចការនារីឆ្ពោះទៅរកតួនាទីថ្មីនៅកម្រិតទីប្រឹក្សាគោលនយោបាយរបស់រាជរដ្ឋាភិបាល | ពង្រឹងកិច្ចព្រមព្រៀងជាមួយដៃគូអភិវឌ្ឍន៍លើសំណុំនៃវិធាននីតិវិធីលក្ខខណ្ឌតម្រូវសម្រាប់គាំទ្រកម្មវិធី និងកាត់បន្ថយចំណាយប្រតិបត្តិការក្រសួងកិច្ចការនារី | ក្រសួងកិច្ចការនារី<br>TWG-G<br>ដៃគូអភិវឌ្ឍន៍ | | × | × | × | × | × | × |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១១. បញ្ជ្រាបយេនឌ័រនៅក្នុងគ្រប់ក្រុមការងារបច្ចេកទេសតាមវិស័យពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល | គោលដៅ និងសកម្មភាពរបស់កម្មវិធីសមភាពយេនឌ័រតាមវិស័យពាក់ព័ន្ធត្រូវបានអនុវត្ត និងរាយការណ៍នៅក្នុងក្រុមការងារបច្ចេកទេសតាមវិស័យ | ពង្រឹងបណ្តាញយេនឌ័រជាមួយនឹងក្រុមការងារបច្ចេកទេសនានា តាមរយៈក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួង ស្ថាប័នក្នុងការជំរុញឱ្យយេនឌ័រ និងតម្រូវការជាយុទ្ធសាស្រ្តរបស់ក្រុមស្រ្តីនិងក្មេងស្រីងាយរងគ្រោះត្រូវបានបង្ហាញ និងពិភាក្សាក្នុងក្រុមការងារបច្ចេកទេសពាក់ព័ន្ធ ទាក់ទងនឹងគោលដៅកម្មវិធីសមភាពយេនឌ័រ | ក្រសួងកិច្ចការនារី<br>TWG-G<br>ដៃគូអភិវឌ្ឍន៍ | × | × | × | × | × | × | × |
| | | រៀបចំសូចនករ និងប្រព័ន្ធតាមដានឱ្យស៊ីចង្វាក់ជាមួយនឹងប្រព័ន្ធសូចនាកររួមរបស់ក្រុមការងារបច្ចេកទេសយេនឌ័រនិងក្រុមការងារបច្ចេកទេសនានា | ក្រសួងកិច្ចការនារី<br>TWG-G<br>ដៃគូអភិវឌ្ឍន៍ | × | × | × | × | × | × | × |
| | យេនឌ័រ និងតម្រូវការជាយុទ្ធសាស្រ្តរបស់ក្រុមស្រ្តី និងក្មេងស្រីងាយរងគ្រោះបានលើកឡើងនៅក្នុងផែនការតាមវិស័យសំខាន់ៗ ដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ | ស្វែងរកការគាំទ្រមតិជាមួយដៃគូអភិវឌ្ឍន៍ដែលឆ្លើយតបនឹងយេនឌ័រ ដើម្បីជំរុញឱ្យសហការីរបស់ពួកគេ និងដៃគូអភិវឌ្ឍដទៃទៀតបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីជំនួយអភិវឌ្ឍន៍ទាំងអស់នៅតាមវិស័យឱ្យកាន់តែស៊ីសង្វាក់គ្នា | ក្រសួងកិច្ចការនារី<br>TWG-G<br>ដៃគូអភិវឌ្ឍន៍ | × | × | × | × | × | × | × |
| | | ស្វែងរកការគាំទ្រមតិជាមួយអង្គការសង្គមស៊ីវិលដែលឆ្លើយតបនឹងយេនឌ័រ ដើម្បីធានាការងារបញ្ជ្រាបយេនឌ័រក្នុងការងារអភិវឌ្ឍន៍ទាំងអស់ឱ្យកាន់តែស៊ីសង្វាក់គ្នាថែមទៀត | ក្រសួងកិច្ចការនារី<br>TWG-G<br>ដៃគូអភិវឌ្ឍន៍ | × | × | × | × | × | × | × |

| និរន្តរភាពរបស់ក្រសួងកិច្ចការនារី ក្នុងការអនុវត្តការងារប្រចាំថ្ងៃ និងឈានទៅរកការអនុវត្តអភិក្រមតាមកម្មវិធី តាមរយៈការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងអភិបាលកិច្ចល្អ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងប្រសិទ្ធភាព ក្នុងការគ្រប់គ្រងជំនួយ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១២. ពង្រឹង និងពង្រីកប្រព័ន្ធនៃការផ្សព្វផ្សាយព័ត៌មាន ទំនាក់ទំនង និងរបាយការណ៍របស់ក្រសួងកិច្ចការនារី និងអ្នកពាក់ព័ន្ធ ក្នុងក្របខណ្ឌនារីរតនៈទី៤ និងអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ដើម្បីឆ្ពោះទៅសមភាពយេនឌ័រ ប្រកបដោយគុណភាព រួមទាំងនៅថ្នាក់ជាតិ និងក្រោមជាតិ | ប្រព័ន្ធនៃការផ្សព្វផ្សាយព័ត៌មាន ការប្រាស្រ័យទាក់ទង និងរបាយការណ៍របស់ក្រសួងកិច្ចការនារី និងអ្នកពាក់ព័ន្ធ ក្នុងក្របខណ្ឌនារីរតនៈទី៤ និងអភិក្រមគ្រប់គ្រងទូទាំង កម្មវិធី ស្តីពីសមភាពយេនឌ័រ ប្រកបដោយគុណភាពនៅថ្នាក់ជាតិ និងក្រោមជាតិ | ពង្រឹងបណ្តាញ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានស្តីពីសមភាពយេនឌ័រតាមវិស័យនានា រៀបចំនិងអនុវត្តការផ្សព្វផ្សាយព័ត៌មាន តាមប្រព័ន្ធអេឡិចត្រូនិច ក្នុងការគ្រប់គងព័ត៌មាន និងទំនាក់ទំនង ក្នុងក្រសួងកិច្ចការនារី និងក្រសួង ស្ថាប័នពាក់ព័ន្ធ<br><br>សម្របសម្រួល ក្នុងការផ្សព្វផ្សាយរបាយការណ៍ជាតិស្តីពីវឌ្ឍនភាព ស្ថានភាពស្ត្រី និងសមភាពយេនឌ័រដល់អ្នកពាក់ព័ន្ធ នៅថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងអន្តរជាតិ<br><br>សម្របសម្រួលកិច្ចសហការ និងទំនាក់ ទំនងអន្តរជាតិជាមួយដៃគូអភិវឌ្ឍន៍ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ នៅថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងថ្នាក់តំបន់ | ក្រសួងកិច្ចការនារី<br>TWG-G<br>ដៃគូអភិវឌ្ឍ | × | × | × | × | × | × | × |
| ១៣. រៀបចំអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ស្របតាមគោលការណ៍ណែនាំនៃកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ | គោលការណ៍ណែនាំនៃកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ ត្រូវបានអនុវត្តក្នុងប្រព័ន្ធអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី | អនុវត្តកម្មវិធីគ្រប់គ្រងធនធានមនុស្ស ស្របតាមគោលការណ៍ណែនាំ នៃកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងបន្ស៊ីជាបណ្តើរៗក្នុងដំណើរការអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ស្តីពីសមភាពយេនឌ័រជាពិសេសពាក់ព័ន្ធនឹងដំណើរការរដ្ឋបាល ការគ្រប់គ្រង និងការវាយតម្លៃលទ្ធផលការងាររបស់បុគ្គលិក | ក្រសួងកិច្ចការនារី<br>TWG-G<br>ដៃគូអភិវឌ្ឍ | × | × | × | × | × | × | × |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | បង្កើត និងពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងសម្រាប់ទទួលខុសត្រូវលើការគ្រប់គ្រងហិរញ្ញវត្ថុនិងការផ្គត់ផ្គង់ និងធ្វើការបន្សុីជាមួយនឹងដៃគូអភិវឌ្ឍ តាមរយៈអនុស្សារណៈនៃការយោគយល់គ្នាក្នុងគោលបំណងដើម្បីអនុវត្តក្នុងប្រព័ន្ធអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីស្តីពីសមភាពយេនឌ័រ និងផ្តោតលើការយកចិត្តទុកដាក់អំពីផលប៉ះពាល់ការផ្លាស់នាពេលអនាគត | ក្រសួងកិច្ចការនារី<br>TWG-G<br>ដៃគូអភិវឌ្ឍ | | | × | × | × | × | × |
| ១៤. ពង្រឹងយន្តការ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងវាយតម្លៃលើវឌ្ឍនភាព និងដំណើរការយន្តការក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ | យន្តការ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងវាយតម្លៃលើវឌ្ឍនភាព និងដំណើរការយន្តការ ក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិប្រកបដោយប្រសិទ្ធភាព | ការរៀបចំប្រព័ន្ធ និងយន្តការក្នុងការតាមដាន និងវាយតម្លៃក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងក្របខណ្ឌអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី<br><br>ការបន្តពង្រឹងមុខងារសវកម្មផ្ទៃក្នុង និងអធិការកិច្ចសម្រាប់ក្រសួងកិច្ចការនារី និងបន្សុីជាមួយនឹងអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី | ក្រសួងកិច្ចការនារី<br>TWG-G<br>ដៃគូអភិវឌ្ឍ | × | × | × | × | × | × | × |

ផ្នែកទី៥

# ធនធានហិរញ្ញវត្ថុ

ការអនុវត្តផែនការយុទ្ធសាស្ត្រ**នារីរតនៈទី៤** គឺពឹងផ្អែកលើធនធានពីរសំខាន់ៗ គឺថវិការដ្ឋ និងការចូលរួមចំណែកពីដៃគូពាក់ព័ន្ធ ។

តម្លៃប៉ាន់ស្មាន ក្នុងតម្រូវការអនុវត្តន៍ផែនការយុទ្ធសាស្ត្រ**នារីរតនៈ៤** ប្រមាណ ៣១ ១០០ ០០០ ដុល្លារអាមេរិក ។ ដោយយេនឌ័រជារបៀបវារៈអន្តរវិស័យរបស់រាជរដ្ឋាភិបាល ការប៉ាន់ប្រមាណតម្រូវការធនធានសរុបសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ**នារីរតនៈទី៤**នេះ មិនបានរាប់បញ្ចូលនូវថវិកាដែលឆ្លើយតបយេនឌ័រតាមវិស័យពាក់ព័ន្ធនោះទេ។

ការប៉ាន់ស្មាននេះបានធ្វើឡើង តាមវិស័យ និងកម្មវិធីជាយុទ្ធសាស្ត្រនីមួយៗ ដូចខាងក្រោម÷

| ក្របខណ្ឌយុទ្ធសាស្ត្រនីមួយៗ | ថវិកាប៉ាន់ស្មាន | ប្រភពមូលនិធិ [52] |
|---|---|---|
| ១. កំណើនសេដ្ឋកិច្ច | | |
| ១.១. ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី | $៤ ៩០០ ០០០ | ថវិការដ្ឋ រួមជាមួយនឹង UN Women, ADB, UNDP, SIDA, JICA, Oxfam, ILO, USAID, EU, WB, IFAD, IOM និងដៃគូដទៃទៀត |
| ២. លទ្ធភាពទទួលបានសេវាសង្គម និងកិច្ចគាំពារសង្គម | | |
| ២.១. ការអប់រំស្ត្រីនិងក្មេងស្រី និងការផ្លាស់ប្តូរឥរិយាបថ | $១ ២០០ ០០០ | ថវិការដ្ឋ រួមជាមួយនឹង UNICEF, UNSCO, Action Aid, Plan International, UNDP និងដៃគូដទៃទៀត |
| ២.២. ការលើកកម្ពស់សុខភាព អាហារូបត្ថម្ភសម្រាប់ស្ត្រី និងកុមារី និងទប់ស្កាត់មេរោគអេដស៍ និងជំងឺអេដស៍ | $៤ ១០០ ០០០ | ថវិការដ្ឋ រួមជាមួយនឹង Fred Hollow Foundation, Global Fund, UNFPA, UN Women និងដៃគូដទៃទៀត |
| ២.៣. កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងកុមារី | $៥ ០០០ ០០០ | ថវិការដ្ឋ រួមជាមួយនឹង UN Women, GIZ, UNFPA, DFAT, Care International, PyD និងដៃគូដទៃទៀត |
| ៣. បញ្ហាអន្តរវិស័យ | | |
| ៣.១. ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេច និងការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងកម្មវិធីកំណែទម្រង់ | $៤ ៣០០ ០០០ | ថវិការដ្ឋ រួមជាមួយនឹង UNDP, UNFPA, SWISS, Oxfam, SIDA, UN Women និងដៃគូដទៃទៀត |
| ៣.២. យេនឌ័រនិងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ | $១ ២០០ ០០០ | ថវិការដ្ឋ រួមជាមួយនឹង ADB, EU, SIDA, UNDP, SWISS, GEF និងដៃគូដទៃទៀត |
| ៤. ការពង្រឹងស្ថាប័ន និងសមត្ថភាពសម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ | $១០ ៤០០ ០០០ | ថវិការដ្ឋ រួមជាមួយនឹងដៃគូអភិវឌ្ឍទាំងអស់ដែលគាំទ្រដល់ក្រសួងកិច្ចការនារី ជាពិសេស UNDP, SIDA, UNFPA, UN Women, JICA, GIZ |

[52] នៅក្នុងដំណើរការរៀបចំនារីរតនៈទី៤ ក្រុមការងារបានទទួលព័ត៌មានពីប្រភពធនធានដែលមានសក្តានុពលតាមវិស័យ និងកម្មវិធីនិមួយៗ ក្រសួងកិច្ចការនារី នឹងបន្តស្វែងរកការគាំទ្រធនធាននៅពេលដំណើរការអនុវត្តន៍។

## ផ្នែកទី៦

# ការពិនិត្យតាមដាន និងការវាយតម្លៃ

## ការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ

ដោយផ្អែកលើផែនការយុទ្ធសាស្ត្រ**នារីរតនៈទី៤** *ក្រសួងកិច្ចការនារី* ក្នុងភាពជាដៃគូជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ នឹងរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ដោយស្របតាមអាណត្តិ និងភារកិច្ចដែលបានកំណត់ដោយច្បាប់។ កិច្ចការនេះនឹងដំណើរការ តាមរយៈភាពជាដៃគូនៃក្រុមការងារបច្ចេកទេសយេនឌ័រ ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី និងដៃគូពាក់ព័ន្ធ ដោយមាននាយកដ្ឋានផែនការនិងស្ថិតិ នៃក្រសួងកិច្ចការនារីជាសេនាធិការ ។ ការរៀបចំ និងពិនិត្យឡើងវិញនូវផែនការសកម្មភាពប្រចាំឆ្នាំ នឹងធ្វើឡើងនៅអំឡុងចុង និងដើមឆ្នាំនីមួយៗក្នុងរយៈពេល៥ឆ្នាំ នៃផែនការយុទ្ធសាស្ត្រ**នារីរតនៈទី៤** ដោយផ្អែកលើផែនការយុទ្ធសាស្ត្រនេះជាមួយនឹងគោលនយោបាយ និងកម្មវិធី ដែលមានបច្ចុប្បន្នភាពនានា និងស្របតាមស្ថានភាពជាក់ស្តែង។ ម្យ៉ាងវិញទៀត ក្រសួងកិច្ចការនារី នឹងដើរតួជាអ្នកសម្របសម្រួលក្នុងដំណើរការនេះ តាមរយៈការរៀបចំកិច្ចប្រជុំបូកសរុបប្រចាំឆ្នាំ និងលើកផែនការបន្ត ។

## ការត្រួតពិនិត្យ និងតាមដាន

ដោយផ្អែកលើសូចនាករដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រនេះ ផែនការសកម្មភាពប្រចាំឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំ ក្រសួងកិច្ចការនារី ក្នុងភាពជាដៃគូជាមួយនឹងក្រសួង ស្ថាប័ននានាដែលពាក់ព័ន្ធ នឹងធ្វើការត្រួតពិនិត្យ ឡើងវិញនូវការរីកចម្រើន ក្នុងរយៈពេលខ្លី និងមធ្យម។

ក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងក្រុមការងារបច្ចេកទេសយេនឌ័រ នឹងសម្របសម្រួលក្នុងការរៀបចំរបាយការណ៍រីកចម្រើនលើការលើកកម្ពស់សមភាពយេនឌ័រ និងការបញ្ជ្រាបយេនឌ័រជាប្រចាំ ដើម្បីចែករំលែក ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍ ។ ដូចនេះការត្រួតពិនិត្យ និងតាមដាននូវការរីកចម្រើនលើការងារអនុវត្តយុទ្ធសាស្ត្រនារីរតនៈទី៤ ក៏ត្រូវផ្សព្វផ្សាភ្ជាប់នៅក្នុងរបាយការណ៍ទាំងនោះផងដែរ ។

## ការវាយតម្លៃ

ដើម្បីពិនិត្យលើប្រសិទ្ធភាព និងភាពសក្តិសិទ្ធិនៃការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈ ក្រសួងកិច្ចការនារី និងដៃគូពាក់ព័ន្ធ នឹងរៀបចំការវាយតម្លៃពាក់កណ្តាលអាណត្តិ និងសន្និបាតជាតិបូកសរុបលទ្ធផលការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ ។ រាល់ដៃគូពាក់ព័ន្ធទាំងអស់ នឹងចូលរួមយ៉ាងទូលំទូលាយ ក្នុងការវាយតម្លៃលទ្ធផលការងារទាំងនេះ និងលើកឡើងពីទិសដៅបន្ត ។

សន្និបាតជាតិបូកសរុបលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រ**នារីរតនៈទី៤** នឹងរៀបចំឡើងនៅពេលបញ្ចប់ អាណត្តិនៃផែនការយុទ្ធសាស្ត្រ**នារីរតនៈទី៤** តាមរយៈការចូលរួមពីភ្នាក់ងារអនុវត្តន៍ និងដៃគូពាក់ព័ន្ធ ដើម្បីបូកសរុបអំពីលទ្ធផលដែលបានអនុវត្ត និងជាមួយនូវផលប៉ះពាល់ជាវិជ្ជមាន នៃផែនការយុទ្ធសាស្ត្រនេះ ។

ចំណុចសំខាន់ដែលអាចផ្ទៀងផ្ទាត់អំពីលទ្ធផលនៃការសម្រេចនេះ តាមរយៈការធ្វើបច្ចុប្បន្នកម្ម នៃឯកសារប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា និងពិនិត្យលើការសម្រេចនូវចំណុចដៅ នៃសូចនាករសំខាន់ៗដែលពាក់ព័ន្ធនឹងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ។

*ក្រសួងកិច្ចការនារី* នឹងបង្កើតនូវក្របខណ្ឌតាមដាន និងវាយតម្លៃដែលមានគូសបញ្ជាក់អំពីតួនាទីរបស់ក្រសួង វិទ្យាស្ថានជាតិ ស្ថិតិ និងក្រសួងស្ថាប័នពាក់ព័ន្ធ ។ ដោយមានពហុវិស័យនៃបញ្ហាយេនឌ័រ ការតាមដាន និងវាយតម្លៃ គឺជាការទទួលខុសត្រូវរបស់គ្រប់ដៃគូពាក់ព័ន្ធដែលចូលរួម ។ ក្រសួងកិច្ចការនារី មានតួនាទីក្នុងពិនិត្យ និងសម្របសម្រួល ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ វិទ្យាស្ថានជាតិស្ថិតិ និងវិទ្យាស្ថានស្រាវជ្រាវផ្សេងទៀត គឺជាដៃគូដ៏សំខាន់ក្នុងប្រមូលទិន្នន័យ ។

**នារីរតនៈទី៤** នឹងចូលរួមក្នុងសម្រេច និងតាមដាននូវសូចនាករជាតិសំខាន់ៗ ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ដូចខាងក្រោម÷

## សូចនាករតាមដានត្រួតពិនិត្យសំខាន់ៗ ២០១៤-២០១៨

| គោលដៅ/ សូចនាករសំខាន់ៗ | | ឯកតា | 2013 | 2014 | 2015 | 2016 | 2017 | 2018 | ប្រភព |
|---|---|---|---|---|---|---|---|---|---|
| ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី | | | | | | | | | |
| | ការចូលរួមរបស់ស្ត្រីក្នុងការងារទទួលកម្រៃ | | | | | | | | |
| ១. | *កសិកម្ម* | % | ៥២ | ៥១ | ៥០ | ៥០ | ៥០ | ៥០ | ជទបក[53] (វជស)[54] |
| ២. | *ឧស្សាហកម្ម* | % | ៦០ | ៥០ | ៥០ | ៥០ | ៥០ | ៥០ | ជទបក (វជស) |
| ៣. | *សេវាកម្ម* | % | ៣០ | ៣៥ | ៤០ | ៤០ | ៤០ | ៤០ | ជទបក (វជស) |
| ៤. | *សមាមាត្រស្ត្រីបានបញ្ចប់ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ រយៈពេលវែង* | នាក់ | ៨ ០០០ | ៨ ៥០០ | ៩ ០០០ | ៩ ៥០០ | ១០ ០០០ | ១១ ០០០ | បពរកស[55] (កកបវ) |
| យេនឌ័រនិងការអប់រំ | | | | | | | | | |
| ៥. | អត្រារួមនៃការសិក្សារបស់ក្មេងស្រីនៅមធ្យមសិក្សាទុតិយភូមិ | % | ២៧,៦ | ២៧,២ | ២៨,៤ | ៣១,៥ | ៣៥,៦ | ៤១,៩ | កអយក |
| ៦. | អត្រារួមនៃស្ត្រីសិក្សានៅឧត្តមសិក្សា | % | ១២ | ១៣ | ១៤ | ១៦ | ១៨ | ២០ | កអយក |
| យេនឌ័រក្នុងវិស័យសុខាភិបាល | | | | | | | | | |
| ៧. | អត្រាមរណភាពមាតា | ក្នុង១រយពាន់កំណើតរស់ | ២០៦ | | ១៤០ | | | ១៣០ | បពរកស (កសភ) |

53 ជទបស (ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា)

54 វជស (វិទ្យាស្ថានជាតិស្ថិតិ)

55 បពរកស (ប្រព័ន្ធព័ត៌មានរដ្ឋបាលរបស់ក្រសួង ស្ថាប័ន)

| គោលដៅ/សូចនាករសំខាន់ៗ | | ឯកតា | 2013 | 2014 | 2015 | 2016 | 2017 | 2018 | ប្រភព |
|---|---|---|---|---|---|---|---|---|---|
| ៨. | ភាគរយស្ត្រីពិនិត្យផ្ទៃពោះយ៉ាងតិចចំនួន ២ដង | % | ៨៨ | ៨៩ | ៩០ | ៩១ | ៩៣ | ៩៥ | HIS (MOH) |
| ៩. | អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើប | % | ៣៧ | ៣៩ | ៥១ | ៥២ | ៥៣ | ៥៤ | បពរកស (កសភ) |
| កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី | | | | | | | | | |
| ១០. | ចំនួនគ្រួសារដែលមានបញ្ហាអំពើហិង្សាក្នុងគ្រួសារ | ចំនួន | ២៧ ០០០ | ២៥ ០០០ | ២៣ ០០០ | ២០ ០០០ | ១៨ ០០០ | ២៥ ០០០ | បពរកស (កកន) |
| ១១. | អត្រាប្រេវ៉ាឡង់អំពើហិង្សាក្នុងគ្រួសារ | ចំនួន | ១២,៨ | ១២,៨ | ១១,៥ | ១១,៥ | ១១,៥ | ១១,៥ | បពរកស (កកន) |
| សមាមាត្រស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ | | | | | | | | | |
| ១២. | ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ (ចាប់ពីអគ្គនាយកដល់ការិយាល័យទាំងនៅថ្នាក់ជាតិ និងក្រោមជាតិ) | % | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ | ក្រ មុខងារសាធារណៈ |
| ១៣. | អគ្គនាយក | % | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | បពរកស (កកន) |
| ១៤. | ប្រធាននាយកដ្ឋាន | % | ១២ | ១២ | ១៤ | ១៥ | ១៦ | ១៧ | បពរកស (កកន) |
| ១៥. | ប្រធានខុទ្ទកាល័យ ឬមន្ទីរថ្នាក់ខេត្ត | % | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | បពរកស (កកន) |
| ១៦. | សមាមាត្រស្ត្រីក្នុងវិស័យសាធារណៈ | % | ៣៥.៥ | ៣៦ | ៣៦.៥ | ៣៧ | ៣៧ | ៣៧ | ក្រ.មុខងារសាធារណៈ |
| ១៧. | សមាមាត្រអាសនៈក្នុងព្រឹទ្ធសភា | % | ១៤,៧ | ១៤,៧ | ១៤,៧ | ១៤,៧ | ៣០ | ៣០ | បពរកស (កកន) |
| ១៨. | សមាមាត្រស្ត្រី ក្នុងរដ្ឋសភា | % | ២០ | ២០ | ២០ | ២០ | ២០ | ៣០ | |
| | សមាមាត្រស្ត្រីជាក្រុមប្រឹក្សា | | | | | | | | |
| ១៩. | រាជធានី ខេត្ត | % | ១០ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | បពរកស (កកន) |
| ២០. | ក្រុង ស្រុក ខណ្ឌ | % | ១២,៦៨ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | បពរកស (កកន) |
| ២១. | ឃុំ សង្កាត់ | % | ១៨ | ១៨ | ១៨ | ១៨ | ២៥ | ២៥ | បពរកស (កកន) |
| យេនឌ័រ និងបម្រែបម្រួលអាកាសធាតុ និងការអភិវឌ្ឍបៃតង | | | | | | | | | |
| ២២. | ចំនួនស្ត្រីជាអ្នកទទួលផលពីកម្មវិធីបម្រែបម្រួលអាកាសធាតុ | ចំនួន | ៥០០០០ | ៧០,០០០ | ៩០,០០០ | ១១០, ០០០ | ១៣០, ០០០ | ១៥០, ០០០ | បពរកស (កកន) |
| ២៣. | ចំនួនគ្រួសារដែលមានលទ្ធភាព ទទួលបានទឹកស្អាតពេញមួយឆ្នាំ | ចំនួន | ១៩០០ ០០០ | ២,០០០, ០០០ | ២,១០០, ០០០ | ២,២០០, ០០០ | ២,៣០០, ០០០ | ២,៤០០, ០០០ | បពរកស (កកន) |

# គំនូសបំព្រួញ នៃផែនការយុទ្ធសាស្ត្រ **នារីរតនៈទី៤**
# ដើម្បីសមភាពយេនឌ័រនិងការបង្កើនភាពអង់អាចដល់ស្ត្រី
# ឆ្នាំ២០១៤ - ២០១៨

| ១. កំណើនសេដ្ឋកិច្ច | ២. លទ្ធភាពទទួលបានសេវាសង្គម និងកិច្ចគាំពារសង្គម | ៣. បញ្ហាអន្តរវិស័យ |
| --- | --- | --- |
| ១.១. ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី | ២. ១. ការអប់រំស្ត្រី និងក្មេងស្រី និងការផ្លាស់ប្តូរឥរិយាបថ<br>២. ២. ការលើកកម្ពស់សុខភាព អាហារូបត្ថម្ភសម្រាប់ស្ត្រីនិងកុមារី និងទប់ស្កាត់មេរោគអេដស៍និងជំងឺអេដស៍<br>២. ៣. កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងកុមារី | ៣.១. ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេច និងការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល<br>៣.២. យេនឌ័រ និងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ |

**៤. ការអភិវឌ្ឍស្ថាប័ន និងសមត្ថភាពសម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ**

ក្រសួងកិច្ចការនារី
ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ ៣ សង្កាត់ស្ទឹងមានជ័យ
ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ហ្វាក់ : (+៨៥៥) ២៣ ៨៨០ ៧៣៧
អ៊ីម៉ែល : mwa@online.com.kh
វេបសាយ : www.mowa.gov.kh
ហ្វេសប៊ុក : www.facebook.com/mowa.gov.kh